ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

## ស្ដីពី

## សកម្មភាព និងលទ្ធផលនៃការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ

## ឆ្នាំ២០១០

## និងទិសដៅ ឆ្នាំ២០១១

# អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជា បានយកចិត្តទុកដាក់បង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទតាំងពីឆ្នាំ ១៩៩៦ ដោយបានកសាងនិងអនុម័តច្បាប់ស្តីពី ការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស និងបានតាក់តែងច្បាប់ថ្មីមួយទៀតឈ្មោះថា ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលមានវិសាលភាពទូលំទូលាយជាងច្បាប់ចាស់ និងដែលត្រូវបានអនុម័ត និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការពីឆ្នាំ ២០០៨ ។

យន្តការជាតិដែលមានលក្ខណៈជាពហុវិស័យ ត្រូវបានរៀបចំជាបន្តបន្ទាប់ ដើម្បីឆ្លើយតបទៅនឹងការជួញដូរមនុស្សក្នុងប្រទេស និងក្នុងតំបន់តាំងពីឆ្នាំ ២០០៥ គឺក្រុមការងារខមមីតកម្ពុជា ដែលទទួលខុសត្រូវអនុវត្តផែនការប្រឆាំងការជួញដូរមនុស្សក្នុងមហាអនុតំបន់ទន្លេមេគង្គ នៅក្នុងប្រទេសកម្ពុជា ។ នៅឆ្នាំ ២០០៧ ក្រុមការងារថ្នាក់ជាតិប្រឆាំងការជួញដូរមនុស្ស (National Taskforce) និងក្រុមការងារដឹកនាំការប្រយុទ្ធប្រឆាំង ការជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ (High Level Working Group) ត្រូវបានបង្កើតឡើង ដើម្បីអនុវត្តសកម្មភាពប្រឆាំងការជួញដូរមនុស្សក្នុងប្រទេស និងត្រូវបានច្របាច់បញ្ចូលគ្នានៅចុងឆ្នាំ ២០០៩ ឱ្យទៅជាយន្តការជាតិតែមួយហៅថា **គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដែលហៅកាត់ថា ប.ជ.រ.ព.ភ** ដឹកនាំដោយ **ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ។ គណៈកម្មាធិការជាតិនេះ គឺជាការប្រមូលផ្តុំកម្លាំងសរុបទាំងរដ្ឋាភិបាល ទាំងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ទាំងនៅថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិដើម្បីរួមគ្នាប្រឆាំងការជួញដូរមនុស្ស និងអំពើពាក់ព័ន្ធឱ្យមានប្រសិទ្ធភាពខ្ពស់ និងមានលេខាធិការដ្ឋានថ្នាក់ជាតិមួយជាសេនាធិការ ។

យុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស ត្រូវបានអនុវត្តយ៉ាងសកម្ម ដោយក្រុមការងារចំរុះក្រសួង ស្ថាប័ន ចំនួនប្រាំមួយដែលត្រូវបានរៀបចំឡើងក្រោមការដឹកនាំរបស់លេខាធិការដ្ឋាន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងនោះមាន:

**ការបង្ការទប់ស្កាត់** - ជាសមរភូមិសំខាន់ទីមួយក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយត្រូវកំណត់អំពីឫសគល់នៃអំពើជួញដូរមនុស្ស និងត្រូវបង្កើតមធ្យោបាយសម្រាប់លុបបំបាត់បុព្វហេតុជាឫសគល់ទាំងនេះ ដើម្បីទប់ស្កាត់ឱ្យបានមុនពេលដែលការជួញដូរមនុស្សកើតមានឡើង ។

**ការអនុវត្តន៍ច្បាប់** - គឺជាសកម្មភាពបង្ក្រាបបទល្មើសជួញដូរមនុស្សដែលអាចកើតមានឡើង ដោយអនុវត្តតាមច្បាប់ទាំងឡាយដើម្បីប្រឆាំងអំពើជួញដូរមនុស្ស និងដើម្បីសង្គ្រោះជនរងគ្រោះឱ្យបានទាន់ពេលវេលា និងស្រាវជ្រាវឃាត់ខ្លួនជនសង្ស័យ និងអ្នកពាក់ព័ន្ធ បញ្ជូនទៅតុលាការដើម្បីផ្តន្ទាទោស និងផ្តល់យុត្តិធម៌ជូនជនរងគ្រោះ ។

**ការការពារជនរងគ្រោះ** - គឺជាការផ្តល់សេវាក្នុងការការពារ ស្តារនីតិសម្បទា មាតុភូមិនិវត្តន៍ និង សមាហរណកម្មជនរងគ្រោះដើម្បីអាចមានឱកាសវិលត្រឡប់ទៅរស់នៅក្នុងគ្រួសារ ឬសហគមន៍វិញដោយសុវត្ថិភាព និងគ្មានការរើសអើង ។

**កិច្ចការយុត្តិធម៌** - ជនសង្ស័យដែលពាក់ព័ន្ធនឹងការជួញដូរមនុស្សត្រូវបានបញ្ជូនទៅតុលាការព្រមជាមួយវត្ថុតាង និងសាក្សី ដើម្បីធ្វើចំណាត់ការរឿងក្តី និងដាក់ទោសទណ្ឌឱ្យសក្តិសមទៅនឹងទម្ងន់ទោស ដើម្បីធានាថាបទឧក្រិដ្ឋទាំងឡាយដែលគេបានប្រព្រឹត្តមិនអាចគេចផុតពីការដាក់ទោសទណ្ឌឡើយ ។

**កិច្ចសហប្រតិបត្តិការអន្តរជាតិ** - គឺជាការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ជាមួយបណ្តាប្រទេសពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាជួញដូរមនុស្សដែលកើតមានឡើងជាលក្ខណៈឆ្លងដែន ។

**កិច្ចការកុមារ** - គឺជាការយកចិត្តទុកដាក់ជាពិសេស ទៅលើកុមារដែលស្ថិតនៅក្នុងស្ថានភាពជួញដូរ ព្រោះកុមារគឺជាក្រុមជនដែលងាយរងគ្រោះជាងគេ និងត្រូវការឱ្យមានការថែទាំ និងកិច្ចប្រឹងប្រែងពិសេសដែលផ្តោតសំខាន់លើវិស័យកុមារ ។

ក្នុងឆ្នាំ ២០១០កន្លងទៅនេះ គណៈកម្មាធិការជាតិ ប.ជ.រ.ព.ភ គ្រប់ថ្នាក់ គ្រប់ផ្នែក បានបង្កើនការយកចិត្តទុកដាក់ និងកិច្ចខិតខំប្រឹងប្រែងទៅតាមមុខសញ្ញារៀងៗខ្លួន រហូតទទួលបាននូវលទ្ធផលល្អប្រសើរគួរឱ្យកត់សម្គាល់ ពោលគឺការកាត់បន្ថយប្រសិទ្ធភាពនៃបទល្មើសជួញដូរមនុស្សតាមរយៈមធ្យោបាយបង្ការ ទប់ស្កាត់ បង្ក្រាប និងផ្តន្ទាទោស ព្រមទាំងអាចសង្គ្រោះជនរងគ្រោះ និងផ្តល់សេវាថែទាំ ទាំងនៅតាមមជ្ឈមណ្ឌល ទាំងនៅតាមគ្រួសារ និងសហគមន៍បានជាច្រើនករណី គឺច្រើនជាងឆ្នាំកន្លងទៅ ។

ក្នុងនាមគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ខ្ញុំមានមោទនភាពខ្ពស់ចំពោះយន្តការជាតិនេះ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រមុខរាជរដ្ឋាភិបាល គឺ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានជម្រុញ និងផ្តល់ការលើកទឹកចិត្តឱ្យបង្កើតជាគណៈកម្មាធិការជាតិនេះ និងសូមថ្លែងអំណរគុណដល់បណ្តាសហគមន៍អន្តរជាតិ អង្គការដៃគូអភិវឌ្ឍន៍អន្តរជាតិ និងអង្គការសង្គមស៊ីវិលទាំងអស់ ដែលបានព្រួតដៃគ្នា ជាមួយរាជរដ្ឋាភិបាល ប្រឆាំងបទឧក្រិដ្ឋដែលគួរឱ្យស្អប់ខ្ពើមនេះ ហើយសង្ឃឹមថាគ្រប់ក្រសួង ស្ថាប័ន ទាំងរដ្ឋាភិបាល ទាំងសង្គមស៊ីវិល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនឹងនៅតែបន្តកិច្ចការនេះដោយមិនធ្វេសប្រហែស និងមិនបណ្តែតបណ្តោយឱ្យបទល្មើសទាំងឡាយនេះកើតមានឡើងបានដោយមិនបានយកចិត្តទុកដាក់នោះទេ។

ជាមួយគ្នានេះដែរ ការអនុវត្តន៍គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព បាននិងកំពុងតែដើរតួជាគន្លឹះក្នុងការលុបបំបាត់បទល្មើសទាំងឡាយនៅតាមបណ្តាភូមិឃុំទូទាំងប្រទេស ដើម្បីកសាងនូវសំណាញ់សុវត្ថិភាព និងបណ្តាញអនុវត្តច្បាប់ឱ្យកាន់តែមានប្រសិទ្ធភាពទៅឡើងទៀត ។

ខ្ញុំសូមជូនពរបវរមហាប្រសើរក្នុងឱកាសឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ ត្រីស័ក ពុទ្ធស័ករាជ ២៥៥៥ នេះសូមនាំមកនូវជោគជ័យ សិរីមង្គល វិបុលសុខ គ្រប់ប្រការ ជូនសម្តេច លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា បងប្អូន ជនរួមជាតិទាំងអស់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរគុណ

# មាតិកា

ទំព័រ


I- សភាពការណ៍ទូទៅ ............ ១-២

II- លទ្ធផលការងារ ប.ជ.រ.ព.ភ ............ ២-១៦

ក- ការរៀបចំច្បាប់-បទដ្ឋាន និងគោលនយោបាយ ............ ២-៣

ខ- ការងារដឹកនាំ សម្របសម្រួល ............ ៣-៤

គ- ការអនុវត្តន៍យុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស ............ ៤-១២

១- ការងារបង្ការ-ទប់ស្កាត់ ............ ៤-៦

២- ការងារការពារ ស្តារនីតិសម្បទា សមាហរណកម្ម និងមាតុភូមិនិវត្តន៍ ............ ៦-៨

៣- ការងារអនុវត្តច្បាប់ ............ ៨

៤- ការងារកិច្ចការយុត្តិធម៌ ............ ៨

៥- ការងារសហប្រតិបត្តិការអន្តរជាតិ ............ ៩-១១

៦- ការងារកិច្ចការកុមារ ............ ១១-១២

ឃ- ការលើកកម្ពស់សមត្ថភាព ............ ១២-១៤

ង- ការងារតាមដានត្រួតពិនិត្យ ............ ១៤-១៥

ច- ការងារគណៈកម្មាធិការដឹកនាំ និងលេខាធិការដ្ឋាន ប.ផ.រ.ព.ភ រាជធានីខេត្ត ............ ១៥-១៦

១- ការងារចាត់តាំង ............ ១៥

២- ការងារប្រឆាំងការជួញដូរមនុស្ស ............ ១៥-១៦

III- ការវាយតម្លៃ ............ ១៦-១៨

ក- ចំណុចខ្លាំង ............ ១៦-១៧

ខ- ចំណុចសេសសល់ និងភាពប្រឈម ............ ១៨

IV- ទិសដៅសំរាប់ ឆ្នាំ២០១១ ............ ១៨-២០

# របាយការណ៍ស្តីពី

## សកម្មភាព និងលទ្ធផលការងារបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ឆ្នាំ២០១០ និងទិសដៅឆ្នាំ២០១១

## (គិតចាប់ពីថ្ងៃទី២៦/១២/០៩ ដល់ថ្ងៃទី២៥/១២/១០)

### I~ សភាពការណ៍ទូទៅ :

អំពើជួញដូរមនុស្សគឺជាបទល្មើសសកល ដែលកើតមានឡើងនៅក្នុងពិភពលោកតាំងពីយូរលង់មកហើយ រហូតដល់បច្ចុប្បន្ន ។ ការជួញដូរមនុស្សគឺជាការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរបំផុត ដែលមិនអាចអត់អោនបាន និងជាទាសភាពសម័យថ្មីដែលពិភពលោកបាន និងកំពុងតែសកម្មរួមគ្នាប្រយុទ្ធប្រឆាំងយ៉ាងដាច់ខាត ។ ក្នុងរយៈពេលច្រើនឆ្នាំកន្លងមកនេះ ទេសន្តរប្រវេសន៍ការងារក្នុងតំបន់អាស៊ីអាគ្នេយ៍បានកើនឡើងគួរឱ្យកត់សំគាល់ អាស្រ័យដោយគម្លាតផ្នែកធនធានសេដ្ឋកិច្ច បរិស្ថាន ស្ថានភាពរស់នៅ សេចក្តីត្រូវការ និងកំរិតនៃការអភិវឌ្ឍន៍ខុសគ្នាខ្លាំងពីប្រទេសមួយទៅប្រទេសមួយទៀត ។

ព្រមជាមួយនឹងដំណើរការអភិវឌ្ឍន៍ក្នុងតំបន់ដែលកាន់តែរីកចម្រើនឡើងឆ្ពោះទៅកាន់សមាហរណកម្មសេដ្ឋកិច្ចនាពេលខាងមុខ គេរំពឹងថាទេសន្តរប្រវេសន៍ការងារនឹងបន្តកើនឡើង ។ សកលភាវូបនីយកម្ម និងសមាហរណកម្មសេដ្ឋកិច្ចនៅតែបន្ត រីឯការឆ្លើយតបរបស់អន្តររដ្ឋាភិបាលចំពោះបញ្ហាទេសន្តរប្រវេសន៍នៅមិនទាន់គ្រប់គ្រាន់ ដែលជាហេតុនាំឱ្យមានភាពប្រឈមដល់ប្រជាពលរដ្ឋមួយចំនួន ដែលបានត្រៀមខ្លួនជាស្រេចក្នុងការបម្រើសេវាកម្មរបស់ពួកឈ្មួញទាំងឡាយទាំងប្រថុយប្រថាន ដោយសង្ឃឹមថានឹងអាចធ្វើឱ្យប្រសើរឡើងដល់ស្ថានភាពរស់នៅរបស់ពួកគេ ។

ជនទេសន្តរប្រវេសន៍ដែលគេចវេសពីភាពស្របច្បាប់ ដោយប្រថុយប្រថានតាមការអូសទាញពីមេខ្យល់ដែលមានល្បិចកលតែងតែប្រឈមទៅនឹងហានិភ័យខ្ពស់ ហើយស្ថានភាពរបស់ជនទេសន្តរប្រវេសន៍ ដែលត្រូវបានគេនាំឬបញ្ជូនចេញដោយខុសច្បាប់ទាំងនោះ តែងតែជួបប្រទះជាញឹកញាប់នូវគ្រោះថ្នាក់ដោយអំពើហិង្សា ឬការកេងប្រវ័ញ្ចន៍ និងការរំលោភសិទ្ធិ នៅពេលដែលពួកគេបានទៅដល់ប្រទេសគោលដៅ និងជួនកាលត្រូវបានគេបន្តជួញដូរទៅកន្លែងថ្មី ឬប្រទេសផ្សេងទៀតដែលឆ្ងាយពីផ្ទះ ។

ក្នុងរយៈពេលប្រមាណជាជិតពីរទសវត្សរ៍ចុងក្រោយនេះ មានពលរដ្ឋកម្ពុជាកាន់តែច្រើន បានធ្វើចំណាកស្រុកទៅរកការងារធ្វើនៅក្រៅប្រទេសទាំងស្របច្បាប់ ទាំងមិនស្របច្បាប់ ជាពិសេសទៅប្រទេសថៃ និងប្រទេសម៉ាឡេស៊ីដែលជាប្រទេសគោលដៅដ៏សំខាន់នៃជនទេសន្តរប្រវេសន៍កម្ពុជា ។ ថៃគឺជាប្រទេសមួយដែលជនទេសន្តរប្រវេសន៍កម្ពុជាតែងតែឆ្លងដែន ចូលទៅរកការងារធ្វើដោយខ្លួនឯង និងដែលកំពុងតែប្រឈមមុខនឹងគ្រោះថ្នាក់ និងការកេងប្រវ័ញ្ចន៍យ៉ាងខ្លាំង ។ មានកត្តាជំរុញ និងកត្តាអូសទាញជាច្រើន មានជាអាទិ៍ ភាពក្រីក្រ កង្វះការអប់រំ ការចង់ឱ្យជីវភាពគ្រួសារប្រសើរជាងមុន កង្វះទីផ្សារការងារក្នុងប្រទេស កង្វះការយល់ដឹងអំពីការជួញដូរមនុស្សនិងការធ្វើទេសន្តរប្រវេសន៍ដោយប្រថុយប្រថាន កង្វះការយល់ដឹងអំពីកលល្បិចឈ្មួញ ឬមេខ្យល់ដែលមានចេតនាអូសទាញកម្លាំងដើម្បីកេងប្រវ័ញ្ចយកផលប្រយោជន៍ជាដើម ។ល ។

គួរកត់សំគាល់បន្ថែមទៀតថា ជនចំណាកស្រុករកការងារធ្វើទាំងក្នុង និងក្រៅប្រទេសដោយខ្វះការយល់ដឹងគ្រប់គ្រាន់ និងប្រថុយប្រថានងាយធ្លាក់ខ្លួនរងគ្រោះដោយអំពើជួញដូរ និងការកេងប្រវ័ញ្ចន៍គ្រប់រូបភាព ដូចជាការបម្រើការងារខុសគោលដៅស្ម័គ្រចិត្តនៅក្រៅប្រទេស នៅតាមកសិដ្ឋាន, តាមរោងចក្រសហគ្រាស, តាមការដ្ឋានសំណង់ ក្នុងឧស្សាហកម្មនេសាទសមុទ្រដែលប្រកបដោយគ្រោះថ្នាក់ ឬការសុំទានជាដើម ។ ស្ត្រី និងកុមារមួយចំនួន ដែលបំរើតាមសេវាកំសាន្តនានា ត្រូវបានបណ្តាញឈ្មួញទុច្ចរិតបោកបញ្ឆោត, ទិញទឹកចិត្ត ឬត្រូវអាណាព្យាបាលរបស់ខ្លួន លក់ដូរឱ្យបម្រើសេវាកម្មផ្លូវភេទថែមទៀត ។

ដើម្បីជំនះឧបសគ្គចម្បងៗទាំងឡាយរួមទាំងបណ្តាញជួញដូរមនុស្សទាំងក្នុង និងក្រៅប្រទេសដែលមានលក្ខណៈជាប្រព័ន្ធដ៏ស្មុគ្រស្មាញនិងប្រកបដោយល្បិចកលទាមទារឱ្យមានការយកចិត្តទុកដាក់កាន់តែខ្លាំងថែមទៀតពីរដ្ឋាភិបាលនៃប្រទេស

ពាក់ព័ន្ធ ពីអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់នៅក្នុងប្រទេស ពីគ្រប់កម្លាំងសមត្ថកិច្ចជំនាញ និងពីអង្គការសង្គមស៊ីវិល ដែលកំពុងធ្វើការងារពាក់ព័ន្ធទាំងអស់នៅឯសហគមន៍ ។ ឆ្នាំ២០១០កន្លងទៅនេះ គឺជាការរៀបចំឡើងវិញនូវប្រព័ន្ធការងារដែលមានលក្ខណៈទូលំទូលាយជាពហុវិស័យ គឺ **គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការជួញដូរផ្លូវភេទលើស្ត្រី និងកុមារ (ប.ជ.រ.ព.ភ)** ព្រមពេលជាមួយគ្នានឹងកំណែទម្រង់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តនីគោលនយោបាយ និងកម្មវិធីជាតិអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដែលកំពុងតែត្រូវការឱ្យមានការរៀបចំកម្លាំងធនធានមនុស្ស ដោយមានការផ្ទេរ ឬផ្លាស់ប្តូរមុខងារក្នុងការផ្តល់សេវាសាធារណៈនៅថ្នាក់ក្រោមជាតិ ។ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់រាជរដ្ឋាភិបាល និងគណៈកម្មាធិការជាតិ (ប.ជ.រ.ព.ភ) យើងបានធ្វើឱ្យសម្រេចនូវកិច្ចការជាច្រើន ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារនៅកម្ពុជា ។

## II~ <u>លទ្ធផលការងារ ប.ជ.រ.ព.ភ</u> :

នៅក្នុងឆ្នាំ២០១០កន្លងទៅនេះ សកម្មភាពការងារ ប.ជ.រ.ព.ភ ត្រូវបានអនុវត្តយ៉ាងសកម្មដោយមានការចូលរួម និងសហការពីបណ្តាក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានាជាច្រើន ទាំងក្នុងរាជរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពីបណ្តាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ព្រមទាំងទីភ្នាក់ងារអង្គការសហប្រជាជាតិដែលមានទិសដៅប្រឆាំងការជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ទើបយើងសម្រេចបានលទ្ធផលដូចខាងក្រោម :

### ក- <u>ការរៀបចំច្បាប់-បទដ្ឋាន និងគោលនយោបាយ</u> :

- គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ចេញសេចក្តីសម្រេចលេខ០០៤/១០ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការតែងតាំងឈ្មោះសមាសភាព នៃគណៈកម្មាធិការជាតិ ប.ជ.រ.ព.ភ ។

- គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ចេញសេចក្តីសម្រេចលេខ៩២ ចុះថ្ងៃទី០៨/១២/០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ។

- ប្រធានគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ចេញលិខិតលេខ០០២ស.ស.រ ចុះថ្ងៃទី០៣/៧/១០ ស្តីពីការរៀបចំប្រព្រឹត្តទៅគណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ រាជធានី-ខេត្ត ។

- ក្រសួងយុត្តិធម៌បាន :

  - ចេញលិខិតលេខ ១១៩១ កយរប.១០ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១០ ណែនាំឱ្យសាលាដំបូង និងអយ្យការរាជធានី-ខេត្ត ស្រង់ទិន្នន័យរឿងក្តីរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារដាក់បញ្ចូលក្នុងទម្រង់ស្រង់ទិន្នន័យរឿងក្តីពាក់ព័ន្ធនឹងករណីជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ដើម្បីផ្ញើជូនទៅក្រសួងយុត្តិធម៌ ។
  - ចេញលិខិតលេខ ១៣០៣ កយរប១០ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០១០ ឱ្យសាលាដំបូង និងអយ្យការរាជធានី-ខេត្ត ប្រើលេខកូដដាក់លើសំណុំរឿងពាក់ព័ន្ធនឹងករណីជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ដើម្បីឱ្យស៊ីសង្វាក់គ្នាជាមួយសំណុំរឿង ដែលបញ្ជូនមកពីនគរបាលយុត្តិធម៌ ។
  - ចេញសេចក្តីសម្រេចលេខ ១២កយសសរ១០ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ២០១០ បង្កើតក្រុមការងារគ្រប់គ្រង និងវិភាគសំណុំរឿងក្តីជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។
  - ចេញលិខិតលេខ ១៦៣០ កយរក១០ ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១០ ឱ្យសាលាដំបូងនិងអយ្យការរាជធានី-ខេត្តចូលរួមសហការជាមួយក្រុមការងារគ្រប់គ្រង និងវិភាគសំណុំរឿងក្តីជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

- លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ បានចេញលិខិតលេខ០០១ ចុះថ្ងៃទី២៨/១២/០៩ តែងតាំងតំណាងមកពីក្រុមការងារទាំង៦ នៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ចំនួន៧រូប ជាសមាជិកក្រុមត្រួតពិនិត្យខ្លឹមសារ ការផលិតសម្ភារៈឯកសារដែលពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ។

- លេខាធិការដ្ឋានជាតិ ប.ជ.រ.ព.ភ សហការជាមួយក្រុមការងារ COMMIT រៀបចំផែនការសកម្មភាពជាតិប្រឆាំងនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (២០១១-២០១៣) ដើម្បីដាក់ជូនគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ពិនិត្យ និងសុំការអនុម័ត ។

- លេខាធិការដ្ឋានជាតិ ប.ជ.រ.ព.ភ តែងតាំងក្រុមបច្ចេកទេសចំនួន០២ គឺក្រុមត្រួតពិនិត្យតាមដាន និងក្រុមពិនិត្យខ្លឹមសាររូបភាព និងបង្កើតសំភារៈឯកសារសំរាប់ផ្សព្វផ្សាយ និងបណ្តុះបណ្តាល (IEC materials) ។

- ក្រសួងអប់រំ យុវជន និងកីឡា ធ្វើផែនការការងារអប់រំផ្សព្វផ្សាយអំពីការទប់ស្កាត់ ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនានាលើបដា និងផ្ទាំងរូបភាពសម្រាប់បិទផ្សព្វផ្សាយនៅគ្រប់សាលារៀន ពិសេសនៅក្នុងសាលារៀនគោលដៅ ។

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីជូនដំណឹង និងសេចក្តីអំពាវនាវលេខ០២២ និង ០២៣ ស.ជ.ណ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ជុំវិញការជ្រើសរើសពលករ-ពលការិនីកម្ពុជាសម្រាប់កូតាឆ្នាំ២០១០ ដើម្បីទៅធ្វើការងារនៅប្រទេសកូរ៉េ ។

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចេញសេចក្តីជំរាបជូនលេខ២៦៤៧ប.ក/អ.ក ស្តីពីការណែនាំតម្រង់ទិសដៅការងារជ្រើសរើសពលករខ្មែរទៅធ្វើការនៅបរទេស ចំនួន១០ចំណុចដល់ក្រុមហ៊ុននិយោជក ។

- គណៈកម្មាធិការត្រួតពិនិត្យការអនុវត្តន៍លិខិតបទដ្ឋានគតិយុត្តិរបស់រាជរដ្ឋាភិបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី បាន រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ និងបានដាក់ឱ្យអនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** លើការងារប្រឆាំងការជួញដូរផ្លូវភេទ បនពេស្យាចារ ក្លឹបកម្សាន្តល្មើសច្បាប់ ទូរហ្គេម និងអំពើអាសអាភាស ។

- ក្រសួងកិច្ចការនារី ទទួលសិទ្ធិប្បទានចុះហត្ថលេខាលើអនុស្សរណៈ នៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលប្រទេសម៉ាឡេស៊ី ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស តែសេចក្តីព្រាងឯកសារអនុស្សរណៈនៅមិនទាន់សម្រេចនៅឡើយ ។

- ក្រសួងទេសចរណ៍ រៀបចំផែនការសកម្មភាព ស្តីពីការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ នៅតាមបណ្តារាជធានី-ខេត្ត ។

- សាលារាជធានីភ្នំពេញ បានចេញរបាយការណ៍ស្តីពីការលុបបំបាត់ការទប់ស្កាត់អំពើអាសអាភាស អានាចារ ជួញដូរផ្លូវភេទ និងក្លឹបកម្សាន្តល្មើសច្បាប់ តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ។

- អគ្គស្នងការដ្ឋាននគរបាលជាតិ ចេញសេចក្តីណែនាំលេខ០០៥ស.ណ.ន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ ស្តីពីការបង្ការបង្ក្រាបការប្រើប្រាស់គ្រឿងញៀនតាមកន្លែងកម្សាន្ត ការជួញដូរមនុស្ស និងការលេងភ្នាល់ល្បែងគ្មានការអនុញ្ញាត និងសេចក្តីណែនាំលេខ០០៩ស.ណ.ន ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១០ ស្តីពីកិច្ចការអនុវត្តន៍ប្រតិបត្តិការសង្គ្រោះជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ។

## ៩- <u>ការងារដឹកនាំ សម្របសម្រួល</u> :

ក្នុងឆ្នាំកន្លងទៅ លេខាធិការដ្ឋានសម្រេចបាននូវភារកិច្ចជាច្រើន ដោយផ្អែកតាមគោលនយោបាយជាតិ និង ផែនការសកម្មភាពរបស់គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ធ្វើការងារដឹកនាំ និងជម្រុញរាល់សកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់ក្រុមការងារទាំង៦ នៃលេខាធិការដ្ឋានជាតិ និងគណៈកម្មាធិការ ប.ជ.រ.ព.ភ រាជធានី-ខេត្ត តាមតួនាទីភារកិច្ចដែលបានកំណត់ក្នុងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ។ ទន្ទឹមនឹងនោះ លេខាធិការដ្ឋានបានផ្តោតយកចិត្តទុកដាក់លើការងារដឹកនាំ និងសម្របសម្រួលកិច្ចសហការរវាងស្ថាប័នជំនាញ ទាំងក្នុងរាជរដ្ឋាភិបាល ទាំងអង្គការមិនមែនរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការងារត្រួតពិនិត្យ, ជម្រុញការធ្វើសកម្មភាព, ជម្រុញឱ្យមានកិច្ចសហប្រតិបត្តិការផ្ទៃក្នុងជាតិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសពាក់ព័ន្ធ

ជាទ្វេភាគី និងពហុភាគី លើការងារបង្កើនសមត្ថភាពមន្ត្រីអនុវត្តច្បាប់, ការងារបង្ការ, ការងារទប់ស្កាត់, ការងារបង្ក្រាប និងការងារផ្តន្ទាទោស ដោយទទួលបានលទ្ធផលដូចខាងក្រោម :

- លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំប.ជ.រ.ព.ភបានជួបប្រជុំជាមួយក្រុមការងារទាំង៦ចំនួន**០៨**លើក ដើម្បីរកយុទ្ធសាស្ត្រគ្រប់គ្រងទិន្នន័យថ្នាក់ជាតិការសម្របសម្រួលបង្កើតក្រុមបច្ចេកទេសត្រួតពិនិត្យខ្លឹមសាររូបភាព និងបង្កើតសំភារៈឯកសារ ផ្លាស់ប្តូរព័ត៌មាន និងបទពិសោធន៍ការងារក្នុងក្រុមការងារនីមួយៗ និងរវាងក្រុមទាំងប្រាំមួយពិភាក្សាលើការតាមដានសកម្មភាពមិនប្រក្រតីរបស់ភ្នាក់ងារក្រុមហ៊ុនជ្រើសរើសពលករឱ្យទៅបម្រើការងារនៅក្រៅប្រទេសមួយចំនួន និងរកដំណោះស្រាយ ជម្រុញឱ្យមានភាពជឿនលឿនលើការអនុវត្តន៍សកម្មភាពការងារដែលពាក់ព័ន្ធនឹង ប.ជ.រ.ព.ភ ។

- បើកកិច្ចប្រជុំមួយនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ នៅសណ្ឋាគារ **ហ៊ីម៉ាវ៉ារី** ដល់មន្ត្រីជំនាញក្នុងក្រសួង មន្ទីរពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ដើម្បីផ្សព្វផ្សាយសេចក្តីណែនាំរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ លើការអនុវត្តន៍កិច្ចប្រតិបត្តិការសង្គ្រោះជនរងគ្រោះដោយសារការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ។

- លោកជំទាវប្រធានលេខាធិការដ្ឋានបានទទួលការអនុញ្ញាតពី**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ឱ្យចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) និងក្រសួងមហាផ្ទៃ និងរវាងអង្គការសកម្មភាពដើម្បីកុមារ (APLE) និងក្រសួងមហាផ្ទៃ ស្តីពីការចូលរួមសកម្មភាពមនុស្សធម៌នៅព្រះរាជាណាចក្រកម្ពុជាលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

- បានពិភាក្សារួមគ្នារវាងក្រុមការងារអនុវត្តច្បាប់ និងក្រុមការងារកិច្ចការយុត្តិធម៌ ដើម្បីរៀបចំគំរូរបាយការណ៍ និងការប្រើប្រាស់លេខកូដរួមគ្នាងាយស្រួលក្នុងការតាមដានករណីរឿងក្តីជួញដូរមនុស្ស ។

- ជួបប្រជុំដោយឡែកៗពីគ្នាជាមួយលេខាធិការដ្ឋានថ្នាក់ជាតិ លេខាធិការដ្ឋានថ្នាក់រាជធានី-ខេត្ត បណ្តាអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដើម្បីពិនិត្យសេចក្តីព្រាងរបាយការណ៍ និងដើម្បីប្រមូលលទ្ធផលស្នាដៃនៃកិច្ចខិតខំប្រឹងប្រែងទាំងឡាយដាក់បញ្ចូលក្នុងរបាយការណ៍ជាតិ ស្តីពី ប.ជ.រ.ព.ភ ឆ្នាំ២០១០។

- ប្រធានលេខាធិការដ្ឋាន ជួបជាមួយអង្គការពលកម្មអន្តរជាតិ (ILO) ដើម្បីពិភាក្សាពីការរៀបគម្រោងកាត់បន្ថយការកេងប្រវ័ញ្ចន៍កម្លាំងពលកម្មកុមារ និងជាមួយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) ដើម្បីរៀបចំសិក្ខាសាលាពិគ្រោះយោបល់ក្នុងការរកយុទ្ធសាស្ត្រគ្រប់គ្រងពលករនេសាទទេសន្តរប្រវេសន៍ ឱ្យមានសុវត្ថិភាពក្នុងមហាអនុតំបន់មេគង្គ និងប្រទេសម៉ាឡេស៊ី ។

- លោកជំទាវប្រធានលេខាធិការដ្ឋាន និងលោកជំទាវ ប្រធានក្រុមការងារ COMMIT កម្ពុជា ចូលរួមផ្តល់មតិក្នុងការត្រៀមរៀបចំកិច្ចប្រជុំសមាគមន៍សភាអាស៊ី AIPA និង WAIPA ២០១១ ដែលរាជរដ្ឋាភិបាលកម្ពុជាធ្វើជាម្ចាស់ផ្ទះ និងបានលើកយកប្រធានបទ “**តួនាទីសភាក្នុងការគ្រប់គ្រងទេសន្តរប្រវេសន៍**”មកពិភាក្សា និងត្រៀមចូលរួមជាវាគ្មិនក្នុងវេទិកានេះ ។

### គ-<u>ការអនុវត្តន៍យុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស</u> :

### ១- <u>ការងារបង្ការ-ទប់ស្កាត់</u> :

- លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ បានបើកការប្រជុំពិភាក្សាលើបញ្ហាពាក់ព័ន្ធនឹងបែបបទនីតិវិធី នៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសជាបន្តបន្ទាប់ ដើម្បីទប់ស្កាត់អាពាហ៍ពិពាហ៍ដែលក្លែងបន្លំ និងការជួញដូរ ឬរត់ពន្ធមនុស្ស តាមរូបភាពអាពាហ៍ពិពាហ៍។

- ក្រុមការងារបង្ការ-ទប់ស្កាត់ នៃលេខាធិការដ្ឋានថ្នាក់ជាតិបានជួបប្រជុំគ្នាក្នុងការបង្ហាញឯកសារស្រាវជ្រាវ និងប្រមូលអនុសាសន៍ដើម្បីរៀបចំចងក្រងឯកសារសម្រាប់បណ្តុះបណ្តាលអំពីសកម្មភាពថ្នាក់ភូមិ ក្នុងការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ។

- ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការផ្សព្វផ្សាយអំពីយុទ្ធសាស្ត្រការទប់ស្កាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចន៍នានាដោយមានដាក់ជាបដា និងផ្ទាំងរូបភាពបិទនៅតាមអគារសិក្សានៃសាលាបង្គោល និងសាលាឧបសម្ព័ន្ធ ហើយបានបញ្ចូលខ្លឹមសារប្រឆាំងការជួញដូរមនុស្ស នៅក្នុងវិញ្ញាសារប្រឡងប្រចាំខែ ឆមាស ពិសេសបានណែនាំ

ដល់គ្រប់ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង-ស្រុក-ខណ្ឌ ឱ្យធ្វើការប្រជុំនាយក នាយិកា សាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ដើម្បីបន្តផ្សព្វផ្សាយ និងបញ្ជ្រាបយុទ្ធសាស្ត្រខាងលើក្នុងការបង្រៀន និងរៀននូវគ្រប់មុខវិជ្ជាដល់លោកគ្រូ-អ្នកគ្រូ ។

- ក្រសួងទេសចរណ៍ សហការជាមួយអង្គការ World Vision, អ៊ិកផាត (ECPAT) កម្ពុជា, មិត្តសំឡាញ់ និងអង្គការ Child Wise Australia ធ្វើការផ្សព្វផ្សាយខ្លឹមសារ "ចូលរួមជាមួយយើងខ្ញុំ ដើម្បីការពារកុមារ, សូមស្វាគមន៍អ្នកទេសចរដែលមានការទទួលខុសត្រូវ" (Join us to Protect our children, Welcome Responsible Tourists) ផ្សព្វផ្សាយអំពីច្បាប់ទេសចរណ៍នៅតាមបណ្ដាមន្ទីរទេសចរណ៍រាជធានី-ខេត្ត និងធ្វើការផ្សព្វផ្សាយផ្ទាំងរូបភាព ដែលមានសារអប់រំ តាមរ៉ឺម៉កកង់បីនៅក្នុងរាជធានីភ្នំពេញ និងខេត្តព្រះសីហនុបានចំនួន **៣៤២**រ៉ឺម៉ក ។

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានសហការជាមួយអង្គការ IOM និងមូលនិធិអាស៊ី ធ្វើការផ្សព្វផ្សាយកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីនីតិវិធីប្រតិបត្តិបទដ្ឋានក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស ព្រមទាំងបានផ្សព្វផ្សាយលើគោលនយោបាយ ស្តីពីសិទ្ធិការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងបទដ្ឋានអប្បបរមាសម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដល់មន្ត្រីសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ។

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានជួបប្រជុំពិភាក្សា និងធ្វើការងារជាមួយបណ្ដាក្រសួង និងអង្គការដៃគូដូចខាងក្រោម :

- ជួបប្រជុំជាមួយសម្ព័ន្ធអង្គការកូសេកម្ម (COSECAM) និងអង្គការទស្សនៈពិភពលោក (WORLD VISION) ចំនួន**៣**លើកក្នុងគោលបំណងរៀបចំទិន្នន័យ នៃការជួញដូរមនុស្សជាលក្ខណៈស្តង់ដា បង្កើតទម្រង់ត្រួតពិនិត្យមណ្ឌលផ្តល់សេវាដល់ជនរងគ្រោះ ពិនិត្យគម្រោងស្តារលទ្ធភាពកុមាររងគ្រោះដែលបានស្តារ និងការអនុវត្តន៍ការងារកន្លងមក វាយតម្លៃលើកម្មវិធីកាត់បន្ថយផលប៉ះពាល់ដល់កុមារកំព្រា កុមារងាយរងគ្រោះ និងកុមាររងគ្រោះដោយសារការជួញដូរ ។
- ជួបជាមួយអង្គការ The Asia Foundation ដើម្បីពិភាក្សាលើវេទិកាកុមារ-យុវជនមេគង្គថ្នាក់ជាតិ និងការពិនិត្យវាយតម្លៃអំពីលទ្ធផលនៃការធ្វើសិក្ខាសាលាផ្សព្វផ្សាយសៀវភៅគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស។
- ជួបជាមួយអង្គការ IOM ដើម្បីពិនិត្យលើចំណុចខ្លាំង ចំណុចខ្វះខាតក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងសហប្រតិបត្តិការ រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ស្តីពីនីតិវិធីប្រតិបត្តិបទដ្ឋានក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ក្នុងឆ្នាំបន្ទាប់ ។

- ក្រសួងកិច្ចការនារី សហការជាមួយអង្គការ IOM មន្ទីរកិច្ចការនារីខេត្តបន្ទាយមានជ័យ ធ្វើការផ្សព្វផ្សាយអំពីការលើកកម្ពស់សុវត្ថិភាពក្នុងការធ្វើចំណាកស្រុក ដល់ប្រជាពលរដ្ឋចំនួន**៩៦៤**នាក់ ក្នុងស្រុកម៉ាល័យ ខេត្តបន្ទាយមានជ័យ ក្រោមការជួយឧបត្ថម្ភពីគំរោងអាទិភាព (PB) និងបានចុះស្រាវជ្រាវសម្ភាសន៍ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធចំនួន**២៥០**នាក់ ដើម្បីប្រមូលព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកក្នុងខេត្តតាកែវ, ប៉ៃលិន, ក្រចេះ, ស្ទឹងត្រែង, និងខេត្តព្រះសីហនុ ដើម្បីជាមូលដ្ឋានក្នុងការកែសម្រួលឯកសារបណ្តុះបណ្តាល និងផ្សព្វផ្សាយនៅក្នុងខេត្តគោលដៅទាំង៥ ។ ព្រមជាមួយនោះតំណាងក្រសួងបានចូលរួមធ្វើជាវាគ្មិនលើវេទិកាការៀបចំឡើងដោយអង្គការ CARAM នៅខេត្តស្ទឹងត្រែង ស្តីពីចំណាកស្រុករកការងារធ្វើ និងបានចូលរួមជាវាគ្មិនក្នុងកម្មវិធីសំណេះសំណាលតាមវិទ្យុ**FM102Mz** ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា ក្រោមប្រធានបទ **"ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍" "ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងភាពប្រឈមរបស់ស្ត្រីរងគ្រោះដោយសារការជួញដូរ"** ។

- ក្រសួងកិច្ចការនារី បានជួបប្រជុំជាមួយគណៈប្រតិភូគណៈកម្មាធិការ COMMIT ថ្នាក់តំបន់ប្រចាំនៅកម្ពុជា ដើម្បីស្វែងយល់ពីការងារ និងបទពិសោធន៍នៃការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សកន្លងមក ពិសេសលើកិច្ចសហប្រតិបត្តិការ រវាងអង្គការ UNIAP និងដៃគូផ្សេងទៀត ។

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ "**នាយកដ្ឋានការងារកុមារ**" ចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុ **FM103** ចំនួន០៥លើក ដើម្បីផ្សព្វផ្សាយជាសាធារណៈ បញ្ហាពលកម្មកុមារ និងចូលរួមវេទិកាតុមូល ស្តីពីដំណើរការឆ្ពោះទៅលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ក្នុងកម្មវិធីទូរទស្សន៍ជាតិកម្ពុជា ។

- នាយកដ្ឋានជំនាញ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានជួបប្រជុំចំនួន**២៧**លើកជាមួយនឹង : ក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ លេខាធិការដ្ឋានថ្នាក់ជាតិ ក្រុមប្រឹក្សាជាតិដើម្បីកុមារ ក្រុមការងារយេនឌ័រ កាកបាទក្រហមកម្ពុជា អគ្គលេខាធិការជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ស្ថានទូតអាមេរិក និងបណ្តាអង្គការដៃគូមួយចំនួនទៀត ដោយផ្តោតលើបញ្ហាមួយចំនួនដូចជា : កិច្ចសហការ និងបង្ក្រាបបទល្មើសពាក់ព័ន្ធនឹងសកម្មភាព ប.ជ.រ.ព.ភ ការពិនិត្យផែនការសកម្មភាពជាតិក្នុងឆ្នាំ២០១០ បែបបទនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ការវាយតម្លៃបញ្ចប់កម្មវិធីព្រំដែនលើកកម្ពស់សុខភាព និងសុវត្ថិភាពទេសន្តរប្រវេសន៍កម្ពុជាទៅរកការងារធ្វើនៅប្រទេសថៃ ការកំណត់អនុសាសន៍ សម្របសម្រួលសម្រាប់រាជរដ្ឋាភិបាល ស្ថាប័ន អង្គការពាក់ព័ន្ធ ក្នុងការកាត់បន្ថយពលករកម្ពុជារងគ្រោះដោយសារការជួញដូរ និងកេងប្រវ័ញ្ចន៍ពលកម្ម ការចុះប៉ាន់ប្រមាណនៅក្នុងកម្មវិធីស្តារទំនាក់ទំនងគ្រួសារពាក់ព័ន្ធនឹងការធ្វើចំណាកស្រុក ការពិនិត្យលើប្រតិបត្តិការនៃការស្វែងរកចាប់ខ្លួនជនល្មើស ក្រោមរូបភាពអាពាហ៍ពិពាហ៍ និងពិភាក្សាការបង្កើតផ្ទាំងរូបភាព ខិតប័ណ្ណរួមគ្នាដើម្បីធ្វើការផ្សព្វផ្សាយនៅតាមបណ្តាគោលដៅ ។

-ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានល្បាតឃ្លាំមើលគោលដៅអាជីវកម្មសំខាន់ៗចំនួន**១,៥១០**គោលដៅ និងបានចូលរួមផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដល់អាជ្ញាធរមូលដ្ឋាន លោកគ្រូ-អ្នកគ្រូ និស្សិត សិស្សានុសិស្ស និងភ្នាក់ងារជ្រើសរើសពលករទៅបម្រើការងារនៅក្រៅប្រទេស បានចំនួន**២១,៣១៨**នាក់( ស្រី**៨,៦៣៦**នាក់) និងបានយកសេចក្តីណែនាំលេខ០០៥សណន ចុះថ្ងៃទី១១/៣/១០ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ បិទតាមបណ្តាគោលដៅអាជីវកម្ម ដែលអាចពាក់ព័ន្ធនឹងការធ្វើអាជីវកម្មផ្លូវភេទបានចំនួន**៨១៧**គោលដៅ និងសម្រង់ស្ថិតិធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម ព្រមទាំងផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនានាដល់ម្ចាស់អាជីវកម្ម ស្ត្រីបម្រើក្នុងហាងម៉ាស្សា ខារ៉ាអូខេបានចំនួន**១,១៧៨**គោលដៅ មនុស្សចំនួន**២,៤៨៦**នាក់ (ស្រី**១,៥៦៦**នាក់) និងបានសហការជាមួយគណៈបញ្ជាការឯកភាពរាជធានី-ខេត្ត ចុះត្រួតពិនិត្យរដ្ឋបាល និងបិទគោលដៅដែលពាក់ព័ន្ធនឹងអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន**២៣៤**គោលដៅ ។ និងបានធ្វើសម្រង់ស្ថិតិពលករចំណាកស្រុកដើម្បីទៅរកការងារធ្វើនៅក្រៅប្រទេសបានចំនួន**៩៥,១០៦**នាក់ (ស្រី**៣៧,០៩៨**នាក់) និងក្តាប់បានមេខ្យល់អូសទាញចំនួន**១៣១**នាក់ ។ ដោយឡែកស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ និងកំពង់ធំ បានធ្វើការល្បាតទប់ស្កាត់ពលករខ្មែរធ្វើចំណាកស្រុកទៅរកការងារធ្វើនៅប្រទេសថៃដោយខុសច្បាប់បានចំនួន**៦២៩**នាក់ (ស្រី**១៥៤**នាក់) និងបានធ្វើការណែនាំឱ្យត្រឡប់ទៅលំនៅដ្ឋានវិញ ។

## ២- ការងារការពារ ស្តារនីតិសម្បទា សមាហរណកម្ម និងធាតុភូមិនិវត្តន៍ :

## ២.១ ការប្រមូល_ទទួលជនរងគ្រោះ និងស្តារនីតិសម្បទា :

-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានទទួលជនរងគ្រោះ និងងាយរងគ្រោះពីប្រទេសថៃ, វៀតណាម, ឥណ្ឌា, ឥណ្ឌូនេស៊ី, និងអាហ្វ្រិកខាងត្បូងបានចំនួន៤៥៩នាក់ (កុមារ**៣១៧**នាក់) ក្នុងនោះយើងបានទទួលពីអាជ្ញាធរប្រទេសសាមី តាមរយៈការសម្របសម្រួលពីស្ថានទូតកម្ពុជាប្រចាំនៅប្រទេសទាំងនោះ និងមួយចំនួនមានការឧបត្ថម្ភ និងសហការពីអង្គការ IOM, UNIAP និងអង្គការក្នុងស្រុកមួយចំនួនទៀត ។ ជនរងគ្រោះបានប្រគល់ឱ្យអង្គការដៃគូមាន :អង្គការ WNU/CPN**២៣៨**នាក់, Friends**១១**នាក់, WHI**៦**នាក់, AFESIP**៤២**នាក់, HCC**៣៧**នាក់, CCPCR**២១**នាក់, OUR HOME**១**នាក់, Hagar**២**នាក់, និងមណ្ឌលសង្គមកិច្ចរាជធានីភ្នំពេញ**២០**នាក់ ។ ចំនួននៅសល់ក្រោយពីបញ្ជូនឱ្យអង្គការ និងមណ្ឌលខាងលើ ត្រូវបានផ្តល់សេវាសុខភាព, ជម្រក, អប់រំ, ផ្គត់ផ្គង់ជីវភាព, បណ្តុះបណ្តាលវិជ្ជាជីវៈ អប់រំស្តារនីតិសម្បទា និងការបញ្ជូនទៅសហគមន៍ និងគ្រួសារវិញ។

-ក្រុមចំរុះនៃគណៈបញ្ជាការឯកភាពរាជធានីភ្នំពេញ ចុះត្រួតពិនិត្យរដ្ឋបាលតាមផ្លូវសាធារណៈ ប្រមូលនារីរកស៊ីផ្លូវភេទដែលធ្វើការទាក់ទាញភ្ញៀវតាមផ្លូវសាធារណៈបានចំនួន**៣១០**នាក់ ប្រគល់ឱ្យមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញអប់រំបន្ត និងបានត្រួតពិនិត្យក្រុមហ៊ុនជ្រើសរើសពលករទៅបម្រើការងារក្រៅប្រទេស ដោយបានដកហូតអនីតិជនចំនួន**៥៥**នាក់ អនីតិជនទាំងនេះបានធ្វើការប្រគល់ឱ្យអង្គការ CWCC ចំនួន**៧**នាក់ ប្រគល់ឱ្យមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញចំនួន**២២**នាក់ ប្រគល់ឱ្យក្រុមគ្រួសារវិញចំនួន**២៦**នាក់ ។

### ២.២. ការងារសមាហរណកម្មជនរងគ្រោះ :

-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបន្តការតាមដានជនរងគ្រោះ និងងាយរងគ្រោះដែលបានធ្វើសមាហរណកម្មទៅគ្រួសារ និងសហគមន៍ក្នុង២១រាជធានី-ខេត្ត ចំនួន**១,៦១១**នាក់( ស្រី**៩៩៦**នាក់) ក្នុងនោះមានអតិថិជនស្វែងរកគ្រួសារ**២៣៧**នាក់, អតិថិជនប៉ាន់ប្រមាណគ្រួសារ**១៦៥**នាក់, និងសម្រេចបិទករណីចំនួន**៦១៤**នាក់ ។ ជនរងគ្រោះ និងងាយរងគ្រោះខាងលើត្រូវផ្ដល់សេវាអប់រំក្នុងមណ្ឌល គ្រឿងឧបភោគបរិភោគ សម្ភារៈ ថវិកា បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងធ្វើការសម្របសម្រួលមុខរបរផងដែរ ហើយនិយាយជារួមការផ្ដល់សេវាបានចំនួន**៦,៣៣៧**ដងលើ**១,៦១១**នាក់ និងមានស្ថិតិត្រូវតាមដានបន្តនៅចំនួន**៩៩៥**នាក់ទៀត ។

### ២.៣. ការទទួលពលករពីអាជ្ញាធរបរទេស :

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទទួលទេសន្តរប្រវេសន៍ពីអាជ្ញាធរប្រទេសថៃ វៀតណាម និងប្រទេសម៉ាឡេស៊ី បញ្ជូនមកវិញមានចំនួន**១៩៦**នាក់ កុមារ**១២៧**នាក់ ជនទាំងនេះត្រូវបានបញ្ជូនទៅអង្គការដៃគូ និងបានផ្ដល់ជម្រក, សេវាសុខភាព, អប់រំ, ផ្ដត់ផ្គង់ជីវភាព, បណ្ដុះបណ្ដាលវិជ្ជាជីវៈ, សម្របសម្រួលមុខរបរ និងធ្វើសមាហរណកម្មទៅរស់នៅតាមសហគមន៍ គ្រួសារវិញ ។

- ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ខេត្តស្វាយរៀង និងខេត្តកោះកុង បានទទួលជនទេសន្តរប្រវេសន៍កម្ពុជាដែលត្រូវបានបញ្ជូនត្រឡប់មកវិញដោយអាជ្ញាធរថៃ និងវៀតណាម មានចំនួនសរុប **១២៧,០៥៣**នាក់ ( ស្រី**៣៨,៥៧២**នាក់) (បើប្រៀបធៀបឆ្នាំ២០០៩ កើនឡើងចំនួន **២៤.៧៣៦**នាក់ ស្មើនឹង**២១.៤៧**%) និងមានកុមារអាយុក្រោម១៥ឆ្នាំ **១១,៨៧១**នាក់ :

- តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ចំនួន**១១៤,១៩៨**នាក់ ( ស្រី**៣៨,០៧៣**) -កុមារ**១១,៨៥៦**នាក់
- តាមច្រកទ្វារបាវិត-ច្រកបុសមន ចំនួន**៥៧១**នាក់ ( ស្រី**៣០០**នាក់) -កុមារ**១៥**នាក់
- តាមច្រកទ្វារចាំយាម ចំនួន**៤១៣**នាក់ ( ស្រី**១៩៩**នាក់)

តារាងជនទេសន្តរប្រវេសន៍ ដែលទទួលពីអាជ្ញាធរថៃ និងវៀតណាម :

| ច្រកទ្វារទទួលជនទេសន្តរប្រវេសន៍ | ចំនួនសរុប | ស្រី : ១៥ឆ្នាំឡើង | ប្រុស : ១៥ឆ្នាំឡើង | កុមារក្រោម១៥ឆ្នាំ |
|---|---|---|---|---|
| ប៉ោយប៉ែត -បន្ទាយមានជ័យ | ១២៦.០៥៤ | ៣៨.០៧៣ | ៧៦.១២៥ | ១១.៨៥៦ |
| បាវិត-បុសមន-ស្វាយរៀង | ៥៨៦ | ៣០០ | ២៧១ | ១៥ |
| ចាំយាម-កោះកុង | ៤១៣ | ១៩៩ | ២១៤ | |
| សរុប | ១២៧.០៥៣ | ៣៨.៥៧២ | ៧៦.៦១០ | ១១.៨៧១ |

ក្នុងនោះ ជនដែលត្រូវអាជ្ញាធរថៃឃាត់ខ្លួនលើសពីរយៈពេល១ខែមុនពេលបញ្ជូនមកកម្ពុជាវិញ មានចំនួន **១៤.៥៥២**នាក់ ។ សមត្ថកិច្ចយើងបានសម្ភាសន៍ពលករមួយចំនួនក្លាប់បានមុខសញ្ញាមេខ្យល់ចំនួន**៥០**នាក់ និងបានធ្វើការអប់រំណែនាំឱ្យជនទេសន្តរប្រវេសន៍ទាំងនោះវិលត្រឡប់ទៅលំនៅដ្ឋានវិញ លើកលែងតែមុខសញ្ញាកុមាររងគ្រោះ ដែលសង្ស័យថាត្រូវបាននាំចេញដោយខុសច្បាប់ មន្ទីរសង្គមកិច្ចបានទទួលឱ្យស្នាក់នៅក្នុងមណ្ឌលសង្គមកិច្ចរបស់អង្គការដៃគូដែលផ្ដល់ការថែទាំ ដើម្បីស្វែងរកអាណាព្យាបាល និងលំនៅដ្ឋានពិតប្រាកដ ។ រីឯអ្នកដែលសង្ស័យថានាំកុមារចេញដោយខុសច្បាប់ ត្រូវបានកំណត់ដើម្បីធ្វើការស្រាវជ្រាវ និងស៊ើបអង្កេត ។

## ៣- ការងារអនុវត្តច្បាប់ :

### ៣.១. កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើស :

- ក្នុងឆ្នាំ ២០១០នេះ នាយកដ្ឋានជំនាញ កងរាជអាវុធហត្ថ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើការស្រាវជ្រាវ និងបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន**១៦០**ករណីលើ**១៦៥**ករណី ឃាត់ខ្លួនជនជាប់សង្ស័យចំនួន**២៤២**នាក់ (ស្រី**៧៩**នាក់) បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០០៩ ឃើញថាថយចុះចំនួន**០៥**ករណី ជនល្មើសកើនឡើង ចំនួន**១១**នាក់ ក្នុងនោះមានជនបរទេស**១៩**នាក់ (សញ្ជាតិអង់គ្លេស**៤**នាក់, អាមេរិក**៤**, ជប៉ុន**២**, អូស្ត្រាលី**២**, អាហ្វ្រិក**១**, ដាណឺម៉ាក**១**, ចិន**១**, ណ័រវេ**១**, ហូឡង់**១**, ឡាវ**១**, និងស្វីស**១**នាក់) សង្គ្រោះជនរងគ្រោះបានចំនួន**៦៨៦**នាក់ ។ ក្នុងចំនួនជនរងគ្រោះបែងចែកអាយុជាបីប្រភេទគឺ : អាយុក្រោម១៥ឆ្នាំ មានចំនួន**៨៨**នាក់, អាយុពី១៥ឆ្នាំដល់ក្រោម១៨ឆ្នាំ មានចំនួន**១០៩**នាក់, និងអាយុពី១៨ឆ្នាំឡើងមានចំនួន**៤៨៩**នាក់ ។ ជនរងគ្រោះត្រូវបានបញ្ជូនឱ្យមន្ទីរសង្គមកិច្ចមានចំនួន**៣០១**នាក់, អង្គការមិនមែនរដ្ឋាភិបាលចំនួន**២៤**នាក់, និងប្រគល់ឱ្យគ្រួសារវិញចំនួន**៣៦១**នាក់ ។

**<u>តារាងលទ្ធផលនៃប្រតិបត្តិការបង្ក្រាប ឆ្នាំ ២០១០ :</u>**

| បទល្មើស | ចំនួនករណី | ចំនួនជនសង្ស័យ | ចំនួនជនរងគ្រោះ | | | គោលដៅបញ្ជូនជនរងគ្រោះ | | |
|---|---|---|---|---|---|---|---|---|
| | | | ក្រោម១៥ឆ្នាំ | ១៥-១៧ឆ្នាំ | ១៨ឆ្នាំឡើង | មន្ទីរសង្គមកិច្ច | អង្គការNGO | គ្រួសារ |
| ជួញដូរមនុស្ស | ៦៥ ករណី | ១០២ នាក់ | ៨៨ នាក់ | ១០៩ នាក់ | ៤៨៩ នាក់ | ៣០១ នាក់ | ២៤ នាក់ | ៣៦១ នាក់ |
| អាជីវកម្មផ្លូវភេទ | ៩៥ ករណី | ១៤០ នាក់ | | | | | | |
| សរុប | ១៦០ ករណី | ២៤២ នាក់ | ៦៨៦ នាក់ | | | ៦៨៦ នាក់ | | |

**ក្នុងបទល្មើសទាំង១៦០ករណី និងជនជាប់សង្ស័យ២៤២នាក់ ដែលសមត្ថកិច្ចយើងបង្ក្រាបបានក្នុងឆ្នាំ២០១០ នេះមាន :**

- ***បទល្មើសជួញដូរមនុស្ស ចំនួន៦៥ករណី ជនជាប់សង្ស័យ១០២នាក់*** ។ (មាន ២២ ករណី ដែលសមត្ថកិច្ចយើងបានបង្ក្រាប និងសង្គ្រោះជនរងគ្រោះក្នុងពេលដែលជនសង្ស័យត្រៀមបញ្ជូនឆ្លងដែនដោយខុសច្បាប់ និងសង្គ្រោះជនរងគ្រោះចំនួន**៣០០**នាក់ ក្នុងនោះមានអនីតិជនចំនួន**៧៨**នាក់ )
- ***បទល្មើសអាជីវកម្មផ្លូវភេទ ចំនួន៩៥ករណី ជនជាប់សង្ស័យ១៤០នាក់ ។***

- ដោយឡែក ក្រុមការងារអនុវត្តច្បាប់ ដែលដឹកនាំដោយអគ្គស្នងការរងនគរបាលជាតិ សហការជាមួយកម្លាំងស្នងការរាជធានី-ខេត្ត ចុះពិនិត្យភាពមិនប្រក្រតីរបស់ក្រុមហ៊ុន ចំនួន**៦**ករណី ពាក់ព័ន្ធក្រុមហ៊ុនចំនួន**៦** ឃាត់ខ្លួនជនជាប់សង្ស័យចំនួន**៨**នាក់ និងសង្គ្រោះពលការិនីជាអនីតិជនចំនួន**៥៥**នាក់ឱ្យរួចផុតពីការប៉ុនប៉ងបញ្ជូនទៅបំរើការងារនៅក្រៅប្រទេស ។

- បានទទួលពាក្យបណ្តឹងពីសាមីខ្លួន និងពីអង្គការមិនមែនរដ្ឋាភិបាលដៃគូ អំពីករណីពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចន៍ពលកម្ម យើងបានធ្វើការស៊ើបអង្កេត និងចាត់វិធានការបង្ក្រាបជាច្រើនករណី ដើម្បីសង្គ្រោះជនរងគ្រោះ និងចាប់បញ្ជូនជនសង្ស័យទៅតុលាការដើម្បីផ្តន្ទាទោស ។

## ៤- <u>ការងារកិច្ចការយុត្តិធម៌</u> : (រយៈពេល ០១ឆ្នាំ គិតពីខែ មករា - ខែ ធ្នូ ឆ្នាំ ២០១០)

សាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើរឿងក្តីជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ បានចំនួន**១៦៣លើ៩៧ករណី** ជនល្មើស**២៤៩**លើ**១៤៦**នាក់ បើប្រៀបធៀបទៅនឹងឆ្នាំ២០០៩ មានការកើនឡើង**៦៦**ករណី (គិតជាភាគរយស្មើ**៦៨,០៤%**) ជនល្មើសកើនឡើងចំនួន **១០៣**នាក់ ។

ជាលទ្ធផលសរុបសាលាដំបូង និងអយ្យការរាជធានី-ខេត្ត បានទទួល និងចាត់ការរឿងក្តីពាក់ព័ន្ធនឹងករណីបទល្មើសនានាក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដូចមានខាងក្រោម :

៤.១ **ទទួលសំណុំរឿង :**

- ករណីសរុប : **១៥២**ករណី ជនល្មើស**២៩៦**នាក់ ក្នុងនោះ

  ⁘ មិនឃុំខ្លួន និងគេចខ្លួន**៥៨**នាក់

  ⁘ ឃុំខ្លួន**១៥៩**នាក់

  ⁘ អនុញ្ញាតឱ្យនៅក្រៅឃុំ**៣៩**នាក់

៤.២ **ចំណាត់ការរបស់តុលាការ :**

-ករណីសរុប : **១៦៣**ករណី ជនល្មើស**២៤៩**នាក់

  ⁘ លើកលែងចោទ**០៦**ករណី : មានជនសង្ស័យ**០៦**នាក់

  ⁘ បើកការជំនុំជំរះ**១៥៧**ករណី : មានជនជាប់ចោទ**២៤៣**នាក់

  - ឱ្យរួចពីបទចោទ**១៩**ករណី : **២៨**នាក់
  - ផ្តន្ទាទោសជាប់ពន្ធនាគារ**១៣៨**ករណី : **២១៥**នាក់ :

  ក្នុងនោះមានផ្តន្ទាទោសពិន័យជាប្រាក់**២៤**នាក់ :

**តួលេខបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនៅតាមសាលាជម្រះក្តី ឆ្នាំ២០១០ :**

| ការទទួលសំណុំរឿងករណី | | | | | | ការសម្រេចរបស់សាលាជម្រះក្តី | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំនួនករណី | ចំនួនជនរងគ្រោះ | | ចំនួនជនជាប់ចោទសរុប | | | លើកលែងចោទ | | អោយរួចផុតពីបទចោទ | | ផ្តន្ទាទោស | | |
| | អនីតិជន | នីតិជន | ឃុំខ្លួន | មិនឃុំ-គ្មានខ្លួន | អោយនៅក្រៅឃុំ | ករណី | ជនសង្ស័យ | ករណី | ជនត្រូវចោទ | ករណី | ដាក់ពន្ធនាគារ | ពិន័យជាប្រាក់ |
| ១៥២ | ១០៦ | ៧៩ | ១៥៩ | ៥៨ | ៣៩ | ០៦ | ០៦ | ១៩ | ២៨ | ១៣៨ | ២១៥ | ២៤ |

**តួលេខបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទកំណត់ដោយក្រសួងការបរទេសសហរដ្ឋអាមេរិក យកចេញពីតួលេខខាងលើ :**

| ការទទួលសំណុំរឿងករណី | | | | | | ការសម្រេចរបស់សាលាជម្រះក្តី | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំនួនករណី | ចំនួនជនរងគ្រោះ | | ចំនួនជនជាប់ចោទសរុប | | | លើកលែងចោទ | | អោយរួចផុតពីបទចោទ | | ផ្តន្ទាទោស | | |
| | អនីតិជន | នីតិជន | ឃុំខ្លួន | មិនឃុំ-គ្មានខ្លួន | អោយនៅក្រៅឃុំ | ករណី | ជនសង្ស័យ | ករណី | ជនត្រូវចោទ | ករណី | ដាក់ពន្ធនាគារ | ពិន័យជាប្រាក់ |
| ៣៦ | ៤២ | ១៣ | ៤៧ | ២១ | ០៧ | ០១ | ០១ | ០៤ | ០៤ | ៣០ | ៤៩ | ០៨ |

## ៥- ការងារសហប្រតិបត្តិការអន្តរជាតិ :

- ប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ បានចូលរួមក្នុងពិធីបិទសិក្ខាសាលា ស្តីពីទេសន្ត-ប្រវេសន៍ និងចូលរួមសន្និសីទ ស្តីពីបម្លាស់ទីរបស់ប្រជាជននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលរៀបចំសហការដោយក្រុមអង្គការស្រាវជ្រាវនៅភូមិភាគឥសាន្ត, អុកស្វាមគេបិច, ចាប់ដៃ, មូលនិធិអាស៊ី និង UNIAP ។
- ថ្នាក់ដឹកនាំលេខាធិការដ្ឋានជាតិ ប.ជ.រ.ព.ភ បានទទួលជួបជាមួយ :
  - គណៈប្រតិភូ និងប្រធានអង្គការ IOM មកពីប្រទេសអ៊ីតាលី ពិភាក្សាលើសកម្មភាពបន្តរបស់ IOM ក្នុងការគាំទ្រការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅប្រទេសកម្ពុជា ។
  - ប្រតិភូតំណាងពីសេតវិមានសហរដ្ឋអាមេរិក (White House) ពិភាក្សាអំពីលទ្ធផលនៃការវាយតម្លៃរបស់សហរដ្ឋអាមេរិក ចំពោះសកម្មភាពប្រឆាំងអំពើជួញដូរមនុស្សនៅប្រទេសកម្ពុជា ។

- គណៈប្រតិភូនីតិកម្មចិនមកធ្វើទស្សនៈកិច្ចសិក្សាស្វែងយល់អំពីរចនាសម្ព័ន្ធ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ព្រមទាំងធ្វើការចែករំលែកបទពិសោធន៍ល្អៗពីគ្នាទៅវិញទៅមក ជាពិសេសផ្តោតលើគោលបំណងសិក្សាស្រាវជ្រាវ ដើម្បីរៀបចំសេចក្តីព្រាងច្បាប់បង្ក្រាបអំពើជួញដូរមនុស្សនៅប្រទេសចិនផងដែរ ។
- ប្រតិភូចំរុះរដ្ឋាភិបាល និងអង្គការទស្សនៈពិភពលោកនៃប្រទេសបង់ក្លាដែស និងប្រតិភូអង្គការ IOM ប្រទេសឡាវ មកធ្វើទស្សនៈកិច្ចសិក្សាស្វែងយល់អំពីច្បាប់ និងយន្តការជំនាញ នៅថ្នាក់ជាតិក្នុងការបង្ក្រាបអំពើជួញដូរមនុស្សនៅកម្ពុជា និងយកជាបទពិសោធន៍ ដើម្បីអនុវត្តការបង្ក្រាបអំពើជួញដូរមនុស្សនៅប្រទេសខ្លួន ។

- លេខាធិការដ្ឋានជាតិ ប.ជ.រ.ព.ភ និងក្រុមការងារ COMMIT :
  - ដឹកនាំប្រតិភូចូលរួមប្រជុំ ថ្នាក់តំបន់លើកទី៧ (SOM-7) ក្រោមប្រធានបទ "**លទ្ធផលជោគជ័យនៃដំណោះស្រាយការប្រយុទ្ធប្រឆាំង នៃអំពើជួញដូរមនុស្ស**" នៅទីក្រុង**បាហ្គាន** ប្រទេសមីយ៉ាន់ម៉ា ។
  - បានសហការជាមួយអង្គការ UNIAP ជួបប្រជុំជាមួយសមាជិកក្រុម ថ្នាក់តំបន់ នៅទីក្រុង**បាងកក** ប្រទេសថៃ ដើម្បីរាយការណ៍ពីលទ្ធផលកិច្ចសហប្រតិបត្តិការរបស់ COMMIT និងបន្តធ្វើកិច្ចប្រជុំមួយទៀត ស្តីពីការអនុវត្តន៍កិច្ចព្រមព្រៀងកម្ពុជា-វៀតណាម នៅទីក្រុង**ហូជីមិញ** ប្រទេសវៀតណាម ។
  - បានពិភាក្សាគ្នាធ្វើបច្ចុប្បន្នភាពលើសេចក្តីព្រាងអនុស្សរណៈ នៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី ដើម្បីប្រឆាំងនឹងអំពើជួញដូរមនុស្ស និងបានពិនិត្យលើសេចក្តីព្រាងផែន-ការសកម្មភាពអនុតំបន់លើកទី៣ (២០១០-២០១៣) ។
  - បានជួបប្រជុំក្រុមការងារអនុវត្តកិច្ចព្រមព្រៀងសហប្រតិបត្តិការ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងសាធារណៈរដ្ឋសង្គមនិយមវៀតណាម ស្តីពីនីតិវិធីប្រតិបត្តិការស្តង់ដាលើការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍របស់ជនរងគ្រោះដោយសារការជួញដូរ និងធ្វើការផ្សព្វផ្សាយប្រកាសស្តីពីការបង្កើតក្រុមការងារលេខ៧៥៧ ស.អ.យ ពិនិត្យលើសេចក្តីព្រាងប្រកាសបង្កើតមណ្ឌលសំចតនៅខេត្តស្វាយរៀង ។
  - បានដឹកនាំគណៈប្រតិភូអន្តរក្រសួង និងបណ្តាអង្គការពាក់ព័ន្ធ ទៅចូលរួមប្រជុំនៅទីក្រុង**ហូជីមិញ** ប្រទេសវៀតណាម ស្តីពីការអនុវត្តន៍កិច្ចព្រមព្រៀងប្រទេសកម្ពុជា និងប្រទេសវៀតណាម ដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងកិច្ចជួយសង្គ្រោះជនរងគ្រោះដោយសារការជួញដូរ និងបានរៀបចំផែនការសកម្មភាពមួយសម្រាប់ឆ្នាំ២០១០-២០១៥ ។
- ប្រតិភូ COMMIT កម្ពុជា បានចូលរួមក្នុងសិក្ខាសាលា ស្តីពីការផ្តល់អំណាចដល់ពលករីនីចំណាកស្រុកជាមួយអង្គការ UNIFEM នៅទីក្រុង**ញ៉ូដេលី** ប្រទេសឥណ្ឌា ។
- ក្រសួងយុត្តិធម៌បាន :
  - ចាត់មន្ត្រីចូលរួមធ្វើបទបង្ហាញអំពីគោលការណ៍ច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវ-កម្មផ្លូវភេទ នៅក្នុងសិក្ខាសាលាថ្នាក់តំបន់ ស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការអនុវត្តន៍ច្បាប់ប្រឆាំងការជួញដូរមនុស្ស ដែលរៀបចំឡើងដោយ UNODC កាលពីថ្ងៃទី ២៩-៣០ ខែមេសា ឆ្នាំ២០១០ នៅទីក្រុង **បាងកក** ប្រទេសថៃឡង់ដ៍ ។
  - ចាត់មន្ត្រី និងចៅក្រម ព្រះរាជអាជ្ញាមួយចំនួនចូលរួមសិក្ខាសាលា ស្តីពីការស៊ើបអង្កេត និងការចោទប្រកាន់ករណីជួញដូរមនុស្ស ដែលរៀបចំឡើងដោយ ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា កាលពីថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០១០ ។
  - ចាត់មន្ត្រី ចូលរួមក្នុងសិក្ខាសាលា ស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីអនុវត្តសន្ធិសញ្ញាជួយគ្នាទៅវិញទៅមកក្នុងការអនុវត្តន៍ច្បាប់ប្រឆាំងការជួញដូរមនុស្ស ដែលរៀបចំឡើងដោយមហាអយ្យការនៃប្រទេស**ថៃឡង់ដ៍**កាលពីថ្ងៃទី ៨-១២ ខែវិច្ឆិកា ឆ្នាំ២០១០ នៅទីក្រុង**បាងកក** ។

- ក្រសួងទេសចរណ៍ បានធ្វើបទបង្ហាញមួយនៅប្រទេសស្រីលង្កា ស្តីពី **"ការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍"** ដើម្បីទប់ស្កាត់ការជួញដូរកុមារ ការកេងប្រវញ្ចផ្លូវភេទ និងកម្លាំងពលកម្មកុមារលើវិស័យទេសចរណ៍ ។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានសហការជាមួយអង្គការទស្សនៈពិភពលោក និង អង្គការមេត្រីភាពកម្ពុជា ធ្វើទស្សនៈកិច្ចផ្លាស់ប្តូរបទពិសោធន៍ និងតាមដានពីស្ថានភាពជនរងគ្រោះជនជាតិវៀតណាម ដែលរងគ្រោះដោយសារការជួញដូរ ហើយបានធ្វើមាតុភូមិនិវត្តន៍ក្នុងខេត្តអាងយ៉ាង ដុងថាប និងទីក្រុង**ហូជីមិញ** ប្រទេសវៀតណាម ។
- ក្រសួងកិច្ចការនារី បានចូលរួមប្រជុំថ្នាក់តំបន់ ស្តីពីទេសន្តរប្រវេសន៍ និងកិច្ចអភិវឌ្ឍន៍ ដែលរៀបចំដោយ UNESCAP នៅទីក្រុង**បាងកក** ប្រទេសថៃ ក្នុងនោះក៏បានធ្វើបទបង្ហាញអំពីការងារទេសន្តរប្រវេសន៍ដោយស្របច្បាប់ និងមិនស្របច្បាប់របស់ពលករកម្ពុជាផងដែរ ។
- ក្រុមការងារកិច្ចការកុមារ និងប្រធានក្រុមការងារ COMMIT បានដឹកនាំគណៈប្រតិភូកុមារ និង យុវជនកម្ពុជា ទៅចូលរួមក្នុងវេទិកាយុវជនមេគង្គថ្នាក់តំបន់ ដែលរៀបចំឡើងដោយអង្គការ UNIAP នៅទីក្រុង**បាងកក** ដើម្បីពិនិត្យលើការងារអនុវត្ត និងពិភាក្សាជាមួយយុវជនអំពីការងារដែលត្រូវធ្វើបន្តក្នុងការទប់ស្កាត់អំពើជួញដូរមនុស្ស កិច្ចជួយសង្គ្រោះជនរងគ្រោះ និងការផ្តន្ទាទោសជនល្មើស ។
- នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានចាត់នាយនគរបាល ឱ្យចូលរួមតាមការអញ្ជើញទៅបណ្តាប្រទេសដូចខាងក្រោម ៖
  - បានជួបប្រជុំជាមួយអាជ្ញាធរវៀតណាម ដើម្បីបូកសរុបការងាររយៈពេល៥ឆ្នាំ នៃការអនុវត្តកិច្ចព្រមព្រៀងសហប្រតិបត្តិការដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងកិច្ចជួយសង្គ្រោះជនរងគ្រោះដោយសារការជួញដូរ ។
  - ចូលរួមជាសក្ខីកម្មក្នុងសវនាការពលរដ្ឋអាមេរិក នៅ**ទីក្រុង** Los Angeles **រដ្ឋ** California សហរដ្ឋអាមេរិក ពីបទរួមភេទជាមួយក្មេងស្រីអាយុក្រោម១៥ឆ្នាំនៅកម្ពុជា ។
  - បានបើកវគ្គបណ្តុះបណ្តាលរួមគ្នាជាមួយសមត្ថកិច្ចប្រទេសថៃ ស្តីពីការជួញដូរមនុស្សឆ្លងដែន ឱ្យដល់មន្ត្រីអនុវត្តច្បាប់ថ្នាក់មូលដ្ឋាន (ថៃ-កម្ពុជា) នៅខេត្តកោះកុង ។
  - បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលរួមគ្នានៅប្រទេសថៃ និងប្រទេសឥណ្ឌូនេស៊ី ស្តីពីសកម្មភាពក្រុមចំរុះដែលមានទិសដៅក្នុងការប្រយុទ្ធប្រឆាំងការជួញដូរ ការចែករំលែកបទពិសោធន៍គ្នា រវាងបណ្តាប្រទេសក្នុងតំបន់មេគង្គ និងការជួញដូរមនុស្ស ព្រមទាំងការស៊ើបអង្កេតករណីជួញដូរមនុស្សនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។
  - បានចូលរួមកិច្ចប្រជុំលើកទី៥ នៃគណៈកម្មាធិការសម្របសម្រួលថ្នាក់តំបន់ (RPCC) របស់គម្រោងតំបន់អាស៊ី ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្សនៅទីក្រុង **Cebu** ប្រទេសហ្វីលីពីន ក្រោមការឧបត្ថម្ភពី Aus-AID ។
  - បានចូលរួមក្នុងសិក្ខាសាលាថ្នាក់តំបន់នៅប្រទេសម៉ាឡេស៊ី ស្តីពីការធ្វើសំណូកប្រាក់ដែលបានមកពីការជួញដូរមនុស្ស ។

## ៦- <u>ការងារកិច្ចការកុមារ</u> ៖

- ក្រុមការងារកិច្ចការកុមារនៃលេខាធិការដ្ឋាន ប.ជ.រ.ព.ភ សហការជាមួយអង្គការទស្សនៈពិភពលោក និងអង្គការចំនួន**៧**ទៀត ៖ ទីភ្នាក់ងារអង្គការសហប្រជាជាតិ, ទីភ្នាក់ងារអង្គការអន្តរជាតិផ្សេងទៀតរួមមាន ៖ ILO, UNIAP, UNICEF, The Asia Foundation, Save The Children និង Child Fund Cambodia រៀបចំវេទិកាកុមារ-យុវជនមេគង្គថ្នាក់ជាតិលើកទី**៣** ស្តីពីអំពើជួញដូរមនុស្ស និងចំណាកស្រុក នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារយៈពេល**៣**ថ្ងៃ ដែលមាន ភ្ញៀវជាតិ និងអន្តរជាតិចូលរួមចំនួន**៨០**នាក់ មកពី១៥រាជធានី-ខេត្ត ក្រោមអធិបតីភាពឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងលោកជំទាវ **ជូ ប៊ុនអេង** ប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ ដឹកនាំ ប.ជ.រ.ព.ភ ។ វេទិកានេះបានបន្តសហការធ្វើទៅលើខេត្តពីរ

ទៀតគឺ បាត់ដំបង និងស្វាយរៀង ដោយមានកុមារចំនួន **៧៧**នាក់ និងយុវជនចំនួន**១១០**នាក់ មកពីខេត្ត : ព្រៃវែង, កំពង់ចាម, ពោធិ៍សាត់, ក្រចេះ, សៀមរាប, បន្ទាយមានជ័យ, និង រតនៈគិរី ចូលរួមផងដែរ ។

-ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានបើកវេទិកាកុមារថ្នាក់ជាតិ ស្តីពីការពិគ្រោះយោបល់លើសេចក្តីព្រាងរបាយការណ៍ពីការអនុវត្តន៍ពិធីសារបន្ថែម នៃអនុសញ្ញាសិទ្ធិកុមារនៃការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ និងការលក់កុមារ ការធ្វើពេស្យាចារកុមារ និងរូបភាពអាសអាភាសកុមារ ដោយមានសមាជិកចូលរួមក្នុងវេទិកានេះចំនួន**៩៦**នាក់ (ស្រី**១៩**នាក់) និងកុមារ**៤៤**នាក់ ផងដែរ ។

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃនាយកដ្ឋានការងារកុមារ សហការជាមួយអង្គការ Winrock និងអង្គការ ILO/IPEC ប្រជុំចំនួន**០៣**លើក ដល់អនុគណៈកម្មការជាតិពលកម្មកុមារ និងទម្រង់នៃការកេងប្រវ័ញ្ចន៏ផ្សេងៗទៀតលើកុមារ ស្តីពីកិច្ចសហប្រតិបត្តិការ និងការចែករំលែកព័ត៌មាន ជាមួយដៃគូពាក់ព័ន្ធនឹងពលកម្មកុមារ គោលបំណងលុបបំបាត់ពលកម្មកុមារតាមគម្រោងក្នុងខេត្តចំនួន**០៤** និងរៀបចំផែនការនិរន្តភាពដើម្បីលុបបំបាត់ពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរឱ្យអស់ក្នុងឆ្នាំ ២០១៦ នៅកម្ពុជា ។ ព្រមជាមួយគ្នានោះក្នុងឆ្នាំ២០១០កន្លងទៅនាយកដ្ឋានការងារកុមារសហការសម្រេចបាន :

- ដកហូតពលកម្មកុមារ ពីទម្រង់ធ្ងន់ធ្ងរក្នុងវិស័យកសិកម្ម ដើម្បីផ្តល់ការអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្ម បានចំនួន**៨,៤៧១**នាក់ (កុមារចំនួន**៤,៩២៥**នាក់, កុមារីចំនួន**៣,៥៤៦**នាក់) ។
- ប្រជុំជាមួយអង្គការពលកម្មអន្តរជាតិខាងការងារ ចំនួន**០៣**លើក ស្វែងយល់អំពីតំលាត និងការបំពេញតម្រូវការគោលនយោបាយ ច្បាប់ និងអធិការកិច្ច ដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ។
- ចូលរួមប្រជុំ ចំនួន**០៥**លើក ស្តីពីការឆ្លើយតបជាពហុវិស័យឱ្យកាន់តែប្រសើរឡើងសម្រាប់កុមារកំព្រា និងកុមារងាយរងគ្រោះ អនុម័តលើការងារអាទិភាពក្នុងផែនការប្រតិបត្តិការ ។

- ក្រសួងទេសចរណ៍ បានជួបប្រជុំជាមួយអង្គការអែដេទូដើម្បីពិភាក្សាលើសំណើសុំបន្តអនុស្សរណៈ នៃការយោគយល់គ្នាក្នុងគំរោងកម្មវិធីថ្មីៗ **"ការបញ្ឈប់ទេសចរណ៍ផ្លូវភេទជាមួយកុមារ"** សម្រាប់រយៈពេល៣ឆ្នាំ (២០១០-២០១៤) និងបានចូលរួមប្រជុំជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ស្តីពីការកែសម្រួលផែនការសកម្មភាពជាតិ**៥**ឆ្នាំ នៃការប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ, ការផ្តល់យោបល់ពីស្ថានភាពកុមារនៅកម្ពុជា សម្រាប់ឆ្នាំ២០០៩-២០១០ ព្រមទាំងការផ្តល់យោបល់លើការបង្កើតសញ្ញាថ្មីរបស់ក្រុមប្រឹក្សាជាតិដើម្បីកុមារ និងការផ្តល់មតិលើសេចក្តីព្រាងរបាយការណ៍ពិធីសារជម្រើសដកស្រង់ចេញពីអនុសញ្ញា ស្តីពីសិទ្ធិកុមារ និងការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ, ការជួញដូរកុមារ ការធ្វើអាជីវកម្មពលកម្មកុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសនៃកុមារ ។

## **យ- ការលើកកម្ពស់សមត្ថភាព :**

ដើម្បីឱ្យការងារប្រឆាំងការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចន៏ពលកម្ម និងផ្លូវភេទ ទទួលបានលទ្ធផលដូចខាងលើនេះ, ក្រុមការងារគ្រប់ផ្នែក ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាព ដល់មន្ត្រី និងភ្នាក់ងារអនុវត្តជាបន្តបន្ទាប់ ដូចខាងក្រោម :

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបើកសិក្ខាសាលាផ្សព្វផ្សាយអំពីគោលនយោបាយ បទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដល់សមាជិកលេខាធិការដ្ឋាន ប.ជ.រ.ព.ភ និងតាមបណ្តាខេត្ត ។

- បានសហការជាមួយអង្គការ IOM, USAID, The Asia Foundation, ស៊ីសា បើកវគ្គសិក្ខាសាលា និងបណ្តុះបណ្តាលក្រុមការងារចំនួន**៣**វគ្គ : ស្តីពីការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្ស, កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលមានសិក្ខាកាមពីក្រសួង មន្ទីរ ស្ថាប័នដៃគូពាក់ព័ន្ធ ចំនួន**២២២**នាក់ចូលរួម ។

- បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោល១វគ្គ ចំនួន២៨នាក់ (ស្រី៩នាក់) ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស ក្នុងក្របខណ្ឌក្រសួង សម្រាប់ចុះអប់រំផ្សព្វផ្សាយនៅតាមបណ្តារាជធានី-ខេត្ត ។ ក្នុងនោះដែរក្រសួងបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាចំនួន២វគ្គទៀត គឺនៅខេត្តស្វាយរៀង សៀមរាប កោះកុង និងខេត្តរតនៈគិរី ស្តីពីយុទ្ធសាស្ត្រនៃការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស គម្រោងសាកល្បងលើសេចក្តីព្រាងប្រកាស អនុម័តគោលនយោបាយ ស្តីពីការថែទាំកុមារ ។

- ក្រសួងយុត្តិធម៌បានចាត់មន្ត្រីចូលរួមធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដល់ :

- មន្ត្រីតាមមន្ទីរនានាជុំវិញខេត្តរតនៈគិរី បាត់ដំបង និងខេត្តកំពង់ចាមសរុបមានសិក្ខាកាមប្រមាណ១៦០នាក់ ។
- មន្ត្រី មេបញ្ជាការ មេបញ្ជាការរង នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី-ខេត្ត ទូទាំងប្រទេសប្រមាណ៦០នាក់ ។
- មន្ត្រីនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈប្រមាណ៦០នាក់ ។

- ក្រសួងទេសចរណ៍ សហការជាមួយអង្គការ UNIAP និងមូលនិធិសុម៉ាលីម៉ម បើកវគ្គបណ្តុះបណ្តាល ស្តីពីការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ក្រមសីលធម៌ការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទក្នុងវិស័យទេសចរណ៍ដល់សិក្ខាកាមចំនួន៣១៧នាក់(ស្រី៦៨នាក់) មកពីបណ្តាមន្ទីរទេសចរណ៍ នៅក្នុងខេត្តកំពង់ចាម បាត់ដំបង កំពត កែប ប៉ៃលិន និងខេត្តរតនៈគិរី និងបានចូលរួមធ្វើបទបង្ហាញក្នុងវគ្គបណ្តុះបណ្តាល ស្តីពី **"យុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស"** ដល់កងរាជអាវុធហត្ថ ក្នុងរាជធានី -ខេត្តចំនួន២៣ ផងដែរ ។

- ក្រសួងកិច្ចការនារី និងក្រុមការងារ COMMIT បានសហការជាមួយអង្គការ UNIAP, IOM និងមូលនិធិសុម៉ាលីម៉ម គំរោងថវិកាកម្មវិធីរបស់រាជរដ្ឋាភិបាល (PB)បានបើកវគ្គបណ្តុះបណ្តាល ស្តីពីយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សចំនួន៩វគ្គ នៅខេត្តរតនៈគិរី, ប៉ៃលិន, កំពត, បាត់ដំបង, និងខេត្តកំពង់ចាម មានសិក្ខាកាមសរុប២៧២នាក់ វគ្គបណ្តុះបណ្តាលស្តីពីការលើកកម្ពស់ការយល់ដឹងស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពចំនួន១វគ្គនៅស្រុកម៉ាល័យ ខេត្តបន្ទាយមានជ័យ មានសិក្ខាកាមសរុប៤១នាក់ និងវគ្គបណ្តុះបណ្តាលស្តីពីសកម្មភាពថ្នាក់ភូមិដើម្បីទប់ស្កាត់ការជួញដូរមនុស្សចំនួន៩វគ្គ នៅខេត្តក្រចេះ, ស្ទឹងត្រែង, ប៉ៃលិន, តាកែវ, និងខេត្តព្រះសីហនុ មានសិក្ខាកាមសរុប២០០នាក់បានចុះពិនិត្យនិងវាយតម្លៃលើសកម្មភាពរបស់សិក្ខាកាមចំនួន១៦០នាក់/២០០នាក់ ដែលបានទទួលការបណ្តុះបណ្តាលរួចក្នុងខេត្តទាំង៥ : (ក្រចេះ, ស្ទឹងត្រែង, ប៉ៃលិន, តាកែវ, និងខេត្តព្រះសីហនុ) ។ ព្រមជាមួយគ្នានេះក្រសួងក៏បានចាត់បញ្ជូនគ្រូឧទ្ទេសទៅចូលរួមក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការលើកកម្ពស់ការយល់ដឹងពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភផ្លូវភេទលើកុមារ ការប្រើប្រាស់គ្រឿងញៀន និងអំពើទំនាស់នឹងច្បាប់របស់កុមារនៅខេត្តបន្ទាយមានជ័យ ដែលរៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការទស្សនៈពិភពលោក ។ និងវគ្គបណ្តុះបណ្តាល អំពីយេនឌ័រ និងកិច្ចអភិវឌ្ឍន៍ដែលពាក់ព័ន្ធដល់ការជួញដូរមនុស្ស និងអំពើហិង្សាលើស្ត្រី ដែលរៀបចំឡើងដោយអង្គការ ICC ខេត្តរតនៈគិរី ។

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **"នាយកដ្ឋានការងារកុមារ"** សហការជាមួយអង្គការ ILO/IPEC និងអង្គការ Winrockកម្ពុជា ប្រជុំក្រុមការងារសម្រាប់សិក្សាស្រាវជ្រាវ ដើម្បីរៀបចំប្រកាសពាក់ព័ន្ធពលកម្មកុមារប្រកបដោយគ្រោះថ្នាក់ក្នុងវិស័យកសិកម្មចំនួន០៥លើក ។ ធ្វើការផ្សព្វផ្សាយបណ្តុះបណ្តាលសមាជិកគណៈកម្មការកុមារខេត្ត ចុះធ្វើការពិនិត្យតាមដានផែនការអនុវត្តគម្រោងក្នុងខេត្តគោលដៅ : ខេត្តពោធិ៍សាត់ចំនួន០៤លើក, ព្រៃវែង០៤លើក, សៀមរាប០៤លើក, និងខេត្តកំពង់ចាម០៤លើក ។

- នាយកដ្ឋានជំនាញ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានចូលរួមនិងសហការជាមួយបណ្តាក្រសួង អង្គការដៃគូ : ស្ថានទូតបារាំង, អូស្ត្រាលី, អាមេរិក, អង្គការ IOM, SISHA, IJM, CWCC, World Vision, UNIAP, Oxfam Quebec, ICE, SEADO, Terre des Hommes, គំរោង

LEASETC, គំរោងកាម៉ូណូហាស៊ី បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីការងារចំនួន៤០វគ្គ សិក្ខាកាមសរុបចំនួន **២,១៦១**នាក់ (ស្រី**២៧៧**នាក់) ដោយបានប្រព្រឹត្តទៅនៅក្រសួងពាក់ព័ន្ធក្នុងរាជធានីភ្នំពេញ និងខេត្តកណ្តាល កំពង់ចាម កំពង់ឆ្នាំង, ស្វាយរៀង, បាត់ដំបង, បន្ទាយមានជ័យ, សៀមរាប និងរតនៈគីរី ក្នុងនោះ ៖

- វគ្គបណ្តុះបណ្តាលចំនួន**៣១**វគ្គ សិក្ខាកាមចំនួន**១,៣៤៨**នាក់ (ស្រី**១៦៤**នាក់) ស្តីពីច្បាប់បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ការប្រមូលភស្តុតាង ការឆែកឆេរមនុស្ស ការត្រួតពិនិត្យឆែកឆេរកំព្យូទ័រ និងឧបករណ៍រក្សាទុកទិន្នន័យផ្សេងៗ មេរៀនឧក្រិដ្ឋកម្មឆ្លងដែនរបស់នីសេរីយ៉ា ក្រមនីតិវិធីព្រហ្មទណ្ឌ បច្ចេកទេសសម្ភាសន៍ជនសង្ស័យ ការការពារសាក្សី ការកំណត់អត្តសញ្ញាណ ការងារបង្ការ-បង្ក្រាបទប់ស្កាត់អំពើជួញដូរមនុស្ស ការជួញដូរមនុស្សសម្រាប់មេបញ្ជាការឯកទេស យុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ទេសចរណ៍ផ្លូវភេទ និងការកេងប្រវ័ញ្ចផ្លូវភេទកុមារ ការទទួលបន្ទុកអនីតិជនដោយអំពើជួញដូរផ្លូវភេទ និងការសម្ភាសន៍យកចម្លើយពីជនរងគ្រោះដោយសារការជួញដូរ ។
- វគ្គសិក្ខាសាលាចំនួន**៩**វគ្គ សិក្ខាកាមចំនួន**៨១៣**នាក់ (ស្រី**១១៣**នាក់) ស្តីពីគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយសារការជួញដូរ ដំណោះស្រាយរឿងក្តីពាក់ព័ន្ធនឹងគ្រួសារកុមារក្នុងប្រព័ន្ធតុលាការ ការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ការទប់ស្កាត់អំពើល្មើសច្បាប់របស់កុមារ ការប្រើប្រាស់គ្រឿងញៀនដែលពាក់ព័ន្ធទៅនឹងការរំលោភផ្លូវភេទ ការរៀបចំតុលាការគំរូសាកល្បងសម្រាប់អនីតិជន ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុកដោយប្រថុយប្រថានខុសច្បាប់ ល្បិចកលរបស់ជនល្មើស ការកំណត់អត្តសញ្ញាណអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារដែលត្រូវទទួលជីសម្បទានសង្គមកិច្ច ។

- នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចូលរួមជាវាគ្មិនក្នុងកម្មវិធីពិភាក្សាតុមូល និងជាគ្រូឧទ្ទេសក្នុងការងារផ្សព្វផ្សាយក្នុងវគ្គបណ្តុះបណ្តាលស្តីពី "ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ, ការរួមគ្នាប្រឆាំងនឹងអំពើជួញដូរមនុស្ស, សុវត្ថិភាពចំណាកស្រុកនិងការងារ, ទេសន្តរប្រវេសន៍ការងារ និងចំណេះដឹងផ្នែកច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស" ។

## ៦- ការងារតាមដានត្រួតពិនិត្យ ៖

- សម្របសម្រួលឱ្យមានកិច្ចប្រជុំទៀងទាត់តាមបណ្តាក្រុមការងារទាំងប្រាំមួយ ដើម្បីតាមដាន ត្រួតពិនិត្យការអនុវត្តន៍ការងារ ដែលក្រសួងស្ថាប័ននីមួយៗ ក៏ដូចជាអង្គការសមាជិកនីមួយៗ បានប្តេជ្ញាចិត្តចូលរួម និងធ្វើសកម្មភាពតាមតួនាទីភារកិច្ចដែលបានចែងក្នុងអនុក្រឹត្យលេខ ១៦២ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិ ប.ជ.រ.ព.ភ និងសេចក្តីសម្រេចលេខ ៩២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃលេខាធិការដ្ឋាន ប.ជ.រ.ព.ភ ។

- លេខាធិការដ្ឋាន តាមដានជាប្រចាំ នូវព័ត៌មានដែលផ្តល់ឱ្យដោយលេខាធិការដ្ឋាន រាជធានី-ខេត្ត ដែលមានស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ជាសេនាធិការដោយបានទំនាក់ទំនងជាទៀងទាត់រាល់សប្តាហ៍ ចំពោះការតាមដានបទល្មើស និងប្រចាំខែចំពោះរបាយការណ៍រួមរបស់លេខាធិការដ្ឋាន ។

- ក្រសួងអប់រំ យុវជន និងកីឡា បានប្រជុំត្រួតពិនិត្យលើកម្មវិធីបណ្តុះបណ្តាលយុទ្ធសាស្ត្រទប់ស្កាត់អំពើជួញដូរមនុស្សនៅតាមសាលារៀន និងការបណ្តុះបណ្តាលគ្រូឧទ្ទេសទៅតាមសាលាគរុកោសល្យរាជធានី-ខេត្ត និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ។

- ក្រុមពិនិត្យតាមដាននៃលេខាធិការដ្ឋានថ្នាក់ជាតិ ប.ជ.រ.ព.ភ បានចុះធ្វើការប៉ាន់ប្រមាណពីដំណើរការរបស់លេខាធិការដ្ឋាន នៃរាជធានីភ្នំពេញ ខេត្តកោះកុង និងខេត្តបន្ទាយមានជ័យ ដើម្បីស្វែងយល់ និងផ្លាស់ប្តូរបទពិសោធន៍លើខេត្តទាំងនោះដើម្បីយកធ្វើជាបទពិសោធន៍សម្រាប់ខេត្តដទៃទៀត និងជម្រុញឱ្យមានការបណ្តុះបណ្តាល មន្ត្រីលេខាធិការដ្ឋានដើម្បីឱ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញមុខងាររបស់ខ្លួន ។

- បានជម្រុញការត្រួតពិនិត្យការងារ និងពង្រឹងការអនុវត្តច្បាប់ ជាពិសេសការងារបង្ក្រាប អំពើជួញដូរមនុស្ស គ្រប់រូបភាពតាមរយៈការប្រជុំត្រួតពិនិត្យការងារប្រចាំខែ ជាមួយនាយកដ្ឋានជំនាញពាក់ព័ន្ធ និងស្នងការងទទួលបន្ទុកជំនាញរបស់ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ។

## ច- ការងារគណៈកម្មាធិការដឹកនាំ និងលេខាធិការដ្ឋាន ប.ជ.រ.ព.ភ រាជធានី-ខេត្ត :

### ១. ការងាររចនាសម្ព័ន្ធ :

តាំងពីគណៈកម្មាធិការជាតិដឹកនាំ ការបង្ក្រាបអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ (ប.ជ.រ.ព.ភ) ត្រូវបានបង្កើតឡើងកាលពីចុងឆ្នាំ២០០៩រួចមក ការរៀបចំគណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ រាជធានី-ខេត្ត និងលេខាធិការដ្ឋាន ពុំទាន់បានធ្វើឡើងទាន់ពេលវេលា ដើម្បីអនុវត្តព្រមគ្នាជាមួយថ្នាក់ជាតិនៅឡើយទេ អាស្រ័យដោយមានភាពមមាញឹកក្នុងការកែសម្រួលរបៀបរបបការងារ នៅថ្នាក់ក្រោមជាតិ ទៅតាមបទដ្ឋានថ្មីនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការអនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។ ដើម្បីសម្របសម្រួលដល់ការរៀបចំគណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ រាជធានី-ខេត្ត គណៈកម្មាធិការជាតិ បានចេញលិខិតណែនាំ លេខ០០២ ស.ស.រ ចុះថ្ងៃទី០៣/៧/១០ ស្តីពីការរៀបចំប្រព្រឹត្តទៅគណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ រាជធានី-ខេត្ត ។

អនុវត្តតាមសេចក្តីណែនាំនេះ មានខេត្តចំនួន១១ បានធ្វើការកែសម្រួលសមាសភាពគណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ និងលេខាធិការដ្ឋាន របស់ខ្លួនរួចរាល់មាន : ខេត្តកណ្តាល, ស្វាយរៀង, កំពត, កំពង់ស្ពឺ, ព្រះវិហារ, បន្ទាយមានជ័យ, កោះកុង, ក្រចេះ, រតនៈគីរី, ព្រៃវែង, និងខេត្តសៀមរាប ។

ដោយឡែក:

- ខេត្តចំនួន០៣ មិនទាន់បានធ្វើការកែសម្រួលសមាសភាពលេខាធិការដ្ឋាន គឺខេត្តស្ទឹងត្រែង, កំពង់ធំ, និងខេត្តប៉ៃលិន ។
- ខេត្តចំនួន១០ មិនទាន់បានធ្វើការកែសម្រួលទាំងសមាសភាពគណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ និង លេខាធិការដ្ឋានរាជធានី-ខេត្តរបស់ខ្លួនឡើងវិញ មាន : រាជធានីភ្នំពេញ, ខេត្តបាត់ដំបង, ព្រះសីហនុ, កំពង់ឆ្នាំង, កំពង់ចាម, កែប, តាកែវ, ពោធិ៍សាត់, មណ្ឌលគីរី, និងឧត្តរមានជ័យ ។

### ២. ការងារប្រឆាំងការជួញដូរមនុស្ស :

- គណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ ខេត្តសៀមរាប, បន្ទាយមានជ័យ, ព្រៃវែង, កំពង់ធំ, កំពង់ស្ពឺ, ក្រចេះ, ព្រះសីហនុ, ស្វាយរៀង, និងខេត្តកណ្តាល បានធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីច្បាប់បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ, អំពើហិង្សាក្នុងគ្រួសារ, និងច្បាប់ពាក់ព័ន្ធផ្សេងៗទៀត ដល់ប្រជាពលរដ្ឋនៅតាមបណ្តាស្រុក បានចំនួន **៤៤,២២៩**នាក់( **ស្រី១៩,៣៧៧**នាក់) ។ ដោយឡែកខេត្តសៀមរាប បានរៀបចំវេទិកានារីរតនៈស្តីពីការស្វែងយល់ដល់យុវវ័យពីអំពើហិង្សាក្នុងគ្រួសារ និងធ្វើការផ្សព្វផ្សាយលេខទូរស័ព្ទអចិន្ត្រៃយ៍របស់ខេត្តដល់ប្រជាពលរដ្ឋ ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការទំនាក់ទំនងនៅពេលមានបញ្ហាកើតឡើង និងខេត្តបន្ទាយមានជ័យ បានចុះធ្វើការត្រួតពិនិត្យធ្វើកិច្ចសន្យាតាមគោលដៅបញ្ចូលរូបភាពតាមទូរស័ព្ទ នៅក្នុងភូមិសាស្ត្រស្រុកមួយចំនួន និងធ្វើការប៉ាន់ប្រមាណពីការយល់ដឹងរបស់ប្រជាពលរដ្ឋ លើការទប់ស្កាត់អំពើជួញដូរមនុស្ស ។ ព្រមជាមួយនោះបានធ្វើជាវាគ្មិនក្នុងកម្មវិធីសំណួរ-ចម្លើយតាមវិទ្យុផ្សាយសំឡេងខេត្តនៅរៀងរាល់ថ្ងៃសុក្រ ដែលពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទល្មើសក៏ដូចជាវិធានការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ។

- លេខាធិការដ្ឋាន នៃគណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ ខេត្តកណ្តាល សហការជាមួយមន្ទីរកិច្ចការនារី និងសមាគមន៍នារីដើម្បីសន្តិភាពអភិវឌ្ឍន៍ បានហែរក្បួនយុទ្ធនាការបង្ការទប់ស្កាត់ការជួញដូរមនុស្ស នៅក្នុងឃុំក្អមសំណរស្រុកលើកដែក និងឃុំសំពៅលូន ស្រុកកោះធំ ដោយមានប្រជាពលរដ្ឋចូលរួម ចំនួន**៨៧០**នាក់ ។

- លេខាធិការដ្ឋាន នៃគណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ ខេត្តបន្ទាយមានជ័យសហការជាមួយអង្គការ UNIAP The Asia Foundation និងអង្គការ VCAO បើកវគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលា បានចំនួន២វគ្គដែលមានសិក្ខាកាមចំនួន៨៧នាក់ ក្នុងនោះមាន :

- វគ្គបណ្ដុះបណ្ដាល ស្ដីពីការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងគោលនយោបាយបទដ្ឋានអប្បបរមា ស្ដីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស សិក្ខាកាមចូលរួមចំនួន៤៧នាក់ ។
- វគ្គសិក្ខាសាលា ស្ដីពីការពង្រឹងបណ្ដាញការពារកុមារថ្នាក់ខេត្ត សិក្ខាកាមចូលរួមចំនួន៤០នាក់ ។
- សហការជាមួយមន្ទីរ អង្គការដៃគូក្នុងខេត្ត បើកវគ្គបណ្ដុះបណ្ដាល មុខវិជ្ជាផ្សេងៗទៀតឱ្យដល់ប្រជាពលរដ្ឋនៅតាមសហគមន៍មួយចំនួន ដើម្បីកសាងសមត្ថភាពក្នុងការបង្កើតមុខរបរ និងការរកប្រាក់ចំណូលឱ្យជីវភាពគ្រួសារកាន់តែប្រសើរឡើង ។

- លេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ ខេត្តស្វាយរៀង និងកោះកុង បានសហការជាមួយអង្គការ USAID និង The Asia Foundation បើកវគ្គបណ្ដុះបណ្ដាលដើម្បីពង្រឹងសមត្ថភាពមន្ត្រីលេខាធិការដ្ឋាន និងមន្ត្រីមូលដ្ឋាន ចំនួន៦.៨៦២នាក់ ( ស្រី៣.៤៩៣នាក់) ស្ដីពីការយល់ដឹងអំពីទិដ្ឋភាពទូទៅនៃច្បាប់បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស គោលនយោបាយបទដ្ឋានអប្បបរមាស្ដីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជំនាញផ្សេងៗទៀត ក្នុងការបង្កើតមុខរបរដើម្បីឱ្យជីវភាពកាន់តែប្រសើរឡើង ។

- យុទ្ធនាការផ្សព្វផ្សាយ បានធ្វើឡើងនៅក្នុងទិវាប្រឆាំងការជួញដូរមនុស្ស១២ធ្នូ ក្នុងនោះ :

- រាជធានីភ្នំពេញ បានសហការជាមួយក្រសួងកិច្ចការនារី និងអង្គការ AFESIP និងមូលនិធិសុម៉ាលីម៉ម រៀបចំទិវាជាតិ ប្រឆាំងការជួញដូរមនុស្ស១២ធ្នូ ដោយមានសកម្មភាពចំនួនពីរគឺ :
  - ធ្វើសន្និសីទសារព័ត៌មានក្រោមអធិបតីភាពលោកជំទាវរដ្ឋមន្ត្រី ក្រសួងកិច្ចការនារី នៅក្នុងក្រសួងកិច្ចការនារី ដែលមានអ្នកចូលរួមចំនួន១០០នាក់ ។
  - ពិធីមិទ្ទីញអបអរសាទរក្រោមអធិបតីភាពលោកជំទាវបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា និងជាប្រធានកិត្តិយសគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រីខ្មែរ និងគ្រួសារខ្មែរ គ.ជ.ស.ស.ខ នៅសួនច្បារមុខវត្តបុទុមតី និងមានប្រជាពលរដ្ឋចូលរួមប្រមាណ៦.០០០នាក់ ។

- ដោយឡែកខេត្តបន្ទាយមានជ័យ សហការជាមួយអង្គការ Big C បណ្ដាញការពារកុមារតាមព្រំដែន រៀបចំទិវាប្រឆាំងការជួញដូរមនុស្ស១២ ធ្នូ នៅស្រុកម៉ាល័យនិងសហការជាមួយអង្គការ SEADO ( អង្គការអភិវឌ្ឍន៍កសិកម្មនិងបរិស្ថានសង្គម) រៀបចំព្រឹត្តិការណ៍ដើរនៅក្រុងសិរីសោភ័ណ រួមទាំងបានធ្វើពិធីដង្ហែក្បួនតាមព្រំដែន និងក្នុងក្រុងសិរីសោភ័ណ មានប្រជាជនសរុបប្រមាណ៣.០០០នាក់ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** ប្រធានលេខាធិការដ្ឋាន ប.ជ.រ.ព.ភ ថ្នាក់ជាតិ ។

- នៅខេត្តសៀមរាប សហការជាមួយអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) រៀបចំទិវាជាតិប្រឆាំងការជួញដូរមនុស្ស ដោយមានការដង្ហែក្បួនជុំវិញទីក្រុង និងមានអ្នកចូលរួមប្រមាណ៥០០នាក់ ។

## III. ការវាយតម្លៃ :

### ក. ចំណុចខ្លាំង :

- ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា គឺជាការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ដោយចាត់ទុកថា ការជួញដូរមនុស្សគ្រប់រូបភាព គឺជាការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ និងធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់អធិបតេយ្យភាពបុគ្គល និងប្រទេសជាតិ ដែលមិនអាចអត់អោនបាន ។ កម្ពុជាមានច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមនីតិវិធីព្រហ្មទណ្ឌ និងថ្មីៗនេះក្រមព្រហ្មទណ្ឌ ត្រូវបានអនុវត្ត ព្រមទាំងបានបង្កើតនូវ

បទដ្ឋានគតិយុត្តិមួយចំនួនទៀត ដើម្បីបំពេញបន្ថែមលើការខ្វះខាត និងសម្រួលដល់ការអនុវត្តន៍ឱ្យរឹតតែមានប្រសិទ្ធភាពទ្វេឡើងទៀត ។

- មិនតែប៉ុណ្ណោះ យើងមានយន្តការជាតិ ដែលហៅថាគណៈកម្មាធិការជាតិដឹកនាំ ការបង្ក្រាបអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដែលជាការរួមបញ្ចូលនូវកិច្ចខិតខំប្រឹងប្រែងរួមគ្នាជាពហុវិស័យ ក្រោមយុទ្ធសាស្ត្រដ៏ទូលំទូលាយ ដែលមានទាំងការបង្ការទប់ស្កាត់មុនមានបទល្មើស រហូតដល់ការបង្ក្រាប ការផ្តន្ទាទោសជនល្មើស និងការការពារជនរងគ្រោះ ដោយផ្តល់សេវាស្តារនីតិសម្បទាសមាហរណកម្ម និងមាតុភូមិនិវត្តន៍ និងបានជម្រុញឱ្យមានកិច្ចសហការជាមួយបណ្តាប្រទេសពាក់ព័ន្ធ ទ្វេភាគី និងពហុភាគី ដើម្បីប្រឆាំងការជួញដូរមនុស្ស និងបានគិតគូជាពិសេសចំពោះការការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ ។
- ឆ្លងតាមការអនុវត្តន៍រយៈពេលមួយឆ្នាំកន្លងមកនេះ គិតចាប់តាំងពីថ្ងៃប្រើប្រាស់អនុក្រឹត្យលេខ១៦២អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិ ប.ជ.រ.ព.ភ និងសេចក្តីសម្រេចលេខ៩២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន ប.ជ.រ.ព.ភ រួចមក បណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គភាពពាក់ព័ន្ធ ទាំងក្នុងរដ្ឋាភិបាល ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទាំងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អន្តរជាតិ និងទីភ្នាក់ងារអង្គការសហប្រជាជាតិ បានរួមសហការគ្នាអនុវត្តភារកិច្ចយ៉ាងសកម្មទៅតាមគោលដៅគ្រោងទុក ។
- ឆ្នាំ២០១០នេះ យើងបានបំពេញនូវចន្លោះខ្វះខាត ដែលនៅសេសសល់ពីឆ្នាំ២០០៩ ដែលក្នុងនោះការបង្ក្រាបដើម្បីបង្ការភាពរងគ្រោះ និងការផ្តន្ទាទោស បានធ្វើឡើងច្រើនជាងឆ្នាំកន្លងទៅ និងបានពិនិត្យកែសម្រួល នូវបែបបទនីតិវិធី ដើម្បីធ្វើឱ្យមានការប្រែប្រួលប្រសើរឡើងនូវនីតិវិធីក្នុងការជួយជនរងគ្រោះ ការថែទាំ ការស្តារនីតិសម្បទាការធ្វើសមាហរណកម្ម និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ ដោយផ្តោតការយកចិត្តទុកដាក់លើស្ត្រី កុមារ និងបុរស ដែលត្រូវបានគេជួញដូរ និងកេងប្រវ័ញ្ចន៍តាមគ្រប់រូបភាព ។
- ក្រុមការងារទាំងប្រាំមួយ ដែលជាអ្នកអនុវត្តនូវយុទ្ធសាស្ត្រដ៏ទូលំទូលាយ និងជាកម្លាំងចម្រុះពហុវិស័យ បានពង្រឹងសមត្ថភាព និងកៀងគរការចូលរួម ដើម្បីធ្វើការងារយ៉ាងសកម្ម ទៅតាមជំនាញរៀងៗខ្លួន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ។
- ការបង្ក្រាបបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទឆ្នាំ២០១០ មានការថយចុះចំនួន**០៥**ករណី ស្មើនឹង**-៣.១២%** បើប្រៀបធៀបទៅឆ្នាំ២០០៩ តែការបង្ក្រាបនេះ មានករណីមួយចំនួនធ្វើឡើងដើម្បីសង្គ្រោះជនងាយរងគ្រោះមុនពេលត្រូវបានគេជួញដូរ ជាក់ស្តែងមាន **២២** ករណី ដែលសមត្ថកិច្ចយើងបានបង្ក្រាប និងសង្គ្រោះជនរងគ្រោះក្នុងពេលដែលជនសង្ស័យត្រៀមបញ្ជូនឆ្លងដែនដោយខុសច្បាប់ និងសង្គ្រោះជនរងគ្រោះចំនួន**៣០០**នាក់ ក្នុងនោះមានអនីតិជនចំនួន**៧៨**នាក់ ឱ្យរួចផុតពីការជួញដូរ និងកេងប្រវ័ញ្ចន៍ ។
- ចំណាត់ការរបស់តុលាការទៅលើជនល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស មានភាពរីកចម្រើនជាងបណ្តាឆ្នាំមុនៗ ជាក់ស្តែងឆ្នាំនេះសាលាដំបូងរាជធានី-ខេត្ត បានចាត់ការលើករណីជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទបានចំនួន **១៦៣**ករណី/**៩៧**ករណី ជនល្មើសចំនួន**២៤៩**នាក់/**១៤៦**នាក់ បើប្រៀបធៀបឆ្នាំ២០០៩ កើនឡើងចំនួន**៦៦**ករណី (ស្មើ**៦៨.០៤%**) បានផ្តន្ទាទោសជនល្មើស**២១៩**នាក់ ។
- ចំណាត់ការរបស់តុលាការទៅលើជនល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស មានភាពរីកចម្រើនជាងបណ្តាឆ្នាំមុនៗ ចំពោះករណីជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ។
- លើសពីនេះទៅទៀត គោលនយោបាយ "**ភូមិ-ឃុំ មានសុវត្ថិភាព**" របស់រាជរដ្ឋាភិបាល ដែលមានក្រសួងមហាផ្ទៃជាស្នូល គឺជាកម្លាំងចលករយ៉ាងសំខាន់ បំផុសឱ្យគ្រប់ស្ថាប័ន អង្គភាព សង្គមស៊ីវិល គណបក្សនយោបាយ និងសមត្ថកិច្ចជំនាញគ្រប់ផ្នែករួមដៃគ្នាបង្កើតជាសំណាញ់សុវត្ថិភាពមួយដ៏សក្តិសិទ្ធិ សម្រាប់ការពារប្រជាពលរដ្ឋពីភាពរងគ្រោះ និងកសាងសង្គមមួយដែលមានសុវត្ថិភាព ស្ថេរភាព សន្តិសុខ សណ្តាប់ធ្នាប់ និងមានការរីកចំរើន ។

**ខ. ចំណុចសេសសល់ និងភាពប្រឈម :**

កិច្ចផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចសហការរវាងបណ្តាដៃគូពាក់ព័ន្ធ រួមមានក្រសួង ស្ថាប័ន អង្គភាពនានាក្នុងរាជរដ្ឋាភិបាល និងបណ្តាអង្គការដៃគូក្នុងស្រុក អន្តរជាតិ ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលប្រទេសពាក់ព័ន្ធ ទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់ ។ ទោះបីជាយ៉ាងនេះក្តី ក៏ការជួញដូរមនុស្ស ដែលជាបទល្មើសឆ្លងដែន និងមានភាពស្មុគស្មាញ តម្រូវឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់បន្តកិច្ចខិតខំប្រឹងប្រែងប្រកបដោយសុឆន្ទៈ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ ។ ស្ថិតក្នុងល័ក្ខខ័ណ្ឌបែបនេះ ទាមទារឱ្យគិតគូរអំពីចំណុចជាអាទិភាពមួយចំនួនដែលចាំបាច់ត្រូវកែលំអឱ្យប្រសើរឡើង រួមមាន :

- សមត្ថភាពជំនាញ និងធនធានមួយចំនួនដែលចាំបាច់សម្រាប់ការអនុវត្តន៍ច្បាប់ នៅមានកម្រិត ដែលទាមទារឱ្យពង្រឹងបន្ថែមទៀត ទើបអាចឆ្លើយតបទៅនឹងសភាពការណ៍បទល្មើសបាន ។
- កិច្ចសហការពីអ្នកពាក់ព័ន្ធ ដែលរួមទាំងជនរងគ្រោះផង នៅមិនទាន់ឆ្លើយតបទាន់សភាពការណ៍ ។
- ដោយសារតែព័ត៌មាន និងការអប់រំពីកលល្បិច ជនខិលខូចមិនបានទូលំទូលាយ និងឱ្យចំក្រុមប្រជាជនគោលដៅ ទើបបានពួកឈ្មួញទុច្ចរិតដែលមានបណ្តាញពីជនបទដល់ទីក្រុង ប្រើគ្រប់មធ្យោបាយ និងចិត្តសាស្ត្រ បន្លំអូសទាញ បោកបញ្ឆោត ទិញទឹកចិត្តឱ្យស្ត្រី-កុមារ និងបុរសមួយចំនួនធ្លាក់ខ្លួនជាជនរងគ្រោះក្នុងការជួញដូរមនុស្ស ការកេងប្រវ័ញ្ចទីពលកម្ម និងការជួញដូរផ្លូវភេទដោយមិនដឹងខ្លួន និងបន្តស្វែងរកការធ្វើទេសន្តរប្រវេសន៍ការងារដោយប្រថុយប្រថាននៅក្នុងស្រុក និង ដោយខុសច្បាប់ទៅក្រៅប្រទេសបន្តទៀត ។
- ពលករទេសន្តរប្រវេសន៍ដែលឆ្លងដែនទៅធ្វើការងារតាមរដូវកាលនៅប្រទេសជាប់ព្រំដែន ទាមទារឱ្យមានយន្តការ និងនីតិវិធីច្បាស់លាស់ ដើម្បីគ្រប់គ្រង និងឆ្លើយតបទៅនឹងតម្រូវការរបស់ពលករ ។
- រចនាសម្ព័ន្ធនៃគណៈកម្មាធិការដឹកនាំ និងលេខាធិការដ្ឋាននៅថ្នាក់ក្រោមជាតិមួយចំនួនត្រូវការឱ្យរៀបចំឡើងវិញ និងត្រូវមានមន្ត្រីប្រចាំការនៅលេខាធិការដ្ឋាន ដើម្បីតាមដានការងារជាប្រចាំ ព្រមទាំងមានផែនការការងារ និងថវិកាសម្រាប់ការអនុវត្តន៍ភារកិច្ចឱ្យបានច្បាស់លាស់ ។
- អង្គការក្នុងស្រុក និងអន្តរជាតិមួយចំនួននៅមិនទាន់ចូលរួមពេញលេញក្នុងយន្តការ និងសកម្មភាពរួមនេះ ហើយព្យាយាមធ្វើសកម្មភាពដោយឡែក ដែលមិនឆ្លើយតបទៅនឹងគោលដៅនៃការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ។
- ដើម្បីធ្វើឱ្យគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល និងប្រព័ន្ធរកការងារស្របច្បាប់អាចអនុវត្តបានដោយជោគជ័យ ដើម្បីបង្កើនឱកាសការងារ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ចាំបាច់ណាស់ត្រូវពង្រឹងការតាមដានត្រួតពិនិត្យក្រុមហ៊ុនស្របច្បាប់ ដែលទទួលការអនុញ្ញាតឱ្យជ្រើសរើសពលករទៅបរទេសដើម្បីចៀសវាងភាពមិនប្រក្រតី ដែលអាចកើតមានឡើង ។
- កិច្ចសហការក្នុងចំណោមក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធ ចាំបាច់ត្រូវពង្រឹងបន្ថែមទៀត ដើម្បីធ្វើការត្រួតពិនិត្យក្រុមហ៊ុនជ្រើសរើសពលករ និងជំរុញឱ្យអនុវត្តវិធានការ គោលការណ៍ណែនាំ គោលនយោបាយ និងច្បាប់ផ្សេងៗ ព្រមជាមួយនឹងការចាត់វិធានការជាក់ស្តែង ដោយអប់រំ ព្រមាន និងផ្តន្ទាទោសតាមច្បាប់ចំពោះភ្នាក់ងារក្រុមហ៊ុន ឬ អ្នកប្រព្រឹត្ត ល្មើសផ្ទុយពីគោលការណ៍ណែនាំនិងច្បាប់ទាំងនោះ ។

## IV. __ទិសដៅសំរាប់ ឆ្នាំ២០១១__ :

១. លេខាធិការដ្ឋាន ចាត់ចែងផ្សព្វផ្សាយរបាយការណ៍ជាតិ ស្តីពីលទ្ធផលការងារប្រឆាំងការជួញដូរមនុស្ស ការរត់ពន្ធការធ្វើអាជីវកម្មពលកម្ម និងអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ឆ្នាំ២០១០ និងទិសដៅឆ្នាំ២០១១ ។

២. ជម្រុញការអនុម័តលើផែនការសកម្មភាពជាតិ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ (២០១១-២០១៣) ដោយរួមបញ្ចូលផែនការប្រឆាំងការជួញដូរមនុស្សតាមបណ្តាក្រសួងស្ថាប័ន និងជម្រុញការកៀងគរធនធានគាំទ្រសកម្មភាព ព្រមទាំងរៀបចំផែនការសកម្មភាពរយៈពេលខ្លី និងផែនការថវិកាសម្រាប់លេខាធិការដ្ឋានថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីស្នើបញ្ចូលទៅក្នុងកញ្ចប់ថវិកាជាតិ ។

៣. ពង្រឹងវិធានការជាក់ស្តែង និងការចូលរួមសហការពីអ្នកពាក់ព័ន្ធ គ្រប់ផ្នែក គ្រប់ថ្នាក់ តាមការចាំបាច់ ដែលរួមទាំងជនរងគ្រោះផង ។

៤. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងយុត្តិធម៌ ជម្រុញការរៀបចំបទដ្ឋានគតិយុត្តិ ដើម្បីផ្តល់នីតិសម្បទាដល់មណ្ឌលថែទាំជនរងគ្រោះ ។

៥. ពង្រឹងរបៀបរបបការងារលេខាធិការដ្ឋានគ្រប់ថ្នាក់ ឱ្យអនុវត្តតួនាទីភារកិច្ចប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

៦. បង្កើន និងពង្រឹងវិធានការបង្ការ-ទប់ស្កាត់ ដោយបន្តយកចិត្តទុកដាក់ជម្រុញការអប់រំផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការយល់ដឹងជាសាកល អំពីច្បាប់ គោលនយោបាយ ផែនការស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ អំពីល្បិចកល ឧបាយកល និងលក្ខណៈរបស់ជនល្មើស ផលប៉ះពាល់ និងភាពរងគ្រោះផ្សេងៗដោយការធ្វើចំណាកស្រុកខុសច្បាប់ ឱ្យដល់ប្រជាពលរដ្ឋដែលជាក្រុមងាយរងគ្រោះ ក្នុងនោះមានជាអាទិ៍ ក្រុមមនុស្សដែលកំពុងស្វែងរកការងារ ក្រុមយុវជន យុវនារីដែលពេញកម្លាំងនិងចង់ស្វែងរកការរស់នៅទីប្រជុំជន ឬនៅក្រៅប្រទេស សិស្សានុសិស្ស កម្មករ កម្មការនី នារីលក់ស្រាបៀរ និងនារីបម្រើតាមភោជនីយដ្ឋាន ក្លឹបម៉ាស្សា ក្លឹបរាត្រី.... ។ល។

៧. ក្រសួងទេសចរណ៍ បន្តផ្សព្វផ្សាយខ្លឹមសារបង្ការ សម្រាប់ជនបរទេស "Join us to Protect our Children, Welcome Responsible Tourists" តាមអ៊ីម៉ែកកង់បី និងបន្តចែកចាយសៀវភៅ ស្តីពីការយល់ដឹង និងការការពារខ្លួនពីទេសចរណ៍ផ្លូវភេទ តាមសាលារៀន និងសហគមន៍នៅបណ្តារាជធានី-ខេត្ត ។ បន្តផ្សព្វផ្សាយស្តីពី "ការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍" "ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងច្បាប់ស្តីពីទេសចរណ៍" ជូនដល់បុគ្គលិកបម្រើការងារក្នុងសណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋាន នៅតាមគោលដៅក្នុងរាជធានី និងបណ្តាខេត្ត ។

៨. ពង្រឹងការតាមដាន និងស្វែងរកយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងទេសន្តរប្រវេសន៍ ទាំងក្នុងស្រុក និងក្រៅប្រទេស ដើម្បីធានាការគោរពសិទ្ធិ និងផលប្រយោជន៍របស់ពលករចំណាកស្រុក ។

៩. បង្កើនការចុះត្រួតពិនិត្យក្រុមហ៊ុនជ្រើសរើសពលករឱ្យអនុវត្តវិធានការ គោលការណ៍ណែនាំ គោលនយោបាយ និងច្បាប់ផ្សេងៗ ព្រមជាមួយនឹងការចាត់វិធានការជាក់ស្តែង ដោយអប់រំ ព្រមាន និងផ្តន្ទាទោសតាមច្បាប់ចំពោះភ្នាក់-ងារក្រុមហ៊ុន ឬ អ្នកប្រព្រឹត្តល្មើសផ្ទុយពីគោលការណ៍ណែនាំនឹងច្បាប់ទាំងនោះ ដោយមានការចូលរួមពីក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធ ។

១០. បន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ ដោយបង្កើនកិច្ចសហការល្អជាមួយបណ្តាអង្គការសង្គមស៊ីវិលក្នុងស្រុក និងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធរៀបចំឯកសារ និងបន្តបើកវគ្គបណ្តុះបណ្តាល ស្តីពីគោលការណ៍ណែនាំការអនុវត្តច្បាប់ ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងជំនាញប្រឆាំងការជួញដូរមនុស្សដល់គ្រូបង្គោល មន្ត្រីអនុវត្តច្បាប់ និងស្ថាប័នពាក់ព័ន្ធ ។

១១. ក្រុមការងារអនុវត្តច្បាប់ ពង្រឹងមន្ត្រីសមត្ថកិច្ចអនុវត្តច្បាប់ឱ្យជម្រុញប្រតិបត្តិការស៊ើបអង្កេត និងបង្ក្រាបដោយយកចិត្តទុកដាក់ទៅលើ :

- ការពង្រឹងសមត្ថកិច្ចការពារព្រំដែន ឱ្យយកចិត្តទុកដាក់អនុវត្តកិច្ចប្រតិបត្តិការស៊ើបអង្កេត និងបង្ក្រាបបទល្មើសរត់ពន្ធមនុស្ស និងការជួញដូរមនុស្សឆ្លងកាត់ព្រំដែនខុសច្បាប់ ។
- ជម្រុញការបង្ក្រាបអំពើនាំមនុស្សចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន រកការងារធ្វើតាមរយៈក្រុមហ៊ុនជ្រើសរើសពលករ និងភាពមិនប្រក្រតីដែលកើតឡើងដោយការក្លែងបន្លំ ។
- បន្តស្រាវស្រាវករណីអាពាហ៍ពិពាហ៍ជាមួយជនបរទេស ដែលសង្ស័យថាជាករណីក្លែងបន្លំ ដើម្បីកេងប្រវ័ញ្ចផ្លូវភេទ ឬជួញដូរមនុស្ស ដែលកើតមាននៅតំបន់មួយចំនួនតាមបណ្តារាជធានី-ខេត្ត ។
- បន្តធ្វើការសម្អាតទីស្រាវជ្រាវ រកឱ្យឃើញមេខ្យល់នាំពលករឆ្លងដែនខុសច្បាប់ទៅធ្វើការនៅប្រទេសថៃ និងបណ្តាប្រទេសផ្សេងៗទៀត ។
- បន្តវិធានការជំនាញរបស់នគរបាល ចំពោះគោលដៅ និងមុខសញ្ញាប្រព្រឹត្តល្មើសដែលមានកន្លងមកសំដៅ

បំបាត់ប្រសិទ្ធភាពបទល្មើស និងមិនហ៊ានប្រព្រឹត្តបទល្មើស ។

- បន្តទប់ស្កាត់ រឹបអូស និងបង្ក្រាបហ៊ឹងម៉ាត់ការបញ្ចាំងរឿងអាសអាភាស ការបិទរូបភាព ការចែកចាយរូបភាពអាសអាភាស ការលក់ឌីស កាសែតរូបភេទនៅតាមមូលដ្ឋាន ហាងលក់គេសជ្ជៈ និងទីផ្សារនានា ដោយប្រគល់ ឱ្យនគរបាលមូលដ្ឋានទទួលខុសត្រូវក្នុងភូមិសាស្ត្ររបស់ខ្លួន។
- អនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់ លើបទល្មើសសញ្ចារកម្ម និងបទល្មើសផ្លូវភេទផ្សេងៗទៀតឱ្យបានហ៊ឹងម៉ាត់ ។

១២. ក្រសួងយុត្តិធម៌ បន្តជម្រុញការផ្តន្ទាទោសករណីជួញដូរមនុស្សគ្រប់រូបភាពឱ្យបានឆាប់ ត្រឹមត្រូវ និងល្អប្រសើរ ព្រមទាំងជម្រុញការកសាងច្បាប់ ស្តីពីការបង្ក្រាបអំពើរត់ពន្ធមនុស្ស ឱ្យបានឆាប់ ។

១៣. ក្រុមការងារខមមីតកម្ពុជា បន្តកិច្ចសហការជាមួយអង្គការ UNIAP ដើម្បីជម្រុញការអនុវត្តផែនការសកម្មភាពអនុតំបន់មេគង្គប្រឆាំងអំពើជួញដូរមនុស្សលើកទី៣ (២០១១-២០១៣) ។

១៤. ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ ជម្រុញការអនុវត្តអនុស្សរណៈកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងបង្កើតថ្មីបន្ថែមតាមការចាំបាច់ ពិសេស MOU ជាមួយម៉ាឡេស៊ី និងផ្តួចផ្តើមកិច្ចព្រមព្រៀងជាមួយប្រទេសពាក់ព័ន្ធដទៃទៀតតាមការចាំបាច់ និងបង្កើនកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរព័ត៌មាន និងនីតិវិធីជំនួយផ្នែកច្បាប់ឱ្យគ្នាទៅវិញទៅមកក្នុងរឿងក្តីជួញដូរមនុស្ស រវាងប្រទេសក្នុងតំបន់ ។

១៥. ជម្រុញសកម្មភាពត្រួតពិនិត្យរបស់គណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ គ្រប់ថ្នាក់ ។

១៦. ពង្រឹងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ និងពង្រីកការចូលរួមពីអង្គការសង្គមស៊ីវិល និងផ្នែកពាក់ព័ន្ធដទៃទៀត និងធ្វើឱ្យច្បាស់លាស់ និងតម្លាភាពក្នុងការចូលរួម គាំទ្រសកម្មភាពប្រឆាំងការជួញដូរមនុស្សនៅព្រះរាជាណាចក្រកម្ពុជា ។

១៧. សម្របសម្រួលការអនុវត្តភារកិច្ច និងរបាយការណ៍ រវាងគណៈកម្មាធិការ ប.ជ.រ.ព.ភ និងគណៈបញ្ជាការឯកភាពរាជធានី-ខេត្ត ដែលកំពុងអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព ដើម្បីប្រសិទ្ធភាពការងារ និងឱ្យមានទិន្នន័យរលូនជាមួយគ្នា ។

រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ប្រធានគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ**

ស ខេង

**ចម្លងជូន :**

- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី និងទីស្តីការគណៈរដ្ឋមន្ត្រី
- សមាជិកគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ
- សមាជិកលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ
- គណៈកម្មាធិការដឹកនាំ និងលេខាធិការដ្ឋាន ប.ជ.រ.ព.ភ ថ្នាក់រាជធានី ខេត្ត
- អង្គការដៃគូអភិវឌ្ឍន៍

"ដើម្បីជូនជ្រាប"

- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ

១- តារាងទិន្នន័យបទល្មើស ដែលមានចែងក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរ និងការធ្វើអាជីវកម្មផ្លូវភេទ

២- អនុក្រឹត្យ លេខ ១៦២ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីកម្មផ្លូវភេទលើស្ត្រី និងកុមារ (ប.ជ.រ.ព.ភ)

៣- សេចក្តីសម្រេច លេខ ៩២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបការជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្ម ពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ (ប.ជ.រ.ព.ភ)

៤- សេចក្តីណែនាំលេខ ០០៩ សណន ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១០ នៃអគ្គស្នងការនគរបាលជាតិ ក្រសួងមហាផ្ទៃ ស្តីពីការអនុវត្តកិច្ចប្រតិបត្តិការ សង្គ្រោះជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និង/ឬ កាធ្វើអាជីវកម្មផ្លូវភេទ នៅតាមបណ្តាទីតាំងដែលបានកំណត់

៥- សេចក្តីណែនាំលេខ ០០៥ ស.ណ.ន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ នៃអគ្គស្នងការនគរបាលជាតិ ក្រសួងមហាផ្ទៃ ស្តីពីការបង្ការបង្ក្រាបការប្រើប្រាស់គ្រឿងញៀនតាមកន្លែងកម្សាន្ត ការជួញដូរមនុស្ស និងការលេងភ្នាល់ល្បែងគ្មានការអនុញ្ញាត

៦- លិខិតលេខ ១៦៣០ កយរក១០ ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១០ ចេញពីទីស្តីការក្រសួងយុត្តិធម៌ ឱ្យសាលាដំបូងនិងអយ្យការ រាជធានី-ខេត្តចូលរួមសហការជាមួយក្រុមការងារគ្រប់គ្រង និងវិភាគ សំណុំរឿងក្តីជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ

៧- សេចក្តីសម្រេចលេខ ១២ កយសសរ១០ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ២០១០ បង្កើតក្រុមការងារ គ្រប់គ្រង និងវិភាគសំណុំ រឿងក្តីជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

៨- លិខិតលេខ ១៣០៣ កយរប១០ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០១០ ឱ្យសាលាដំបូង និង អយ្យការរាជធានី-ខេត្ត ប្រើលេខកូដដាក់លើសំណុំរឿងពាក់ព័ន្ធនឹងករណីជួញដូរមនុស្ស និងការធ្វើ អាជីវកម្មផ្លូវភេទ ដើម្បីឱ្យស៊ើសង្វាក់គ្នាជាមួយសំណុំរឿង ដែលបញ្ជូនមកពីនគរបាលយុត្តិធម៌

៩- លិខិតលេខ ១១៩១ កយរប.១០ ចេញពីទីស្តីការក្រសួងយុត្តិធម៌ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០១០ ណែនាំឱ្យសាលាដំបូង និងអយ្យការរាជធានី-ខេត្ត ស្រង់ទិន្នន័យរឿងក្តី រំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ ដាក់បញ្ចូលក្នុងទម្រង់ស្រង់ទិន្នន័យរឿងក្តីពាក់ព័ន្ធនឹងករណីជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ

១០- សេចក្តីជំរាបជូន លេខ២៦៤៧ប.ក/អ.ក ចេញពី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការ ណែនាំតម្រង់ទិសដៅការងារជ្រើសរើសពលករខ្មែរទៅធ្វើការនៅបរទេស ចំនួន**១០**ចំណុចដល់ ក្រុមហ៊ុននិយោជក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ត

លេខាធិការដ្ឋាន

# តារាងទិន្នន័យបទល្មើស
## ដែលមានចែងក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
## (២៦/១២/០៩ ដល់ ២៥/១២/១០)

| ល.រ | រាជធានី-ខេត្ត | បង្ក្រាបសរុប | | | មាត្រា០៨ ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | | | | | | មាត្រា១០ ការនាំយកចេញដោយមិនស្របច្បាប់ ដោយមានគោលដៅ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណីបង្ក្រាប | ជនរងគ្រោះ | ជនល្មើស | ករណីបង្ក្រាប | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18 | ជនល្មើស ប | ជនល្មើស ស | ករណីបង្ក្រាប | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18 | ជនល្មើស ប | ជនល្មើស ស |
| 1 | នាយកដ្ឋាន | 6 | 40 | 8 | | | | | | | | | | | | |
| 2 | រាជធានីភ្នំពេញ | 46 | 207 | 63 | 1 | 1 | | | | 1 | | | | | | |
| 3 | សៀមរាប | 23 | 50 | 37 | | | | | | | 1 | | 2 | | | 1 |
| 4 | បន្ទាយមានជ័យ | 19 | 70 | 27 | | | | | | | 5 | | 6 | 23 | 5 | 4 |
| 5 | កណ្តាល | 8 | 47 | 11 | 1 | 1 | | | 1 | | | | | | | |
| 6 | បាត់ដំបង | 9 | 77 | 17 | | | | | | | | | | | | |
| 7 | ព្រះសីហនុ | 7 | 22 | 7 | | | | | | | | | | | | |
| 8 | កំពង់ឆ្នាំង | 5 | 7 | 7 | | | | | | | | | | | | |
| 9 | កំពង់ចាម | 9 | 39 | 15 | 1 | | 1 | | 1 | | | | | | | |
| 10 | កំពង់ស្ពឺ | 1 | 2 | 1 | | | | | | | | | | | | |
| 11 | ព្រះវិហារ | | | | | | | | | | | | | | | |
| 12 | កំពត | 3 | 1 | 3 | 1 | | | | 1 | | 1 | | | | 1 | |
| 13 | ស្ទឹងត្រែង | 2 | 20 | 2 | | | | | | | | | | | | |
| 14 | កែប | | | | | | | | | | | | | | | |
| 15 | ក្រចេះ | | | | | | | | | | | | | | | |
| 16 | តាកែវ | 3 | 5 | 3 | | | | | | | | | | | | |
| 17 | ប៉ៃលិន | | | | | | | | | | | | | | | |
| 18 | ពោធិ៍សាត់ | 1 | 25 | 1 | | | | | | | | | | | | |
| 19 | ព្រៃវែង | | | | | | | | | | | | | | | |
| 20 | ស្វាយរៀង | 5 | 18 | 8 | | | | | | | | | | | | |
| 21 | រតនៈគិរី | | | | | | | | | | | | | | | |
| 22 | មណ្ឌលគិរី | | | | | | | | | | | | | | | |
| 23 | កោះកុង | 2 | 7 | 2 | | | | | | | | | | | | |
| 24 | កំពង់ធំ | 1 | | 1 | | | | | | | | | | | | |
| 25 | ឧត្តរមានជ័យ | | | | | | | | | | | | | | | |
| 26 | PM ផ្ទៃប្រទេស | 10 | 49 | 29 | | | | | | | 1 | | 2 | 11 | 3 | |
| | **សរុប** | **160** | **686** | **242** | 4 | 2 | 1 | | 3 | 1 | 8 | | 10 | 34 | 9 | 5 |

| ល.រ | រាជធានី-ខេត្ត | មាត្រា១១ ការនាំយកចេញដោយមិនស្របច្បាប់ សម្រាប់នាំឆ្លងដែន | | | | | | មាត្រា១២ ការជ្រើសរើសដោយមិនស្របច្បាប់ សម្រាប់កេងប្រវ័ញ្ច | | | | | | មាត្រា១៤ អំពើលក់-ដូរមនុស្ស | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណីបង្ក្រាប | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18 | ជនល្មើស ប | ជនល្មើស ស | ករណីបង្ក្រាប | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18 | ជនល្មើស ប | ជនល្មើស ស | ករណីបង្ក្រាប | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18 | ជនល្មើស ប | ជនល្មើស ស |
| 1 | នាយកដ្ឋាន | | | | | | | | | | | | | | | | | | |
| 2 | រាជធានីភ្នំពេញ | 1 | 3 | 10 | 47 | 1 | | | | | | | | | | | | | |
| 3 | សៀមរាប | | | | | | | | | | | | | 1 | | 1 | | 1 | 1 |
| 4 | បន្ទាយមានជ័យ | 9 | 1 | 3 | 30 | 11 | 2 | | | | | | | 1 | 1 | | | | 1 |
| 5 | កណ្តាល | | | | | | | | | | | | | 1 | | | 1 | | 1 |
| 6 | បាត់ដំបង | 5 | 3 | 5 | 43 | 9 | 1 | | | | | | | | | | | | |
| 7 | ព្រះសីហនុ | | | | | | | | | | | | | 1 | 1 | | | 1 | |
| 8 | កំពង់ឆ្នាំង | 1 | | 1 | 1 | | 1 | | | | | | | 1 | 1 | | | | 3 |
| 9 | កំពង់ចាម | | | | | | | | | | | | | | | | | | |
| 10 | កំពង់ស្ពឺ | | | | | | | | | | | | | | | | | | |
| 11 | ព្រះវិហារ | | | | | | | | | | | | | | | | | | |
| 12 | កំពត | | | | | | | | | | | | | | | | | | |
| 13 | ស្ទឹងត្រែង | | | | | | | | | | | | | | | | | | |
| 14 | កែប | | | | | | | | | | | | | | | | | | |
| 15 | ក្រចេះ | | | | | | | | | | | | | | | | | | |
| 16 | តាកែវ | 1 | | | | 1 | | | | | | | | | | | | | |
| 17 | ប៉ៃលិន | | | | | | | | | | | | | | | | | | |
| 18 | ពោធិ៍សាត់ | 1 | | 1 | 24 | 1 | | | | | | | | | | | | | |
| 19 | ព្រៃវែង | | | | | | | | | | | | | | | | | | |
| 20 | ស្វាយរៀង | 2 | 4 | 1 | 11 | 4 | | | | | | | | 1 | | | | 1 | 1 |
| 21 | រតនៈគិរី | | | | | | | | | | | | | | | | | | |
| 22 | មណ្ឌលគិរី | | | | | | | | | | | | | | | | | | |
| 23 | កោះកុង | | | | | | | | | | | | | | | | | | |
| 24 | កំពង់ធំ | 1 | | | | 1 | | | | | | | | | | | | | |
| 25 | ឧត្តរមានជ័យ | | | | | | | | | | | | | | | | | | |
| 26 | PM ផ្ទៃប្រទេស | | | | | | | | | | | | | | | | | | |
| | **សរុប** | 21 | 11 | 21 | 156 | 28 | 4 | | | | | | | 6 | 3 | 1 | 1 | 3 | 7 |

| ល.រ | រាជធានី-ខេត្ត | មាត្រា១៥ អំពើលក់-ដូរមនុស្ស ដោយមានគោលដៅ | | | | | | មាត្រា១៦ អំពើលក់-ដូរមនុស្ស សម្រាប់នាំឆ្លងដែន | | | | | | មាត្រា១៧ ការដឹកជញ្ជូន ដោយមានគោលដៅ | | | | | | មាត្រា១៨ អំពើនាំឆ្លងដែន | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណីបង្ក្រាប | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18 | ជនល្មើស ប | ជនល្មើស ស | ករណីបង្ក្រាប | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18 | ជនល្មើស ប | ជនល្មើស ស | ករណីបង្ក្រាប | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18 | ជនល្មើស ប | ជនល្មើស ស | ករណីបង្ក្រាប | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18 | ជនល្មើស ប | ជនល្មើស ស |
| 1 | នាយកដ្ឋាន | | | | | | | | | | | | | | | | | | | | | | | | |
| 2 | រាជធានីភ្នំពេញ | | | | | | | 1 | | | 2 | 1 | | | | | | | | | | | | | |
| 3 | សៀមរាប | 2 | | 2 | | | 4 | 1 | | | | 1 | | | | | | | | | | | | | |
| 4 | បន្ទាយមានជ័យ | | | | | | | | | | | | | | | | | | | | | | | | |
| 5 | កណ្តាល | | | | | | | | | | | | | | | | | | | | | | | | |
| 6 | បាត់ដំបង | | | | | | | | | | | | | | | | | | | | | | | | |
| 7 | ព្រះសីហនុ | | | | | | | | | | | | | | | | | | | | | | | | |
| 8 | កំពង់ឆ្នាំង | | | | | | | | | | | | | | | | | | | | | | | | |
| 9 | កំពង់ចាម | | | | | | | | | | | | | | | | | | | | | | | | |
| 10 | កំពង់ស្ពឺ | | | | | | | | | | | | | | | | | | | | | | | | |
| 11 | ព្រះវិហារ | | | | | | | | | | | | | | | | | | | | | | | | |
| 12 | កំពត | | | | | | | | | | | | | | | | | | | | | | | | |
| 13 | ស្ទឹងត្រែង | | | | | | | | | | | | | | | | | | | 2 | | 5 | 15 | 1 | 1 |
| 14 | កែប | | | | | | | | | | | | | | | | | | | | | | | | |
| 15 | ក្រចេះ | | | | | | | | | | | | | | | | | | | | | | | | |
| 16 | តាកែវ | | | | | | | | | | | | | | | | | | | | | | | | |
| 17 | ប៉ៃលិន | | | | | | | | | | | | | | | | | | | | | | | | |
| 18 | ពោធិ៍សាត់ | | | | | | | | | | | | | | | | | | | | | | | | |
| 19 | ព្រៃវែង | | | | | | | | | | | | | | | | | | | | | | | | |
| 20 | ស្វាយរៀង | | | | | | | | | | | | | | | | | | | | | | | | |
| 21 | រតនៈគិរី | | | | | | | | | | | | | | | | | | | | | | | | |
| 22 | មណ្ឌលគិរី | | | | | | | | | | | | | | | | | | | | | | | | |
| 23 | កោះកុង | | | | | | | | | | | | | | | | | | | | | | | | |
| 24 | កំពង់ធំ | | | | | | | | | | | | | | | | | | | | | | | | |
| 25 | ឧត្តរមានជ័យ | | | | | | | | | | | | | | | | | | | | | | | | |
| 26 | PM ផ្ទៃប្រទេស | | | | | | | | | | | | | | | | | | | 1 | | | | 1 | |
| | **សរុប** | 2 | | 2 | | | 4 | 2 | | | 2 | 2 | | | | | | | | 3 | | 5 | 15 | 2 | 1 |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៦២ ... អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការបង្កើតគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ (ប.ជ.រ.ព.ភ)

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៦/០០៤ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃពិធីសារស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងបទឧក្រិដ្ឋឆ្លងដែនដែលមានអង្គការចាត់តាំង
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## សម្រេច

**មាត្រា ១.** – ត្រូវបានបង្កើតគណៈកម្មាធិការជាតិដឹកនាំការបង្រ្កាបអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្រ្តី និងកុមារ ហៅកាត់ថា "ប.ជ.រ.ព.ភ" ។

**មាត្រា ២.** – គណៈកម្មាធិការជាតិដឹកនាំការបង្រ្កាបអំពើជួញដូរមនុស្ស ការរត់ពន្ធការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្រ្តីនិងកុមារ ប.ជ.រ.ព.ភ មានសមាសភាព ដូចតទៅ :

១-រដ្ឋមន្រ្តីក្រសួងមហាផ្ទៃ ប្រធាន

២-រដ្ឋមន្រ្តីក្រសួងកិច្ចការនារី អនុប្រធាន

៣-រដ្ឋមន្រ្តីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុប្រធាន

៤-រដ្ឋមន្រ្តីក្រសួងយុត្តិធម៌ អនុប្រធាន

៥-រដ្ឋមន្រ្តីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុប្រធាន

៦-រដ្ឋមន្រ្តីក្រសួងទេសចរណ៍ សមាជិក

៧-រដ្ឋមន្រ្តីក្រសួងសុខាភិបាល សមាជិក

៨-រដ្ឋមន្រ្តីក្រសួងអប់រំ យុវជន និងកីឡា សមាជិក

៩-រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្រ្តី ០១រូប សមាជិក

១០-រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ០១រូប (ទទួលបន្ទុកជាប្រធានលេខាធិការដ្ឋាន) សមាជិកអចិន្រ្តៃយ៍

១១-រដ្ឋលេខាធិការក្រសួងការពារជាតិ ០១រូប សមាជិក

១២-រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ០១រូប សមាជិក

១៣-រដ្ឋលេខាធិការក្រសួងព័ត៌មាន ០១រូប សមាជិក

១៤-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១រូប សមាជិក

១៥-រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ០១រូប សមាជិក

១៦-រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ០១រូប សមាជិក

១៧-អគ្គស្នងការ នគរបាលជាតិ　　　　　　　　　　　　　　　　　　សមាជិក

១៨-មេបញ្ជាការ កងរាជអាវុធហត្ថលើផ្ទៃប្រទេស　　　　　　　　　　　សមាជិក។

**មាត្រា ៣.-** គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ គឺជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងកិច្ចការប្រយុទ្ធប្រឆាំងអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស ការធ្វើ អាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ និងមានភារកិច្ចដូចខាងក្រោម :

- ដឹកនាំសម្របសម្រួលជាមួយក្រសួង ស្ថាប័នដៃគូ និងបណ្តាប្រទេសពាក់ព័ន្ធ សំដៅការពារប្រជាពលរដ្ឋ ជាពិសេសស្ត្រី និងកុមារ ឱ្យរួចផុតពីអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្ម និងអាជីវកម្មផ្លូវភេទ
- ជាបញ្ជាការផ្ទាល់លើលេខាធិការដ្ឋានក្នុងការត្រួតពិនិត្យ វាយតម្លៃសភាពការណ៍ ការអនុវត្តន៍ផែនការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ របស់ក្រុមការងារបច្ចេកទេសទាំង ០៦ (ប្រាំមួយ) គណៈបញ្ជាការឯកភាពរាជធានី និងខេត្តទាំងអស់
- ពិនិត្យ សម្រេចលើរបាយការណ៍ដែលបានដាក់ជូនដោយលេខាធិការដ្ឋាន ដើម្បីដាក់ជូនរាជរដ្ឋាភិបាល
- ពិនិត្យ ដោះស្រាយសំណូមពរ និងអនុសាសន៍នានា ផ្តល់មតិណែនាំ ដឹកនាំ ដើម្បីឱ្យលេខាធិការដ្ឋាន និងក្រុមការងារបច្ចេកទេសទាំងអស់អនុវត្ត និងចាត់វិធានការទៅតាមមុខសញ្ញារៀងៗខ្លួន
- ណែនាំ និងជំរុញគណៈបញ្ជាការឯកភាពរាជធានី-ខេត្ត អាជ្ញាធរមានសមត្ថកិច្ច ក្រសួង ស្ថាប័នពាក់ព័ន្ធ ឱ្យពង្រឹងការយកចិត្តទុកដាក់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ
- ដាក់វិធានការដើម្បីជួយសង្គ្រោះ ការពារ លើកកម្ពស់គុណភាពសេវានៃការងារស្តារ-នីតិសម្បទា ធ្វើសមាហរណកម្ម និងមាតុភូមិនិវត្តន៍ជនរងគ្រោះ ជាពិសេសស្ត្រី និងកុមារឱ្យបានល្អប្រសើរ

- លុបបំបាត់និទណ្ឌភាព ដោយជំរុញឱ្យមានការស៊ើបអង្កេត ការផ្តន្ទាទោសមេក្លោង និង ជនល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ
- ជំរុញផ្សព្វផ្សាយដើម្បីបង្កើនការជឿទុកចិត្តពីប្រជាពលរដ្ឋ ជាពិសេសពីជនរងគ្រោះលើសេវាសាធារណៈ និងដើម្បីបង្កើនការចូលរួមអនុវត្តច្បាប់
- ទទួលខុសត្រូវដឹកនាំសម្របសម្រួលក្រុមការងារដែលពាក់ព័ន្ធ និងជាអ្នកជំរុញសកម្មភាពក្នុងសាមីក្រសួង ក្នុងការអនុវត្តន៍ផែនការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ព្រមទាំងធ្វើរបាយការណ៍ឱ្យបានទៀងទាត់ផ្ញើមកលេខាធិការដ្ឋាន
- គណៈកម្មាធិការជាតិដឹកនាំ ជួបប្រជុំគ្នាវៀងរាល់ត្រីមាស ដើម្បីផ្លាស់ប្តូរយោបល់លើរបាយការណ៍ដែលរៀបចំដោយលេខាធិការដ្ឋាន ដោះស្រាយសំណូមពរ ពិនិត្យអនុសាសន៍ទាំងឡាយដែលបានស្នើឡើង វាយតម្លៃសភាពការណ៍ កំណត់ទិសដៅ និងយុទ្ធសាស្ត្របន្ត
- ក្នុងករណីចាំបាច់ ប្រធានអាចកោះអញ្ជើញសមាជិកជួបប្រជុំវិសាមញ្ញបាន ។ ក្នុងកិច្ចប្រជុំនីមួយៗ បើសមាជិកណាម្នាក់ជាប់រវល់ អាចចាត់តាំងតំណាងជាមន្ត្រីជាន់ខ្ពស់ដែលមានសិទ្ធិសម្រេចឱ្យមកចូលរួមប្រជុំជំនួសបាន
- ធ្វើរបាយការណ៍ទៀងទាត់ជូនប្រមុខរាជរដ្ឋាភិបាល អំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ
- គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ មានសិទ្ធិប្រើប្រាស់រូបសញ្ញា និងត្រាដោយ ខ្សែករបស់គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ។

**មាត្រា ៤.** – គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ មានលេខាធិការដ្ឋានមួយ ដែលមាននាយកដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃក្រសួងមហាផ្ទៃ ជាសេនាធិការ អមដោយក្រុមការងារបច្ចេកទេសចម្រុះស្ថាប័ន ចំនួន០៦ (ប្រាំមួយ) និង

គណៈកម្មាធិការ ប.ជ.រ.ព.ភ ថ្នាក់រាជធានី និងខេត្តទាំងអស់ដែលមានភារកិច្ច ធ្វើឱ្យសម្រេចនូវផែនការប្រយុទ្ធប្រឆាំង នឹងអំពើ ជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្ម លើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារនៅព្រះរាជាណាចក្រកម្ពុជា ។ លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ដឹកនាំដោយប្រធានមួយរូប ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ អមដោយអនុប្រធានមួយចំនួនតាមការចាំបាច់ ។ ប្រធានក្រុមការងារបច្ចេកទេសទាំងប្រាំមួយ គឺជាសមាជិកលេខាធិការដ្ឋាន ។

លេខាធិការដ្ឋាននេះ មានសិទ្ធិប្រើប្រាស់មន្ត្រីជំនាញក្នុងស្ថាប័នសាមី និងអាចស្នើសុំជួលអ្នកជំនាញការផ្នែកបច្ចេកទេស តាមការចាំបាច់ ដើម្បីជាជំនួយក្នុងការរៀបចំផែនការ ការពង្រឹងសមត្ថភាពក្រុមការងារ ការបង្កើតសម្ភារៈសម្រាប់ផ្សព្វផ្សាយ ការបណ្តុះបណ្តាល ការត្រួតពិនិត្យការវាយតម្លៃ ការប្រមូលរបាយការណ៍បូកសរុប និងការចងក្រងឯកសារជាដើម ។

**មាត្រា ៥.–** លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ដែលជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ

លេខាធិការដ្ឋាននេះមានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ ដែលបានមកពីប្រភពហិរញ្ញប្បទាន សហប្រតិបត្តិការអន្តរជាតិ និងពីប្រភពផ្សេងៗទៀត សម្រាប់បំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

**មាត្រា ៦.–** ក្រុមការងារទាំងប្រាំមួយ មានសមាសភាពជាអន្តរក្រសួង និងមានតំណាងអង្គការសង្គមស៊ីវិល ដែលធ្វើការពាក់ព័ន្ធតាមជំនាញចូលរួម ។ ក្រុមការងារទាំងប្រាំមួយគឺ :

១. ក្រុមការងារទប់ស្កាត់

២. ក្រុមការងារការពារ ស្តារនីតិសម្បទា សមាហរណកម្ម និងមាតុភូមិនិវត្តន៍

៣. ក្រុមការងារអនុវត្តច្បាប់

៤. ក្រុមការងារកិច្ចការយុត្តិធម៌

៥. ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ

៦. ក្រុមការងារកិច្ចការកុមារ ។

មាត្រា ៧.– គណៈកម្មាធិការរាជធានី-ខេត្ត ប.ជ.រ.ព.ភ មានរចនាសម្ព័ន្ធកំណត់ដោយគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ដែលត្រូវដឹកនាំដោយអភិបាលរាជធានី-ខេត្ត និងមានលេខាធិការដ្ឋានមួយ មានទីតាំងស្ថិតក្នុងសាលារាជធានី-ខេត្ត អមដោយក្រុមការងារអន្តរមន្ទីរ ដែលទទួលបន្ទុកអនុវត្តភារកិច្ចពាក់ព័ន្ធជំនាញទាំងប្រាំមួយ ។

មាត្រា ៨.– គណៈកម្មាធិការ រាជធានី-ខេត្ត ប.ជ.រ.ព.ភ

មានភារកិច្ចអនុវត្តគោលនយោបាយ រាជរដ្ឋាភិបាលប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធដទៃទៀតនៅក្នុងដែនដី របស់ខ្លួន ព្រមទាំងអនុវត្តគោលការណ៍ និងបទបញ្ជាផ្សេងៗពីគណៈកម្មាធិការជាតិដឹក- នាំប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈលេខាធិការដ្ឋានគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ។

មាត្រា ៩.– ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមការងារទាំងប្រាំមួយ និងគណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ រាជធានី-ខេត្ត នឹងកំណត់ដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិដឹកនាំការបង្រ្កាបអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និង ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការរាជធានី-ខេត្ត ប.ជ.រ.ព.ភ នឹងកំណត់ដោយប្រកាស របស់ប្រធានគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ។

មាត្រា ១០.– បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១១.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានី អភិបាលគ្រប់ខេត្ត និង សមាសភាពដូចមានចែងក្នុងមាត្រា ២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចុះហត្ថលេខា ។

ភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

***កន្លែងទទួល***

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ២ និងមាត្រា ១១
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ

ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស

និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ (ប.ជ.រ.ព.ភ)

លេខ :..........

# សេចក្តីសម្រេច

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅ នៃលេខាធិការដ្ឋាន គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាប អំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ (ប.ជ.រ.ព.ភ)

---

**គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ (ប.ជ.រ.ព.ភ)**

- បានឃើញ រដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកប/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០៨
- បានឃើញព្រះរាជក្រមលេខ នស/រកប/០១០៦/០០៤ ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃពិធីសារ ស្តីពី ការទប់ស្កាត់

បង្ក្រាប និងដាក់ទណ្ឌកម្ម ការជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារ ដែលបំពេញបន្ថែមលើ អនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ដែលមានអង្គការចាត់តាំង

- បានឃើញអនុក្រឹត្យ លេខ ១៦២ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៩ ស្តីពី ការបង្កើតគណៈកម្មា - ធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ (ប.ជ.រ.ព.ភ)

## សម្រេច

**ប្រការ ១ :** ត្រូវបានរៀបចំនិងតែងតាំងសមាសភាពនៃលេខាធិការដ្ឋាន គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាប អំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើរអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ (ប.ជ.រ.ព.ភ) ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១. | លោកជំទាវ **ជូ ប៊ុនអេង** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២. | លោកជំទាវ **សាន្ត អារុណ** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | អនុប្រធាន |
| ៣. | ឯកឧត្តម **តោ សៀត** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៤. | លោកជំទាវ **ឡាត់ ចន្ថា** | រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៥. | ឯកឧត្តម **អ៊ិត រ៉ាឌី** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៦. | ឯកឧត្តម ឧត្តមសេនីយ៍ឯក **ភេខ សុខន** | អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ | អនុប្រធានអចិន្ត្រៃយ៍ |
| ៧. | ឯកឧត្តម ឧត្តមសេនីយ៍ទោ **ឡាត់ សិទ្ធិ** | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | អនុប្រធាន |
| ៨. | ឯកឧត្តម **លី អ៊ីវឡាក់** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩. | ឯកឧត្តម ឧត្តមសេនីយ៍ឯក **គៀត ចំន្ទថារិទ្ធ** | ប្រធានសេនាធិការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១០. | ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឯម សំណាង** | អគ្គនាយករង នៃអគ្គនាយកដ្ឋាន ភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ | សមាជិក |
| ១១. | លោកឧត្តមសេនីយ៍ទោ **ចិត គិមយ៉ុង** | ប្រធាននាយកដ្ឋានប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១២. | លោកឧត្តមសេនីយ៍ទោ **ឆៅ ភក្តី** | ជំនួយការរដ្ឋមន្ត្រី និងជាប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិក |

១៣. លោក **ហ៊ុ ឌុល្លី** អគ្គនាយករង នៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១៤. លោកជំទាវ **ហោ ម៉ាលីន** អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី សមាជិក

១៥. លោកជំទាវ **សុខ ចិន្ដាឡាយ** អនុរដ្ឋលេខាធិការ ទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក

១៦. លោកជំទាវ **ចំនួ ចារ៉ាន់ចន្ទី** អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

១៧. ឯកឧត្តម **តែខ គន្ធី** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍ សមាជិក

១៨. លោកជំទាវ **ខៀវ សិរីវុឌ្ឍា** អគ្គនាយក នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី សមាជិក

១៩. លោក **គង់ ឆាន** អគ្គនាយករង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

២០. លោក **គីម សុខណ្ណា** អនុប្រធាននាយកដ្ឋានច្បាប់ និងកុងស៊ុល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

២១. តំណាងក្រសួងសុខាភិបាល សមាជិក។

លេខាធិការដ្ឋាននេះ មាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនជាសេនាធិការ និង មានមន្ត្រីអចិន្ត្រៃយ៍ មន្ត្រីបច្ចេកទេសជាតិនិងអន្តរជាតិមួយចំនួនបន្ថែមទៀតជាជំនួយក្នុងការរៀបចំផែនការ ការពង្រឹងសមត្ថភាពក្រុមការងារ និងលេខាធិការដ្ឋានគ្រប់ថ្នាក់ បង្កើតសម្ភារៈសម្រាប់អប់រំផ្សព្វផ្សាយ ចុះតាមដានត្រួតពិនិត្យវាយតម្លៃ ប្រមូលរបាយការណ៍បូកសរុប និងចងក្រងឯកសារ ព្រមទាំងការងារមួយចំនួនទៀត តាមការចាំបាច់។ មន្ត្រីអចិន្ត្រៃយ៍ និងមន្ត្រីបច្ចេកទេស អាចជាមន្ត្រីមកពីក្រសួងស្ថាប័នពាក់ព័ន្ធ បន្ថែមលើមន្ត្រីពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ។

**ប្រការ ២ : លេខាធិការដ្ឋានមានភារកិច្ចដូចតទៅ :**

- ធ្វើឱ្យសម្រេចនូវផែនការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្ម លើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារនៅព្រះរាជាណាចក្រកម្ពុជា ។
- ជួយដល់ប្រធានគណៈកម្មាធិការជាតិដឹកនាំ ប.ជ.វ.ព.ភ ក្នុងការសម្របសម្រួល ជម្រុញ ចាត់តាំង និងតាមដានត្រួតពិនិត្យ វាយតម្លៃ ការអនុវត្តផែនការ **ប.ជ.វ.ព.ភ.** របស់ក្រុមការងារ ទាំងប្រាំមួយ (០៦) និងគណៈកម្មាធិការ ប.ជ.វ.ព.ភ រាជធានី-ខេត្ត ក្នុងការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ។

- លើកគោលការណ៍ និងវិធានការផ្សេងៗ ដាក់ជូនគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ដើម្បីជំរុញ ដឹកនាំកិច្ចការខាងលើ ឱ្យមានប្រសិទ្ធិភាព និងទទួលបានជោគជ័យ ។
- ស្រាវជ្រាវ ប្រមូល និងចងក្រងឯកសារ ដែលទាក់ទងនឹងការរីកចំរើន បទពិសោធន៍ និងការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តការងារ របស់ក្រុមការងារទាំងប្រាំមួយ និងគណៈកម្មាធិការ ប.ជ.រ.ព.ភ រាជធានី-ខេត្ត ។
- ធ្វើរបាយការណ៍ទៀងទាត់ប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ ដាក់ជូនគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ដើម្បីផ្ញើជូនទៅរាជរដ្ឋាភិបាល និងចាត់ចែងផ្សព្វផ្សាយបន្តទៅតាមគោលដៅនានា ។
- រៀបចំឯកសារជូនប្រធានគណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ ដើម្បីចូលរួមកិច្ចប្រជុំ ផ្សេងៗ ក្នុង និងក្រៅប្រទេស ។
- រៀបចំបោះពុម្ពព្រឹត្តិបត្តិប្រចាំត្រីមាស គេហទំព័រ និងឯកសារផ្សព្វផ្សាយអំពីសកម្មភាពការងារគណៈកម្មាធិការជាតិ ប.ជ.រ.ព.ភ ។
- សម្របសម្រួលរៀបចំកិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទផ្សេងៗទាំងថ្នាក់ជាតិ និងអន្តរជាតិដែលពាក់ព័ន្ធនឹង ប.ជ.រ.ព.ភ ។
- រៀបចំគំរោងផែនការសកម្មភាពរយៈពេលវែង មធ្យមនិងខ្លីរបស់លេខាធិការដ្ឋាន និងថ្នាក់ជាតិ ។
- រៀបចំ និងអនុវត្តផែនការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីក្រុមការងារ និងលេខាធិការដ្ឋានគ្រប់ថ្នាក់ ។
- ទំនាក់ទំនង សម្របសម្រួល និងរៀបចំកិច្ចប្រជុំពិភាក្សាជាមួយក្រុមប្រឹក្សានៃបណ្តាដៃគូអភិវឌ្ឍន៍ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ ពង្រឹងកិច្ចសហការ និងស្វែងរកការគាំទ្រធនធានទាំងបច្ចេកទេស ថវិកា មធ្យោបាយ និងសម្ភារៈ គួបផ្សំនិងធនធានរបស់ជាតិដែលមានស្រាប់ ដើម្បីធានាដល់សកម្មភាព ប.ជ.រ.ព.ភ ឱ្យមាននិរន្តរភាព ។
- ប្រជុំក្រុមលេខាធិការដ្ឋានជាទៀងទាត់ប្រចាំត្រីមាស តាមការអញ្ជើញរបស់ប្រធានលេខាធិការដ្ឋាន និងកិច្ចប្រជុំវិសាមញ្ញ ក្នុងករណីចាំបាច់ដើម្បីដោះស្រាយបញ្ហា ។
- បំពេញការងារផ្សេងៗទៀតដែលគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ប្រគល់ជូន ។

**ប្រការ៣ :**

- លេខាធិការដ្ឋាន ប.ជ.រ.ព.ភ មានសិទ្ធិប្រើប្រាស់ត្រា និងរូបសញ្ញានៃគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្ម និងការធ្វើអាជីវកម្មផ្លូវភេទ លើរាល់លិខិតបទដ្ឋាន និង របាយការណ៍របស់លេខាធិការដ្ឋាន ។
- រាល់លិខិតបទដ្ឋានផ្លូវការរបស់ក្រុមការងារនីមួយៗ អាចស្នើសុំប្រើប្រាស់ត្រាលេខាធិការដ្ឋាននៃគណៈកម្មា - ធិការជាតិ ប.ជ.រ.ព.ភ ក្នុងករណី ចាំបាច់ ។
- រាល់លិខិតបទដ្ឋានផ្លូវការរបស់គណៈកម្មាធិការ ប.ជ.រ.ព.ភ រាជធានី-ខេត្ត អាចប្រើប្រាស់ត្រា និងរូបសញ្ញាគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ដោយមានបញ្ជាក់អំពីឈ្មោះរាជធានី-ខេត្តសាម៉ី ។

**ប្រការ៤** : ក្រុមការងារចំនួន ០៦ ជាជំនួយឱ្យលេខាធិការដ្ឋាន មានដូចខាងក្រោម :

**១- ក្រុមការងារទប់ស្កាត់**

**ក-សមាសភាព :**

| | | |
|---|---|---|
| ១. លោកជំទាវ **ហោ ម៉ាលីន** | អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | ប្រធាន |
| ២. ឯកឧត្តម **ហោ សារុន** | អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | អនុប្រធាន |
| ៣. លោកជំទាវ **ញឹម ចាន់ចំនួតន** | អគ្គាធិការរង ក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៤. លោក **ច័ន ទេត** | តំណាងអង្គការ ទស្សនៈពិភពលោក | អនុប្រធាន |
| ៥. លោកស្រី **ជា ផល្លីន** | អគ្គនាយករង ក្រសួង ព័ត៌មាន | សមាជិក |
| ៦. លោកស្រី **នុំ ម៉ូផារី** | ប្រធាននាយកដ្ឋាន ស្ត្រី និងការអប់រំ ក្រសួងកិច្ចការនារី | សមាជិក |
| ៧. លោកស្រី **ស៊ុន វណ្ណា** | អនុប្រធាននាយកដ្ឋាន ការពារផ្លូវច្បាប់ ក្រសួងកិច្ចការនារី | សមាជិកអចិន្ត្រៃយ៍ |
| ៨. លោក **ជួប ណារ៉ាត់** | អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៩. លោកស្រី វរៈសេនីយ៍ឯក **អ៊ឹម ឡូ** | អនុប្រធាន នាយកដ្ឋាន ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង ការពារអានីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១០.លោក **គិម ប៊ុនណារ៉ា** | អនុប្រធាន នាយកដ្ឋានផែនការអភិវឌ្ឍន៍ ក្រសួងទេសចរណ៍ | សមាជិក |
| ១១. លោកអនុសេនីយ៍ឯក **គង់ វេតនៈ** | កងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១២. តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | | សមាជិក |
| ១៣. លោកវេជ្ជបណ្ឌិត **ឡូត សេរីវត្ត** | មន្ត្រីអាជ្ញាធរជាតិប្រយុទ្ធជម្ងឺអេដស៍អេដស៍ | សមាជិក |
| ១៤. តំណាងក្រសួងសុខាភិបាល | | សមាជិក ។ |

**ខ-ភារកិច្ច ក្រុមការងារទប់ស្កាត់**

- បង្កើត និងអភិវឌ្ឍន៍សម្ភារៈសម្រាប់ការអប់រំ ផ្សព្វផ្សាយតាមគ្រប់រូបភាព អំពីកលល្បិចជនល្មើស និងសារអប់រំសំខាន់ៗ តាមគ្រប់រូបភាពដែលមានប្រសិទ្ធភាពក្នុងការបង្ការ និងទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដោយសហការជាមួយក្រុមការងារដទៃទៀត ។
- ត្រួតពិនិត្យរាល់ខ្លឹមសារ និងរូបភាព នៃការផ្សព្វផ្សាយគ្រប់ប្រព័ន្ធ ទាំងវិស័យសាធារណៈ និងវិស័យឯកជន ដើម្បីរកឱ្យឃើញនូវផលប៉ះពាល់ជាអវិជ្ជមាន និងធ្វើការណែនាំកែលំអ ឬធ្វើសំណើសុំផ្អាក ឬបិទជាស្ថាពរ

រាល់ការផ្សព្វផ្សាយទាំងឡាយណា ដែលមានលក្ខណៈអាសអាភាស និងដែលជះឥទ្ធិពលមិនល្អដល់សង្គម ឬដែលធ្វើឱ្យកើនឡើងនូវអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្ម និងអាជីវកម្មផ្លូវភេទ ។

- រៀបចំកម្មវិធីអប់រំ និងផ្សព្វផ្សាយចំណេះដឹងអំពីច្បាប់ជាតិ អនុសញ្ញា ពិធីសារអន្តរជាតិពាក់ព័ន្ធ ព្រមទាំងវិធានការនានាដើម្បីទប់ស្កាត់ កលល្បិចជនល្មើសក្នុងអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្ម និងអាជីវកម្មផ្លូវភេទ ។
- លើកវិធានការទប់ស្កាត់ពេស្យាចារកុមារ ត្រួតពិនិត្យការគ្រប់គ្រង និងការប្រើប្រាស់ពលកម្ម ជាពិសេសការប្រើប្រាស់កុមារ នៅតាមសេវាទេសចរណ៍ និងសេវាបំរើការកំសាន្តគ្រប់រូបភាព ។
- សម្របសម្រួល ស្រាវជ្រាវប្រមូលទិន្នន័យ និងចងក្រងឯកសារ ដែលទាក់ទងនឹងការងារទប់ស្កាត់ អំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្ម និងអាជីវកម្មផ្លូវភេទ ។
- រៀបចំធ្វើផែនការសកម្មភាពរយៈពេលខ្លី មធ្យម និងវែង ដោយផ្អែកលើអាទិភាព ដែលបានកំណត់ក្នុងផែនការសកម្មភាពជាតិ ។
- សម្របសម្រួលសហការជាមួយក្រុមជំនាញដទៃទៀតដើម្បីធ្វើឱ្យសម្រេចលទ្ធផលតាមទិសដៅគ្រោងទុក ។
- ចូលរួមកិច្ចប្រជុំនានា និងកម្មវិធីពង្រឹងសមត្ថភាព ដែលរៀបចំដោយលេខាធិការដ្ឋាន ឬក្រុមការងារផ្សេងទៀត តាមការចាំបាច់ ។
- ជួបប្រជុំក្រុមការងារ ជាទៀងទាត់ ប្រចាំខែ និងរៀបចំកិច្ចប្រជុំវិសាមញ្ញ តាមការអញ្ជើញរបស់ប្រធាន ក្នុងករណីចាំបាច់ ។
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ផ្ញើទៅលេខាធិការដ្ឋាន ដោយធ្វើការវាយតម្លៃ ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្របង្ការទប់ស្កាត់ ចំណុចខ្លាំង ភាពប្រឈម ដំណោះស្រាយជាបទពិសោធន៍ កំណត់ទិសដៅ តម្រូវការជាមូលដ្ឋាន សម្រាប់ជំហានបន្ត និងអនុសាសន៍ជាអាទិភាព ។

**២-ក្រុមការងារការពារ ស្ត្រីនីតិសម្បទា សមាហរណកម្ម និងមាតុភូមិនិវត្តន៍:**

**ក-សមាសភាព :**

១- លោក **គង់ ឆាន** អគ្គនាយករងបច្ចេកទេស ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រធាន

២- លោកស្រីវេជ្ជបណ្ឌិត **ស៊ិន សារ៉េឆាន** ប្រធាននាយកដ្ឋានសុខុមាលភាពសង្គម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុប្រធានអចិន្ត្រៃយ៍

៣- លោកឧត្តមសេនីយ៍ត្រី **ខឹម ផល្លី** អនុប្រធាននាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ អនុប្រធាន

៤- លោក **រស់ យេខ** តំណាង អង្គការ ចាប់ដៃ អនុប្រធាន

៥- លោក វេជ្ជ. **រស់ សីលខាំត់** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សមាជិក

៦- លោកស្រី **ខាម ស៊ីអ៊ុយ** ទីប្រឹក្សាក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៧- លោកស្រី **អ៊ុំ ខណ្ឌឫទ្ធី** អនុប្រធាននាយកដ្ឋានសុខុមាលភាពសង្គម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

៨- លោក **វុន សុខណ្ណា** អនុប្រធាននាយកដ្ឋានអន្តោប្រវេសន៍ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

៩- លោកស្រី **សាត សាឈីម** អនុប្រធាននាយកដ្ឋានការពារផ្លូវច្បាប់ ក្រសួងកិច្ចការនារី សមាជិក

១០- លោកវរៈសេនីយ៍ទោ **តូច សារឿន** នាយផ្នែកអប់រំស្តារនីតិសម្បទា កងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

១១- តំណាងក្រសួងសុខាភិបាល សមាជិក

១២- តំណាងក្រសួង យុត្តិធម៌ សមាជិក

១៣- តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១៤-តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក ។

**ខ-ភារកិច្ច ក្រុមការងារការពារ ស្តារនីតិសម្បទា សមាហរណកម្ម និងមាតុភូមិនិវត្តន៍ :**

- ជំរុញ និងលើកកម្ពស់ប្រសិទ្ធភាពសកម្មភាពការពារ ស្តារនីតិសម្បទា សមាហរណកម្ម និងធ្វើមាតុ ភូមិនិវត្តន៍ជនរងគ្រោះ ដោយអំពើ ជ.រ.ព.ភ. ។
- ធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះ ប្រភេទសេវា និងអាស័យដ្ឋាន មណ្ឌលរដ្ឋាភិបាល និងអាស័យដ្ឋានអង្គការមិនមែនរដ្ឋាភិបាលដែលមានមណ្ឌលថែទាំជនរងគ្រោះ ដោយសារអំពើជួញដូរ និងបោះពុម្ពផ្សាយ ។
- ផ្តល់កិច្ចគាំទ្រ និងការពារតាមផ្លូវច្បាប់ ដល់អង្គការដែលផ្តល់សេវាថែទាំ និងជួយជនរងគ្រោះក្នុងមណ្ឌលរបស់ខ្លួន ។

- ផ្សព្វផ្សាយ និងផ្តល់ការយល់ដឹងអំពីគោលនយោបាយ និងបទដ្ឋានអប្បបរមា (Minimum standard) ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជម្រុញការអនុវត្តបទដ្ឋាននេះទៅគ្រប់អ្នកផ្តល់សេវាជួយជនរងគ្រោះ ទាំងរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ។
- ពង្រឹងគុណភាពសេវា ផ្តល់ជំរកស្នាក់នៅសម្រាប់ជួយជនរងគ្រោះដែលផ្តល់ដោយរដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាល ។
- ចងក្រងឯកសារ សៀវភៅបណ្តុះបណ្តាល អប់រំ ផ្សព្វផ្សាយ (IEC materials) ថ្នាក់ជាតិសំរាប់ការផ្តល់សេវាជួយជនរងគ្រោះ ។
- រៀបចំផែនការរយៈពេលខ្លី មធ្យម វែង ដើម្បីជម្រុញការអនុវត្តឱ្យមានប្រសិទ្ធភាព ។
- សម្របសម្រួល សហការទាំងផ្ទៃក្នុងជាតិ និងអន្តរជាតិ និងជម្រុញការអនុវត្តគោលនយោបាយ និងបទដ្ឋាននានា សំដៅធ្វើឱ្យប្រសើរឡើងនូវសេវាសង្គមក្នុងការការពារ ស្តារនីតិសម្បទា ការធ្វើសមាហរណកម្ម និងមាតុភូមិនិវត្តន៍ជនរងគ្រោះទៅក្នុងសង្គម និងគ្រួសារវិញ ។
- ជួបប្រជុំក្រុមការងារជាទៀងទាត់ប្រចាំខែ និងវិសាមញ្ញ តាមការអញ្ជើញរបស់ប្រធាន ក្នុងករណី ចាំបាច់ ។ ចូលរួមកិច្ចប្រជុំនានា និងកម្មវិធីពង្រឹងសមត្ថភាព ដែលរៀបចំដោយលេខាធិការដ្ឋាន ឬក្រុមការងារផ្សេងទៀត តាមការចាំបាច់ ។
- ផ្តល់របាយការណ៍អំពីលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ផ្ញើទៅលេខាធិការដ្ឋាន ប.ជ.រ.ព.ភ ដោយធ្វើការវាយតម្លៃលើប្រសិទ្ធភាពនៃការការពារជនរងគ្រោះដោយលើកឡើងអំពី ចំណុចខ្លាំង ចំណុចខ្សោយ ភាពប្រឈម ដំណោះស្រាយ កំណត់ទិសដៅបន្ត និងអនុសាសន៍ជាអាទិភាព ។

**៣-ក្រុមការងារអនុវត្តច្បាប់ :**

**ក-សមាសភាព :**

១. ឯកឧត្តមឧត្តមសេនីយ៍ឯក **តខ សុខន** អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ទទួលផែននគរបាលយុត្តិធម៌ ប្រធាន

២. លោកឧត្តមសេនីយ៍ទោ **មឹត តិមឃុន** ប្រធាន នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អនុប្រធានអចិន្ត្រៃយ៍

៣. លោកឧត្តមសេនីយ៍ត្រី **ឆែន មុនីនី** អនុប្រធាន នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អនុប្រធាន

៤. លោក **សំលៀង សីលា** ប្រធានអង្គការសកម្មភាព ដើម្បីកុមារ (APLE) អនុប្រធាន

៥. លោក **គីម សោភ័ណ** អធិការ នៃអគ្គាធិការដ្ឋាន ក្រសួងយុត្តិធម៌ សមាជិក

៦. លោកឧត្តមសេនីយ៍ត្រី **ខាំ សារិន** នាយរងស្នងការស្រាវជ្រាវ និងយុត្តិធម៌ កងរាជអាវុធហត្ថលើផ្ទៃប្រទេសប្រទេស សមាជិក

៧. លោកវរៈសេនីយ៍ឯក **ឆាត់ យូឡាន** អនុប្រធាននាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

៨. លោក **គីម សុខវណ្ណធី** ប្រធានការិយាល័យជួញដូរ និងសមាហរណកម្ម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

**ខ-ភារកិច្ចក្រុមការងារអនុវត្តច្បាប់ ៖**

- ប្រមូលពត៌មានដែលពាក់ព័ន្ធនឹងអំពើ ជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ពីគ្រប់គោលដៅ និងនៅតាមច្រកទ្វារព្រំដែន ។
- ជម្រុញការស៊ើបអង្កេតរាល់ពត៌មាន និងពាក្យបណ្ដឹង សំដៅស្វែងរកភស្ដុតាង សាក្សីគ្រប់គ្រាន់ ដើម្បីបំរើឱ្យការងារបង្ក្រាប និងផ្ដន្ទាទោសតាមច្បាប់ ព្រមទាំងសង្គ្រោះជនរងគ្រោះ បញ្ជូនទៅមន្ទីរសង្គមកិច្ច ឬគ្រួសារវិញ ។
- រៀបចំផែនការរយៈពេលខ្លី មធ្យម វែង និងស្វែងរកមូលនិធិគាំទ្រសកម្មភាព ។
- សំរបសំរួលឱ្យមន្ត្រីជំនាញក្នុងនាយកដ្ឋាននិងការិយាល័យប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់កណ្ដាល និងថ្នាក់ រាជធានី-ខេត្ត ទាំងនៅក្នុងអគ្គស្នងការដ្ឋាននគរបាលជាតិ និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស មានកិច្ចសហការជាមួយ សមត្ថកិច្ចពាក់ព័ន្ធ និងបណ្ដាអង្គការជាដៃគូ ដើម្បីផ្លាស់ប្ដូរពត៌មាន និងធ្វើការស៊ើបអង្កេត ឈានដល់ការបង្ក្រាបបទល្មើសជួញដូរមនុស្ស និងផ្ដន្ទាទោសជនល្មើស ។
- ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ អំពីជំនាញ ច្បាប់ នីតិវិធី សីលធម៌វិជ្ជាជីវៈ និងបច្ចេកទេសក្នុងកិច្ចសង្គ្រោះ ជនរងគ្រោះ និងការបង្ក្រាបជនល្មើសនៃអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ។
- ត្រួតពិនិត្យ តាមដាន និងជម្រុញការងារជំនាញរបស់មន្ត្រីអនុវត្តច្បាប់ នៅតាមបណ្ដាមូលដ្ឋានរាជធានី-ខេត្ត និងមានវិធានការតឹងរ៉ឹង ក្នុងការកែលំអកំហុសឆ្គង និងឥរិយាបទមន្ត្រីអនុវត្តច្បាប់ សំដៅលើកកម្ពស់ គុណភាព និងប្រសិទ្ធភាពឱ្យបានល្អប្រសើរ ។
- ជម្រុញ ណែនាំសមត្ថកិច្ចរាជធានី-ខេត្ត ឱ្យបន្តស្រាវជ្រាវ ស្រង់ស្ថិតិ គោលដៅសង្ស័យ ដើម្បីគ្រប់គ្រង និងជម្រុញការធ្វើកិច្ចសន្យាទប់ស្កាត់បណ្ដាគោលដៅដែលអាចពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ។

- ស្រង់បញ្ជីឈ្មោះជនសង្ស័យ ដែលបានបញ្ជូនទៅស្ថាប័នអយ្យការរាជធានី-ខេត្ត និងតាមដានលទ្ធផលនៃការងារ កាត់ទោស ។
- ប្រជុំក្រុមការងារ ជាទៀងទាត់ ប្រចាំខែ និងចូលរួមកិច្ចប្រជុំវិសាមញ្ញ តាមការអញ្ជើញរបស់ប្រធាន ក្នុងករណីចាំបាច់ដើម្បីដោះស្រាយបញ្ហា និងដាក់ផែនការអនុវត្តបន្ត ។
- អនុវត្តកិច្ចការផ្សេងៗទៀត ដែលលេខាធិការដ្ឋាននៃក្រុមការងារដឹកនាំ ប.ជ.រ.ព.ភ ប្រគល់ឱ្យ ។
- ធ្វើរបាយការណ៍ខែ ត្រីមាស ឆមាស និងឆ្នាំ ជូនទៅលេខាធិការដ្ឋាន ប.ជ.រ.ព.ភ ដោយធ្វើការវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងវិធានការនានាក្នុងការសង្គ្រោះ និងបង្ក្រាប ចំណុចខ្លាំង ភាពប្រឈម ដំណោះស្រាយជាបទពិសោធន៍ តម្រូវការជាមូលដ្ឋានសម្រាប់ ជំហានបន្ត និងអនុសាសន៍ជាអាទិភាព ក្នុងរបាយការណ៍ត្រីមាស ឆមាស និងឆ្នាំ ។

**៤- ក្រុមការងារកិច្ចការយុត្តិធម៌:**

**ក-សមាសភាព :**

១. ឯកឧត្តម **អ៊ិត រ៉ាឌី** អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ ប្រធាន

២. លោកស្រី **ម៉ែន សុមេធា** អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌ ក្រសួងយុត្តិធម៌ អនុប្រធានអចិន្ត្រៃយ៍

៣. លោកឧត្តមសេនីយ៍ត្រី **ឃឹម ធីរៈ** អនុប្រធាននាយកដ្ឋាន ប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ អនុប្រធាន

៤. លោកស្រី **ឈី ទិដ្ឋតា** តំណាងអង្គការជំនួយផ្នែកច្បាប់សម្រាប់ស្ត្រី និងកុមារ (LSCW) អនុប្រធាន

៥. លោកស្រី **សាខឿន សាទាវ៉ត់ឌី** អគ្គនាយករងអភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី សមាជិក

៦. លោកស្រី **ជូ សុផាវី** អគ្គលេខាធិការរង ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី សមាជិក

៧. លោកវរៈសេនីយ៍ទោ **អៀម ទាសនា** កងរាជអាវុធហត្ថ លើផ្ទៃប្រទេស សមាជិក

៨. លោក **ពៅ ម៉ុនធឿន** ប្រធាននាយកដ្ឋានព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ សមាជិក

៩. លោកវរៈសេនីយ៍ទោ **ថ្វើន ទន្លេស្អ** ជំនួយការប្រធានលេខាធិការដ្ឋាន ប.ជ.រ.ព.ភ សមាជិក

១០. តំណាងក្រសួងសុខាភិបាល សមាជិក

១១. តំណាងនាយកដ្ឋានមុខរបរ ក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក ។

**ខ-ភារកិច្ចក្រុមការងារកិច្ចការងារយុត្តិធម៌ :**

- ធ្វើផែនការការងារ ដោយផ្អែកលើអាទិភាពដែលបានកំណត់ និងស្វែងរកជំនួយគាំទ្រទាំងផ្នែកបច្ចេកទេសនិង ថវិកា ដើម្បីអនុវត្តសកម្មភាពរបស់ខ្លួន ។
- បង្កើនកិច្ចសហការជិតស្និទ្ធជាមួយសមត្ថកិច្ចពាក់ព័ន្ធនានា ដើម្បីធ្វើកិច្ចការផ្តន្ទាទោសជនល្មើសឱ្យស្របតាមច្បាប់កំនត់ ។
- តាមដាន គ្រប់គ្រង និងប្រមូលទិន្នន័យរឿងក្តីពាក់ព័ន្ធករណីជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ និង ការផ្តន្ទាទោស ។
- ជម្រុញ និងពង្រឹងការចោទប្រកាន់និងផ្តន្ទាទោសជនល្មើសពាក់ព័ន្ធករណីជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ។
- បង្កើនសមត្ថភាពផ្នែកចំណេះដឹង និងបច្ចេកទេសនៃកិច្ចការចោទប្រកាន់ ស៊ើបអង្កេត និងផ្តន្ទាទោសនៃករណី ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ដល់មន្ត្រីអនុវត្តច្បាប់រួមទាំងចៅក្រម និងព្រះរាជអាជ្ញា ។
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលការយល់ដឹងអំពីច្បាប់ជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ដល់គ្រប់ស្ថាប័នពាក់ព័ន្ធទាំងរដ្ឋ និងឯកជន និងសាធារណជន ។
- ផ្តល់អនុសាសន៍លើគោលនយោបាយពាក់ព័ន្ធ នឹងកិច្ចការចោទប្រកាន់ស៊ើបអង្កេត និងផ្តន្ទាទោសករណីជួញដូរ មនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ដល់ក្រុមការងារដឹកនាំ ប.ជ.រ.ព.ភ. ។
- ផ្តល់កិច្ចគាំទ្រ និងកិច្ចការពារតាមផ្លូវច្បាប់ ដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ។
- សម្របសម្រួលការទំនាក់ទំនងការងាររវាងស្ថាប័នអនុវត្តច្បាប់ទាំងអស់ សំដៅជម្រុញការផ្តន្ទាទោសឱ្យមានប្រសិទ្ធភាព ជាពិសេសក្នុងការអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ។
- សម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិ ទ្វេភាគី និងពហុភាគីក្នុងការអនុវត្តក្រមព្រហ្មទណ្ឌប្រឆាំង ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ រួមមានការធ្វើបត្យាប័ន និងការជួយគ្នាទៅវិញទៅមកតាម ផ្លូវតុលាការ ជាពិសេសកិច្ចការផ្តន្ទាទោស ដែលកំណត់ក្នុងផែនការសកម្មភាពជាតិ (NPA) និង ផែនការសកម្មភាព ក្នុងមហាអនុតំបន់ទន្លេមេគង្គ (COMMIT) ។
- ជួបប្រជុំក្រុមការងារ ជាទៀងទាត់ប្រចាំខែ តាមការអញ្ជើញរបស់ប្រធាន និងកិច្ចប្រជុំវិសាមញ្ញក្នុងករណី ចាំបាច់ដើម្បីដោះស្រាយបញ្ហា និងចូលរួមកិច្ចប្រជុំផ្សេងទៀត ដែលរៀបចំដោយលេខាធិការដ្ឋាន ឬក្រុមការ ងារដទៃតាមការចាំបាច់។

- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ផ្ញើទៅលេខាធិការដ្ឋាន ប.ជ.រ.ព.ក ដោយធ្វើការវាយតម្លៃប្រសិទ្ធភាពនៃដំណើរការផ្តន្ទាទោស ភាពខ្លាំង បញ្ហាប្រឈម ដំណោះស្រាយជាបទពិសោធន៍ ទិសដៅ តម្រូវការជាមូលដ្ឋាន សម្រាប់ជំហានបន្ត និងអនុសាសន៍ជាអាទិភាព។

**៥-ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ:**

**ក- សមាសភាព :**

១- លោកជំទាវ **ខៀវ សិរីវុឌ្ឍា** អគ្គនាយក អភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី ប្រធាន

២- ឯកឧត្តមឧត្តមសេនីយ៍ទោ **ឆៅ ឥន្ទ្រី** ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ក្រសួងមហាផ្ទៃ អនុប្រធាន

៣- លោក**គីម សុខណ្ណា** អនុប្រធាននាយកដ្ឋានច្បាប់ កុងស៊ុល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៤- លោក **លឹម និត** អ្នកសម្របសម្រួលគំរោងអង្គការ UNIAP អនុប្រធាន

៥- លោកស្រី **ហេង ស៊ីម៉ុន** អគ្គនាយករង អភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី សមាជិកអចិន្ត្រៃយ៍

៦- លោកឧត្តមសេនីយ៍ត្រី **អ៊ុច សារ៉ាន់** នាយរងស្នងការពត៌មាន កងរាជអាវុធហត្ថលើផ្ទៃប្រទេសក្រសួងការពារជាតិ សមាជិក

៧- លោក **ខៅង ចំរើន** អនុប្រធាននាយកដ្ឋាន សុខុមាលភាពសង្គម ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

៨- លោកវរៈសេនីយ៍ឯក **សាយ ម៉េងឈាង** អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ សមាជិក

៩- លោកស្រី **ពុធ និស្សៃយ** អនុប្រធាននាយកដ្ឋាន ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១០- លោក **ចំនួ សត្ថា** ប្រធាននាយកដ្ឋាន កិច្ចការអន្តរជាតិ ក្រសួងយុត្តិធម៌ សមាជិក

១១- លោក **អ៊ុក រ៉ាវុធ** ប្រធានការិយាល័យ ត្រួតពិនិត្យកម្មករនិយោជិតខ្មែរ តំណាងក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ សមាជិក

១២- លោកស្រី **ជោគ ស៊ុណារ៉ា** ក្រសួងទេសចរណ៍ សមាជិក ។

**ខ-ភារកិច្ច ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ :**

- ទំនាក់ទំនង សហការ សម្របសម្រួលជាមួយក្រសួង ស្ថាប័នដៃគូ អាជ្ញាធរមានសមត្ថកិច្ច អង្គការក្នុងស្រុក និងអន្តរជាតិ ព្រមទាំងប្រទេសពាក់ព័ន្ធនានា ដើម្បីជំរុញការអនុវត្តកិច្ចព្រមព្រៀង អនុស្សារណៈ

នៃការឃោតយល់គ្នា ទ្វេភាគី និងពហុភាគី ពាក់ព័ន្ធនឹង ប.ជ.រ.ព.ភ. ឱ្យមានប្រសិទ្ធភាព ។

- សហការជាមួយក្រុមការងារ COMMIT រៀបចំកិច្ចព្រមព្រៀង អនុស្សរណៈនៃការឃោតយល់គ្នា ទ្វេភាគី និង ពហុភាគី ជាមួយបណ្តាប្រទេសដែលពាក់ព័ន្ធនឹងការជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្ម និង ការធ្វើអាជីវកម្មផ្លូវភេទ និងដាក់ជូនគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ដឹកនាំពិនិត្យ ។
- បូកសរុបវាយតម្លៃលទ្ធផល នៃការអនុវត្តផែនការស្តីពីការអនុវត្តកិច្ចព្រមព្រៀង អនុស្សារណៈនៃការឃោតយល់ គ្នាទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសនានា អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងលិខិតតូប្បករណ៍ អន្តរជាតិទាំងអស់ពាក់ព័ន្ធនឹងអំពើ ជ.រ.ព.ភ. និងលើកអនុសាសន៍សំដៅជំរុញឱ្យការអនុវត្តមានប្រសិទ្ធភាព ។
- ប្រមូលទិន្នន័យ និងធ្វើរបាយការណ៍អំពីលទ្ធផលនៃកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសពាក់ព័ន្ធក្នុងការ ប្រឆាំងការជួញដូរមនុស្សឆ្លងដែន ។
- ជួបប្រជុំក្រុមការងារ ជាទៀងទាត់ ៣ ខែម្តង និងកិច្ចប្រជុំវិសាមញ្ញ តាមការអញ្ជើញរបស់ប្រធាន ក្នុងករណីចាំបាច់ដើម្បីដោះស្រាយបញ្ហា ។ ក្រុមការងារ គប្បីចូលរួមកិច្ចប្រជុំនានា និងកម្មវិធីពង្រឹងសមត្ថភាព ដែលរៀបចំដោយលេខាធិការដ្ឋាន ឬក្រុមការងារផ្សេងទៀត តាមការចាំបាច់ ។
- ធ្វើរបាយការណ៍ខែ និងរបាយការណ៍បូកសរុបប្រចាំត្រីមាស និងឆ្នាំ ជូនទៅលេខាធិការដ្ឋានក្រុមការងារដឹកនាំ ដោយធ្វើការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀង ចំណុចខ្លាំង ភាពប្រឈម ដំណោះស្រាយជាបទពិសោធន៍ ទិសដៅ តម្រូវការជាមូលដ្ឋានសម្រាប់ជំហានបន្ត និងអនុសាសន៍ ជាអាទិភាព។

## ៦-ក្រុមការងារកិច្ចការកុមារ

### ក-សមាសភាព ៖

| | | |
|---|---|---|
| ១- | លោកជំទាវ **ចំនួ ឃារ៉ាន់ខឌ្ឌី** អនុរដ្ឋលេខាធិការ ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា. | ប្រធាន |
| ២- | លោកស្រី **ខៀវ ប៊ូរី** អគ្គលេខាធិការក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- | លោកស្រី **ឱ្យម និមល** អគ្គនាយករង អភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី | អនុប្រធាន |
| ៤- | លោក **ខេខ ចៀវ** ប្រធាន នាយកដ្ឋាន ការងារកុមារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៥- | កញ្ញា Carol Morrensen តំណាងអង្គការមូលនិធិកុមារ | អនុប្រធាន |

៦- តំណាងក្រសួងអប់រំ យុវជន និងកីឡា សមាជិក

៧- លោកឧត្តមសេនីយ៍ត្រី **ទ្បី ខន** អនុប្រធាននាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ សមាជិក

៨- លោក **ពុទ្ធរា សោភ័ណ្ឌសារ៉ា** តំណាងក្រសួងទេសចរណ៍ សមាជិក

៩- លោក **សុត ចាន់វណ្ណៈ** អនុប្រធាននាយកដ្ឋាន សុខុមាលភាពកុមារ ក្រសួង ស.អ.យ. សមាជិក

១០- តំណាងក្រសួងសុខាភិបាល សមាជិក

១១- លោក **ស៊ិន ទិសិទ្ធ** អនុនាយកដ្ឋានកុមារ ក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១២- លោកស្រី **ឡៅ អេលីសែនា** សមាជិកអចិន្ត្រៃយ៍ ក្រុមការងារបច្ចេកទេស យេនឌ័រ ក្រសួងពត៌មាន តំណាង ក្រសួងពត៌មាន សមាជិក

១៣- លោក អនុសេនីយ៍ទោ **ឈាន សុខម៉េង** កងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

**ខ-ភារកិច្ច ក្រុមការងារកិច្ចការកុមារ :**

- ពិនិត្យ និងបំពេញបន្ថែមលើឯកសារ ឬលិខិតចាំបាច់សម្រាប់ការអនុវត្តច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទលើស្ត្រី បុរស និងកុមារ ព្រមទាំងគោលនយោបាយពាក់ព័ន្ធទៅនឹងការពង្រឹងគោលនយោបាយជាតិ ។
- ពិនិត្យ និងជម្រុញការអនុវត្តន៍ច្បាប់ដែលពាក់ព័ន្ធ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចពលកម្ម និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដែលផ្តោតគោលបំណងលើការ ការងារសិទ្ធិរបស់ពួកគេ ។
- បង្កើតផែនការសកម្មភាពសម្រាប់ក្រុមការងារកិច្ចការកុមារ ដោយផ្អែកលើអាទិភាពដែលបានកំណត់ ។
- ជម្រុញ និងពិនិត្យតាមដានការចូលរួមរបស់សហគមន៍ ដូច្នេះពួកគេអាចពិនិត្យ តាមដាន និងទប់ស្កាត់ការជួញដូរស្ត្រី បុរស និងកុមារ និងអំពើបៀតបៀនផ្លូវភេទលើកុមារ ។
- បង្កើនការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ អំពីការជួញដូរស្ត្រី បុរស និងកុមារ និងវិធានការនានាដោយមានកិច្ចសហការជាមួយក្រុមការងារដទៃទៀត ។
- បង្កើតប្រព័ន្ធមូលដ្ឋាន និងសូចនាករ ពិនិត្យ និងតាមដានដែលវាស់នូវធនធានដែលដាក់បញ្ចូលលទ្ធផល ប្រសិទ្ធភាព និងផលប៉ះពាល់នៃការអនុវត្តន៍សកម្មភាព ។
- ជួបប្រជុំក្រុមការងារ ជាទៀងទាត់រៀងរាល់ខែ តាមការអញ្ជើញរបស់ប្រធាន និងកិច្ចប្រជុំវិសាមញ្ញ ក្នុងករណីចាំបាច់ដើម្បីដោះស្រាយបញ្ហា និងចូលរួមកិច្ចប្រជុំផ្សេងទៀត ដែលរៀបចំដោយ លេខាធិការដ្ឋាន ឬក្រុមការងារដទៃ តាមការអញ្ជើញ ។

- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដោយវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តសកម្មភាព ឆ្លុះបញ្ចាំងពីបញ្ហាដែលពាក់ព័ន្ធ ភាពខ្លាំង បញ្ហាប្រឈម ដំណោះស្រាយដែលមានកន្លងមក មេរៀនដែលទទួលបាន តម្រូវការ និងទិសដៅសម្រាប់ជំហានបន្ទាប់ និងអនុសាសន៍ជាអាទិភាព ។

**ប្រការ ៥ : គណៈកម្មាធិការ ប.ជ.រ.ព.ភ រាជធានី-ខេត្ត**

- រាជធានី និងខេត្តក្រុងទាំងអស់ ត្រូវរៀបចំគណៈកម្មាធិការ ប.ជ.រ.ព.ភ រាជធានី-ខេត្ត ដែលមានសមាសភាពចំរុះស្ថាប័នពាក់ព័ន្ធ និងដឹកនាំដោយ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ។
- សមាសភាពនៃគណៈកម្មាធិការ ប.ជ.រ.ព.ភ រាជធានី-ខេត្ត ត្រូវបានតែងតាំងដោយប្រកាសរបស់គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ។
- គណៈកម្មាធិការ ប.ជ.រ.ព.ភ រាជធានី-ខេត្ត មានភារកិច្ចធ្វើឱ្យសម្រេចនូវផែនការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្ម លើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារនៅក្នុងដែនដីរាជធានី-ខេត្តរបស់ខ្លួន និងធ្វើជាសេនាធិការជូន គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ។
- លេខាធិការដ្ឋាន ប.ជ.រ.ព.ភ រាជធានី-ខេត្ត ដឹកនាំដោយអភិបាលរងមួយរូប និងមានស្នងការរងខេត្តមួយរូប អនុប្រធានមន្ទីរកិច្ចការនារីខេត្ត ឬ/និងអនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬ/និងអនុប្រធានមន្ទីរការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ជាអនុប្រធាន មានប្រធានមន្ទីរពាក់ព័ន្ធនានា ព្រមទាំងតំណាងអង្គការសង្គមស៊ីវិលដែលធ្វើការងារពាក់ព័ន្ធការប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មពលកម្ម និងផ្លូវភេទ ក្នុងខេត្ត ជាសមាជិក ។
- លេខាធិការដ្ឋាន ប.ជ.រ.ព.ភ រាជធានី-ខេត្ត ជាខ្សែបណ្តោយរបស់លេខាធិការដ្ឋាន ប.ជ.រ.ព.ភ ថ្នាក់ជាតិ ។
- លេខាធិការដ្ឋានគប្បីមានមន្ត្រី ដែលទទួលបន្ទុកកិច្ចការអចិន្ត្រៃយ៍ និងមានក្រុមការងារជំនាញដែលស្របទៅនឹងថ្នាក់ជាតិ និងមានការិយាល័យការងារ ស្ថិតនៅក្នុងសាលារាជធានី-ខេត្ត ។
- គណៈកម្មាធិការ ប.ជ.រ.ព.ភ រាជធានី-ខេត្ត មានភារកិច្ចលើកផែនការសកម្មភាព ប.ជ.រ.ព.ភ សម្រាប់រាជធានី-ខេត្តរៀង១ខ្លួន ដោយបញ្ចូលគំរោងថវិកាទៅក្នុងថវិការាជធានី-ខេត្ត ព្រមទាំងស្វែងរកធនធានផ្សេងទៀតទាំងថវិកា និងបច្ចេកទេសដើម្បីគាំទ្រសកម្មភាពទៅតាមលទ្ធភាព របស់ខេត្តនីមួយ១ ។
- គណៈកម្មាធិការ ប.ជ.រ.ព.ភ រាជធានី-ខេត្ត មានភារកិច្ចរៀបចំ និងពង្រឹងគណៈបញ្ជាការថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីជាសេនាធិការ ។
- រៀបចំកិច្ចប្រជុំរៀងរាល់ខែដើម្បីវាយតម្លៃសភាពការណ៍ ធ្វើរបាយការណ៍ប.ជ.រ.ព.ភ របស់ខេត្ត និងផ្ញើជូនលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ រៀងរាល់ថ្ងៃទី ២៥ នៃខែនីមួយ១ ។

- ចូលរួមកិច្ចប្រជុំវាយតម្លៃការអនុវត្តការងារ ប.ជ.រ.ព.ភ និងកិច្ចប្រជុំផ្សេងៗទៀតនៅថ្នាក់ជាតិ តាមការអញ្ជើញរបស់លេខាធិការដ្ឋានថ្នាក់ជាតិ ។

**ប្រការ៦:** រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៧:** សេចក្តីសំរេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែ ធ្នូ ឆ្នាំ ២០០៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ប្រធានគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ.**

**ស ខេង**

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
-អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ
-អគ្គស្នងការដ្ឋាននគរបាលជាតិ
-អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ
-បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
-គ្រប់សាលារាជធានី-ខេត្ត
-ដូចប្រការ១ និងប្រការ៣
-ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គស្នងការដ្ឋាននគរបាលជាតិ
លេខៈ ០០៩ អនគ

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១០

# សេចក្តីណែនាំ

## ស្តីពីការអនុវត្តកិច្ចប្រតិបត្តិការសង្គ្រោះជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និង/ឬការធ្វើអាជីវកម្មផ្លូវភេទ នៅតាមបណ្តាទីតាំងដែលបានកំណត់

ប្រតិបត្តិការសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស និង/ឬ ការធ្វើអាជីវកម្មនៅតាមបណ្តាទីតាំងដែលបានកំណត់ ត្រូវតែមានការរៀបចំ និងប្រព្រឹត្តទៅដោយប្រុងប្រយ័ត្ន ដោយផ្អែកលើគោលការណ៍គោរពសិទ្ធិជនរងគ្រោះនិងមិនត្រូវធ្វើឲ្យសុវត្ថិភាពរបស់ពួកគេប្រឈមនឹងហានិភ័យជាដាច់ខាត។ **គ្រប់កិច្ចប្រតិបត្តិការសង្គ្រោះត្រូវតែគោរពយ៉ាងខ្ជាប់ខ្ជួនទៅតាមសេចក្តីណែនាំដូចខាងក្រោម:**

**១.មុនពេលធ្វើកិច្ចប្រតិបត្តិការសង្គ្រោះ**

-ប្រមូលព័ត៌មាន ដែលមានសារៈប្រយោជន៍ឲ្យបានច្រើន តាមដែលអាចធ្វើទៅបាន អំពីទីតាំងប្រតិបត្តិការសង្គ្រោះ ជនសង្ស័យដែលពាក់ព័ន្ធ ចំនួន និងស្ថានភាពរបស់ជនរងគ្រោះ ពីសាក្សីជនរងគ្រោះ អ្នកផ្តល់ព័ត៌មាន និងភ្នាក់ងារសម្ងាត់:

| |
|---|
| *កំណត់ចំណាំ ការស៊ើបអង្កេតដោយប្រើភ្នាក់ងារសម្ងាត់ ត្រូវបានយកមកប្រើប្រាស់តែក្នុងគោលបំណងប្រមូលព័ត៌មាន និងប្រមូលភស្តុតាងដើម្បីកាត់ទោសឧក្រិដ្ឋជនតែប៉ុណ្ណោះ គឺមិនមែនមានចេតនាញុះញង់ឲ្យបុគ្គលណាមួយប្រព្រឹត្តបទល្មើសនោះឡើយ។* |

-ត្រូវព្យាយាមគូរប្លង់ ទីតាំង ដោយបញ្ជាក់ច្បាស់ពីទីកន្លែង របស់ជនរងគ្រោះ និងជនសង្ស័យស្ថិតនៅត្រង់ ណា ត្រូវបញ្ជាក់អំពីទ្វារ និងច្រកចេញដ៏ទៃទៀត។

-ត្រូវរក្សាសម្ងាត់គ្រប់ព័ត៌មានទាំងអស់។

-ត្រូវធ្វើរបាយការណ៍ជូនថ្នាក់លើ និងព្រះរាជអាជ្ញាជាបន្ទាន់ នៅពេលដែលអ្នកប្រមូលបានព័ត៌មានទាំងអស់នោះ។

-ត្រូវធ្វើការឃ្លាំមើលលើទីតាំង។

+មន្ត្រីទទួលបន្ទុកត្រូវរាយការណ៍អំពីការចេញ ឬ ចូលទៅក្នុងទីតាំងទាំងអស់ ការដឹកជញ្ជូនជនរងគ្រោះចេញ ឬ ចូលទៅក្នុងទីតាំងប្រតិបត្តិការសង្គ្រោះ ពីសកម្មភាពរបស់ជនសង្ស័យ និងព័ត៌មានប្រហាក់ ប្រហែល ដែលបានប្រមូលក្នុងអំឡុងពេលឃ្លាំមើល។

-កំណត់ និងវាយតម្លៃហានិភ័យមកលើនគរបាល ជនរងគ្រោះ និងសមាជិកសហគមន៍។

+ចាត់វិធានការឲ្យបានគ្រប់គ្រាន់ដើម្បីគ្រប់គ្រងហានិភ័យ។

-ធានាថាព័ត៌មានដែលប្រមូលបាន ផ្តល់នូវមូលដ្ឋានគ្រប់គ្រាន់ សម្រាប់ការចូលឆែកឆេរទីតាំង និងសម្រាប់កិច្ចប្រតិបត្តិការសង្គ្រោះ បានប្រព្រឹត្តទៅដោយស្របច្បាប់។

-ត្រូវទទួលបានការអនុញ្ញាតពីព្រះរាជអាជ្ញាជាមុនសិន មុននឹងអនុវត្តប្រតិបត្តិការសង្គ្រោះ ឆែកឆេរ និងចាប់ខ្លួន។

+ត្រូវចងចាំចំពោះករណី ដែលត្រូវសុំការអនុញ្ញាតពីព្រះរាជអាជ្ញាជាបន្ទាន់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ត្រូវតែជូនដំណឹងទៅព្រះរាជអាជ្ញាគ្រប់ករណីទាំងអស់ ប៉ុន្តែក្នុងករណីបន្ទាន់ការផ្តល់ការអនុញ្ញាតសម្រាប់ធ្វើការឆែកឆេរ អាចធ្វើឡើងដោយផ្ទាល់មាត់បាន។ ហើយការឆែកឆេរអាចធ្វើបាន គ្រប់ពេលវេលានៅតាមទីកន្លែងដែលបើកចំហជាសាធារណៈ។

-ត្រូវបង្កើតក្រុមការងារប្រតិបត្តិការសង្គ្រោះ និងត្រូវធ្វើការបែងចែកភារកិច្ចដល់សមាជិកទាំងអស់នៅក្នុងក្រុម។

+ចំនួនសមាសភាព និងសមាជិកនៅក្នុងក្រុមប្រតិបត្តិការសង្គ្រោះ គឺអាស្រ័យទៅលើស្ថានភាព និងហានិភ័យ (ដែលជាធម្មតាត្រូវមានចំនួនមន្ត្រីពី ១០ ទៅ ២០នាក់)។

-រៀបចំការប្រជុំផ្សព្វផ្សាយខ្លីមួយ ដើម្បីធានាថា សមាជិកនៅក្នុងក្រុមទាំងអស់ យល់ពីភារកិច្ចរបស់ពួកគេម្នាក់ៗនៅក្នុងកិច្ចប្រតិបត្តិការនិងដឹងពីវិធីដើម្បីធានានូវសុវត្ថិភាពដល់ជនរងគ្រោះនិងសិទ្ធិរបស់ជនរង គ្រោះ នៅក្នុងអំឡុងពេលនៃកិច្ចប្រតិបត្តិការសង្គ្រោះ។

-ត្រូវរៀបចំសម្ភារៈ ឧបករណ៍ចាំបាច់សំខាន់ៗនានា(ដូចជាយានជំនិះ វិទ្យុទាក់ទង ទូរស័ព្ទដៃ អាវុធរបស់ នគរបាល ខ្នោះដៃ ពិល កាមេរ៉ាថតរូប និងថតវីដេអូ កំណត់ហេតុឆែកឆេរ និងស្រោមសម្រាប់ប្រមូល និង វេច ខ្ចប់ភស្តុតាង)។

-ត្រូវជួបជាមួយមន្ត្រីបន្ទីសង្គមកិច្ច និងអង្គការក្រៅរដ្ឋាភិបាល ដែលមានឯកទេសដើម្បីធានាថា ជនរងគ្រោះនឹងទទួលបាននូវតម្រូវការចាំបាច់ (ដូចជា ទឹក ចំណីអាហារ......................) ការសង្គ្រោះបន្ទាន់ ប្រសិនជាចាំបាច់ត្រូវមានការគាំទ្រខាងផ្លូវចិត្ត និងសង្គម បន្ទាប់ពីធ្វើកិច្ចប្រតិបត្តិការសង្គ្រោះ។

+ត្រូវទំនាក់ទំនងជាមួយបុគ្គលិកមន្ទីរសង្គមកិច្ច និង បុគ្គលិកអង្គការក្រៅរដ្ឋាភិបាលដែលមានឯកទេសដើម្បីដឹងជាមុនថា តើគេត្រូវធ្វើការរៀបចំសម្រាប់ជនរងគ្រោះប៉ុន្មាននាក់ តើពេលណាដែលកិច្ចប្រតិបត្តិការសង្គ្រោះនេះនឹងកើតឡើង និងទីកន្លែងដែលជនរងគ្រោះត្រូវស្នាក់នៅ បន្ទាប់ពីកិច្ចប្រតិបត្តិការសង្គ្រោះ។

-ត្រូវកំណត់លើកាលបរិច្ឆេទ និងពេលវេលាសម្រាប់កិច្ចប្រតិបត្តិការសង្គ្រោះ។

**២.អនុវត្តប្រតិបត្តិការសង្គ្រោះ ឆែកឆេរ និង ចាប់ខ្លួន:**

-មន្ត្រីម្នាក់ៗត្រូវប្រកាន់ខ្ជាប់នូវភារកិច្ច តាមមុខងារដែលបានប្រគល់និងត្រៀមនៅជិតទីតាំងដែលត្រូវសង្គ្រោះតាមការកំណត់។

-ត្រូវធានាសុវត្ថិភាព ដល់ការចូលទៅកាន់ទីតាំងត្រូវសង្គ្រោះ និងត្រូវប្រាកដថាជនរងគ្រោះមានវត្តមាននៅទីនោះ។

+កំណត់អត្តសញ្ញាណ និងចាប់ខ្លួនជនសង្ស័យទាំងអស់ រួមទាំងភ្ញៀវផងដែរ ប្រសិនបើមានការពាក់ព័ន្ធនឹងអនីតិជន នៅក្នុងករណីដែលប្រតិបត្តិការសង្គ្រោះធ្វើនៅក្នុងផ្ទះបន វង្គសាល ភោជនីយដ្ឋាន ការ៉ាអូខេ ហាងម៉ាស្សា ឬក៏ទីតាំងធ្វើអាជីវកម្មផ្លូវភេទដែលមានលក្ខណៈប្រហាក់ប្រហែល។

+ធ្វើសកម្មភាពឲ្យបានឆាប់រហ័ស ម៉ឺងម៉ាត់ ប៉ុន្តែបើមិនចាំបាច់ទេមិនត្រូវប្រើកម្លាំងច្រើនឡើយ។

-ត្រូវបញ្ជូនជនរងគ្រោះ និងទ្រព្យសម្បត្តិរបស់ពួកគេទៅកាន់កន្លែងដែលមានសុវត្ថិភាព។

-ត្រូវប្រាប់ឲ្យជនសង្ស័យបានដឹងពីមូលហេតុ នៃកិច្ចប្រតិបត្តិការ និងហេតុផលនៃការចាប់ខ្លួន។

-ត្រូវថតយករូបភាពកន្លែងកើតហេតុ ដោយមិនត្រូវរំកិល ឬ ប៉ះពាល់របស់អ្វី ប្រសិនបើគ្មានការចាំបាច់។

-ត្រូវធ្វើការឆែកឆេរលើទីតាំងសង្គ្រោះទាំងមូល ទៅតាមវិធីសាស្ត្រត្រឹមត្រូវ ដោយមានការអនុញ្ញាតពីព្រះ រាជអាជ្ញា និងនៅចំពោះមុខជនសង្ស័យ ឬវត្តមានរបស់ម្ចាស់ផ្ទះ/អ្នកគ្រប់គ្រង ឬ ក៏សាក្សីពីរនាក់។

+ការឆែកឆេរនេះធ្វើឡើងក្នុងគោលបំណងដើម្បីស្វែងរកជនរងគ្រោះដទៃទៀត និងដើម្បីចាប់យក ភស្តុតាងនានា ដូចជា អត្តសញ្ញាណប័ណ្ណ ឯកសារធនាគារ ប្រាក់កាស ថ្នាំញៀន ឧបករណ៍គេទ ស៊ីឌី ឌីវីឌី កុំព្យូទ័រ ឧបករណ៍ផ្ទុកទិន្នន័យ ទូរស័ព្ទដៃ និងសម្ភារៈដទៃទៀត ដែលពាក់ព័ន្ធករណី។

-ត្រូវធ្វើការទំនាក់ទំនងជាមួយជនរងគ្រោះដែលបានសង្គ្រោះដោយលក្ខណៈទន់ភ្លន់មានជំនឿទុកចិត្ត និងត្រូវប្រាប់ឲ្យពួកគេដឹងថា ពេលទៅដល់ទីកន្លែងថ្មីពួកគេនឹងទទួលបានការជួយឧបត្ថម្ភពីបុគ្គលិកក្រសួងសង្គមកិច្ច ឬអង្គការក្រៅរដ្ឋាភិបាល។

-ត្រូវចុះក្នុងកំណត់ហេតុរាល់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនទាំងអស់របស់ជនរងគ្រោះ ដែលត្រូវបានដកហូតជាបណ្តោះអាសន្ន ដូចជា ទូរស័ព្ទដៃ សៀវភៅអាសយដ្ឋាន ប្រាក់កាស និងរបស់ដទៃទៀត និងថតចម្លង កំណត់ហេតុនោះជូនជនរងគ្រោះ។

+ប្រសិនបើទ្រព្យសម្បត្តិណាដែលគេមិនត្រូវការយកមកធ្វើជាភស្តុតាងទេទ្រព្យសម្បត្តិនោះគប្បី ប្រគល់ជូនទៅម្ចាស់ដើមវិញ បន្ទាប់ពីនគរបាលបានសម្ភាសន៍គេរួច។

+ត្រូវចាត់តាំងមន្ត្រីម្នាក់ឲ្យគ្រប់គ្រងទ្រព្យសម្បត្តិទាំងនេះ។

-ត្រូវធានាបានសុវត្ថិភាពក្នុងការដឹកជញ្ជូនជនរងគ្រោះទៅកាន់ទីស្នាក់ការរបស់នគរបាល។

+ត្រូវដឹកជញ្ជូនជនរងគ្រោះ និងជនសង្ស័យដោយរថយន្តផ្សេងពីគ្នា។

+ត្រូវបំបែកជនរងគ្រោះពេញវ័យចេញពីជនរងគ្រោះដែលជាអនីតិជន ឬត្រូវគេសង្ស័យថាជាអនីតិ ជន។

**<u>៣.ក្រោយពីកិច្ចប្រតិបត្តិការ:</u>**

-ត្រូវធ្វើការឆែកឆេរខ្លួនប្រាណ និងឃុំខ្លួនជនសង្ស័យនៅកន្លែងសុវត្ថិភាពរបស់នគរបាល។

+មិនត្រូវអនុញ្ញាតឲ្យជនសង្ស័យទំនាក់ទំនងគ្នា ឬទំនាក់ទំនងជាមួយជនរងគ្រោះ។

-ត្រូវសហការជាមួយមន្ទីរសង្គមកិច្ចដើម្បីផ្តល់សេវាសង្គម និងសេវាចិត្តសាស្ត្រដល់ជនរងគ្រោះ និង ដើម្បីសម្របសម្រួលការសម្ភាសន៍ជាមួយពួកគេ ព្រមទាំងផ្តល់ជូនពួកគេនូវតម្រូវការចាំបាច់នានា។

–តម្រូវការជាចាំបាច់ និងសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានកំណត់នៅក្នុងបទដ្ឋានអប្បបរមាសម្រាប់ ការពារសិទ្ធិរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

-ត្រូវពន្យល់ប្រាប់ជនរងគ្រោះអំពីរបៀប និងហេតុផលនៃការសម្ភាសន៍។

–ត្រូវពន្យល់ប្រាប់ជនរងគ្រោះថា ពួកគេមិនបានប្រព្រឹត្តបទល្មើសណាមួយទេ ហើយពួកគេក៏មិន

ត្រូវបានចាប់ខ្លួនដែរ និងត្រូវពន្យល់ទៀតថា ពួកគេមានសុវត្ថិភាព ហើយនឹងទទួលបានការ គាំពារពីសេវាកម្មនគរបាល និងសង្គម។

-ត្រូវធ្វើបទសម្ភាសន៍មួយដែលផ្តោតលើផលប្រយោជន៍ជនរងគ្រោះ ហើយការសម្ភាសន៍នេះត្រូវធ្វើនៅក្នុង បរិយាកាសមេត្រីភាព ដោយគ្មានការគំរាមកំហែង ឬការយាយីឡើយ។

+នៅពេលដែលនគរបាលសម្ភាសន៍ជនរងគ្រោះគប្បីមានវត្តមានអាណាព្យាបាល ឬមេធាវី។ រីឯការសម្ភាសន៍កុមារវិញត្រូវតែមានវត្តមានរបស់បុគ្គលដែលធ្វើជាតំណាងការពារឧត្តមប្រយោជន៍ របស់កុមារ។

+ប្រសិនបើមានសំណូមពរ ត្រូវផ្តល់ជូនជនរងគ្រោះនូវពេលវេលាសមស្របសម្រាប់ឆ្លើយនឹង សំណួរ និងផ្តល់ពេលឲ្យឈប់សំរាក ហើយទន្ទឹមនឹងនោះ ពួកគេក៏មានសិទ្ធិ មិនឆ្លើយតបនឹងសំណួរណាមួយ។

+រាល់គ្រប់ការសម្ភាសន៍ត្រូវធ្វើកំណត់ហេតុឲ្យបានពេញលេញ។

-ត្រូវតែដឹងថា អ្នកចង់បាននូវកំណត់ហេតុដែលដាក់បន្ទុកដល់ការផ្តន្ទាទោសជនល្មើស ដូច្នេះត្រូវសួរនូវសំណួរទាំងឡាយណាដែលពាក់ព័ន្ធ។

-ត្រូវបញ្ជូនភស្តុតាង និងជនសង្ស័យទៅតុលាការឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាននៅក្នុងរយៈពេល៤៨ម៉ោង។

-ត្រូវប្រគល់ទ្រព្យសម្បត្តិជូនជនរងគ្រោះវិញ។

-ត្រូវធ្វើការសហការជាមួយអាជ្ញាធរដែនដីដើម្បីបិទទ្វារទីតាំងដែលបានប្រើប្រាស់សម្រាប់ធ្វើអាជីវកម្មលើជនរងគ្រោះ ទាំងការធ្វើអាជីវកម្មពលកម្ម និងអាជីវកម្មផ្លូវភេទ។

-ត្រូវសម្ភាសន៍ជនសង្ស័យឲ្យបានម៉ត់ចត់។

+ត្រូវធ្វើកំណត់ហេតុពីការសម្ភាសន៍នេះ។

រៀបចំកសាងសំណុំរឿង និងរបាយការណ៍បញ្ជូនទៅព្រះរាជអាជ្ញា ហើយប្រសិនបើព័ត៌មានដែលប្រមូលបាន មានពាក់ព័ន្ធដល់ជនល្មើស ឬ ជនរងគ្រោះដទៃទៀត ដែលកំពុងស្ថិតនៅក្នុងស្ថានភាពត្រូវគេធ្វើអាជី វកម្ម គប្បីរាយការណ៍ព័ត៌មានទាំងនេះជូនមន្ត្រីទទួលបន្ទុកបានជ្រាប។

ទទួលបានសេចក្តីណែនាំនេះ នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នាយកដ្ឋានជំនាញ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្តទាំងអស់ត្រូវចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធភាព។

**អគ្គស្នងការនគរបាលជាតិ**

នាយឧត្តមសេនីយ៍ នេត សាវឿន

**ចម្លងជូន**

-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
-ឯកឧត្តមរដ្ឋលេខាធិការក្រសួងមហាផ្ទៃ
-ឯកឧត្តមអគ្គលេខាធិការក្រសួងមហាផ្ទៃ
-ស្នងការនគរបាលរាជធានី-ខេត្ត
-ឯកសារ-កាលប្បវត្ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គស្នងការដ្ឋាននគរបាលជាតិ
លេខៈ...០០៤......សណក

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០

# សេចក្ដីណែនាំ
## ស្ដីពី
## ការបង្ការ-បង្ក្រាបការប្រើប្រាស់គ្រឿងញៀននៅតាមកន្លែងកំសាន្ត ការជួញដូរមនុស្ស និងការលេងភ្នាល់ល្បែងគ្មានការអនុញ្ញាត

ក្រោមដឹកនាំដ៏ឈ្លៀសវៃរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា ប៉ុន្មានឆ្នាំចុងក្រោយនេះប្រទេសជាតិយើងបានបោះជំហានរីកចម្រើនយ៉ាងឆាប់រហ័សលើគ្រប់វិស័យ ជាពិសេស សេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ វប្បធម៌ និងសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ ដែលធ្វើឱ្យជីវភាពប្រជាជនមានភាពប្រែប្រួលល្អប្រសើរជាបន្តបន្ទាប់ ទាំងសេដ្ឋកិច្ចគ្រួសារ វប្បធម៌ សុជីវធម៌ របៀបរស់នៅ និងសីលធម៌សង្គម ស័ក្តិសមជាប្រទេសមួយដែលកំពុងបោះដំណើរឆ្ពោះទៅកាន់វឌ្ឍនភាពគួរជាទីមោទនៈ។

ចំពោះកងកម្លាំងនគរបាល ផ្អែកតាមតួនាទីរបស់ខ្លួនស្របគ្នានឹងការច្បាមជាប់កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងគោលការណ៍ដឹកនាំរបស់ក្រសួងមហាផ្ទៃ បានអនុវត្តប្រកបដោយជោគជ័យ និងទទួលបាននូវស្នាដៃជាច្រើនក្នុងការរួមចំណែកអភិវឌ្ឍន៍ប្រទេស ជាពិសេសបានដើរតួនាទីស្នូលសំខាន់ក្នុងការរក្សាសន្តិសុខ សណ្ដាប់ធ្នាប់ និងសុវត្ថិភាពសង្គម ដែលជាបុព្វបទមិនអាចខ្វះបាន។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ អគ្គស្នងការដ្ឋាននគរបាលជាតិ បានសង្កេតឃើញមានសកម្មភាពល្មើសដូចជា : ការប្រើប្រាស់គ្រឿងញៀន នៅតាមក្លឹបកំសាន្ត ការឆ្លៀតយកអាជីវកម្មខារ៉ាអូខេ ម៉ាស្សា-កោសជប់ខ្យល់ ដើម្បីប្រព្រឹត្តអំពើជួញដូរពេស្យាចារ និងការលួចលាក់លេងល្បែងស៊ីសង ល្បែងភ្នាល់ខុសច្បាប់ បានប្រព្រឹត្តទៅនៅតាមមូលដ្ឋានមួយចំនួន ធ្វើឱ្យជះឥទ្ធិពលមិនល្អប៉ះពាល់ដោយផ្ទាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងរបៀបរៀបរយសង្គម។

ដើម្បីលើកកំពស់ស្មារតី ម្ចាស់ការថែមទៀត ក្នុងការរ៉ាប់រងភារៈកិច្ចរបស់ខ្លួន ក៏ដូចជាការឆ្លើយតបដោយការទទួលខុសត្រូវចំពោះ ការដឹកនាំណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ សូមធ្វើការណែនាំដូចខាងក្រោម :

១-នាយកដ្ឋានកណ្ដាល នាយកដ្ឋាន និងការិយាល័យជំនាញ ដែលមានភារៈកិច្ចបង្ការ និងបង្ក្រាបការជួញដូរគ្រឿងញៀនខុសច្បាប់ ការជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មលើពលកម្មមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ និងការលេងល្បែងខុសច្បាប់គ្រប់ប្រភេទ ត្រូវបង្កើនការទទួលខុសត្រូវលើតួនាទីដែលបានប្រគល់ឱ្យ ដោយខិតខំជំរុញការអនុវត្តន៍បណ្ដាគោលការណ៍ វិធានការ និងទិសដៅទាំងឡាយដែលក្រសួងមហាផ្ទៃ ក៏ដូចជាអគ្គស្នងការដ្ឋាននគរបាលជាតិ បាន

ដាក់ចេញកន្លងមកឱ្យមានប្រសិទ្ធភាពខ្ពស់ សំដៅធ្វើឱ្យបទល្មើសទាំងនោះថយចុះជាអប្បបរមា និងឈានទៅលុបបំបាត់ឱ្យបាននាពេលអនាគត ។

**២**–គ្រប់ស្នងការដ្ឋាននគរបាលរាជធានី–ខេត្ត អធិការដ្ឋាននគរបាលក្រុង–ស្រុក–ខណ្ឌ និងប៉ុស្តិ៍នគរបាលរដ្ឋបាល ត្រូវក្ដាប់ឱ្យបាននូវបណ្ដាមូលដ្ឋានអាជីវកម្មដែលមានលក្ខណៈងាយស្រួលឱ្យជនល្មើសប្រព្រឹត្តសកម្មភាពប្រើប្រាស់គ្រឿងញៀន ឬសកម្មភាពជួញដូរមនុស្ស (ជួញដូរពេស្យាចារ) ដូចជា : កន្លែងប្រកបអាជីវកម្មរាំ–ច្រៀង–អាហារដ្ឋានគ្រប់ប្រភេទ សណ្ឋាគារ ផ្ទះសំណាក់ ផ្ទះជួល ម៉ាស្សា–កោសជប់ខ្យល់...។ល។ នៅក្នុងភូមិសាស្ត្រទទួលខុសត្រូវរបស់ខ្លួន ដើម្បីមានវិធានការគ្រប់គ្រងឱ្យបានល្អ ។

**៣**–ត្រូវតម្លើងបញ្ជីមូលដ្ឋានទាំងនេះឱ្យបានច្បាស់លាស់ និងធ្វើសេនាធិការជូនគណៈបញ្ជាការឯកភាពរាជធានី–ខេត្ត ដើម្បីប្រគល់ភារៈកិច្ចឱ្យថ្នាក់នីមួយៗទទួលខុសត្រូវគ្រប់គ្រង ដូចខាងក្រោម :

**–ប្រភេទ ក** : ប្រគល់ឱ្យប៉ុស្តិ៍នគរបាលរដ្ឋបាល គ្រប់គ្រង

**–ប្រភេទ ខ** : ប្រគល់ឱ្យអធិការដ្ឋាននគរបាលក្រុង–ស្រុក–ខណ្ឌ គ្រប់គ្រង

**–ប្រភេទ គ** : ប្រគល់ឱ្យស្នងការដ្ឋាននគរបាលរាជធានី–ខេត្ត គ្រប់គ្រង

**៤**–ត្រូវធ្វើសេនាធិការជូនគណៈបញ្ជាការឯកភាពគ្រប់ជាន់ថ្នាក់ និងសហការជាមួយអង្គភាព ឬស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំជួបប្រជុំឱ្យបានញឹកញាប់ជាមួយម្ចាស់មូលដ្ឋានអាជីវកម្ម និងអ្នកគ្រប់គ្រងទាំងអស់ដើម្បីផ្សព្វផ្សាយអំពីច្បាប់ អប់រំឱ្យមានការទទួលខុសត្រូវ និងធ្វើកិច្ចសន្យាហាមប្រាមការយកទីតាំង ឬអនុញ្ញាតឱ្យគេប្រព្រឹត្តសកម្មភាពប្រើប្រាស់គ្រឿងញៀន ឬជួញដូរមនុស្ស និងកំណត់កាតព្វកិច្ចត្រូវរាយការណ៍ពេលឃើញមានបាតុភាពសង្ស័យកើតឡើង ។

**៥**–នាយកដ្ឋានជំនាញត្រូវសរសេរដកស្រង់ខ្លឹមសារច្បាប់ ដោយសង្ខេបអំពីការផ្ដន្ទាទោសចំពោះការចែកចាយ ការជួញដូរគ្រឿងញៀន និងសកម្មភាពជួញដូរមនុស្សប្រគល់ឱ្យស្នងការដ្ឋាននគរបាលរាជធានី–ខេត្ត ណែនាំឱ្យម្ចាស់មូលដ្ឋានអាជីវកម្មទាំងអស់ចម្លងបិទនៅតាមបន្ទប់ ឬកន្លែងដែលពិនិត្យឃើញថាមានការចាំបាច់ ដើម្បីរំលឹក ឬព្រមានដល់អ្នកមកកាន់កន្លែងនេះឱ្យចងចាំ និងប្រុងប្រយ័ត្ន។

**៦**–ត្រូវធ្វើការណែនាំ ជូនដំណឹងដល់ម្ចាស់មូលដ្ឋានអាជីវកម្មទាំងអស់ឱ្យពង្រឹងការអនុវត្តន៍ម៉ឺងម៉ាត់ ខ្លឹមសារលិខិតជូនដំណឹងរបស់ទីស្ដីការគណៈរដ្ឋមន្ត្រីលេខ ១២៨០ សជណ ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០០៩ ជាពិសេសការហាមក្មេងអាយុក្រោម ១៦ឆ្នាំ ចូលស្នាក់នៅសណ្ឋាគារ ផ្ទះសំណាក់ ក្លឹបកំសាន្ត និងកន្លែងសប្បាយភាពផ្សេងៗតែម្នាក់ឯង គ្មានការចូលរួមដំណើរពីអាណាព្យាបាល ឬឪពុកម្ដាយ និងហាមយុវជន យុវនារី ក្រោមអាយុ ១៨ឆ្នាំ ចូលក្លឹបរាត្រី និងហូបគ្រឿងស្រវឹងក្រោយម៉ោង ២១:០០នាទី។

**៧**–ត្រូវយកចិត្តទុកដាក់ក្នុងការលុបបំបាត់ឱ្យបានជាដាច់ខាតការឆ្លៀតបើកឱ្យមានការរាំស្រាតនៅតាមមូលដ្ឋានអាជីវកម្ម រាំច្រៀងមួយចំនួនដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយស សេចក្ដីថ្លៃថ្នូរ និងប្រពៃណីជាតិ ។

**៨**–ក្នុងករណីរកឃើញមានការប្រព្រឹត្តសកម្មភាពល្មើសនៅមូលដ្ឋានអាជីវកម្មណាមួយ ត្រូវខិតខំប្រមែប្រមូលភស្តុតាង សាក្សីឱ្យបានគ្រប់គ្រាន់ រួចហើយរាយការណ៍ស្នើសុំគណៈបញ្ជាការ

